# “ខ្ញុំចង់ជំរាបប្រាប់លោកអ្នក”

## អំពើហិង្សាខាងផ្លូវភេទក្នុងកំឡុងពេល
## នៃរបបកម្ពុជា ប្រជាធិបតេយ្យ
## ( ១៩៧៥_១៩៧៩)



**សមាជិកក្រុមការងារស្រាវជ្រាវ**

## ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
ផ្ទះលេខ ១២ ផ្លូវលេខ ២៨២ សង្កាត់បឹងកេងកង១
ក្រុងភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ: ( ៨៥៥) ២៣ ៧២០ ០៣២
ទូរសារ: ( ៨៥៥) ២៣ ៧២០ ០៣១
ខែវិច្ឆិកា ឆ្នាំ២០០៦

សំរាប់ព័ត៌មានបន្ថែម:
sok_sam_oeun@cdpcambodia.org
kasumi611@online.com.kh

# អារម្ភកថា



សុក សំអឿន

តាំងនាមឱ្យក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណចំពោះ វិទ្យាស្ថានសង្គមបើកចំហ (OSI) ដោយបានគាំទ្រគំរោងការនេះ ស្តីអំពីបទឧក្រិដ្ឋផ្លូវភេទ ក្នុងកំឡុងពេលនៃរបបខ្មែរក្រហម។ របាយការណ៍នេះ ផ្អែកទៅតាមការស្រាវជ្រាវដែល ធ្វើឡើងក្នុងប្រទេសកម្ពុជាចន្លោះខែមីនា និង ខែកញ្ញា ឆ្នាំ២០០៦។

ក្នុងកំឡុងពេលនៃរបបខ្មែរក្រហមប្រជាជនខ្មែរទាំងអស់ សុទ្ធតែជាអ្នករងគ្រោះ។ របាយការណ៍ និង សៀវភៅមួយចំនួន បានពន្យល់ពីរបៀបដែលយើងទទួលរងគ្រោះ និង ពីរបៀបដែលយើងអាចរស់រៀនមានជីវិតបាន។ ក៏ប៉ុន្តែ នៅពេលចូលដល់រឿងអំពើហិង្សាខាងផ្លូវភេទ ដែលកើតមានឡើងក្នុងកំឡុងពេលនៃរបបខ្មែរក្រហម រឿងនេះមិនត្រូវបានគេចងក្រងជាឯកសារគ្រប់គ្រាន់នៅឡើយទេ។ ក្នុងនាមជាអ្នករងគ្រោះម្នាក់ដែលនៅមានជីវិតនៅឡើយនោះ ខ្ញុំមានបំណងរៀបចំចងក្រងជាឯកសារអំពើហិង្សាខាងផ្លូវភេទក្នុងកំឡុងពេលនៃរបបខ្មែរក្រហម។

កម្មវិធីនេះត្រូវបានផ្តួចផ្តើមឡើង និង ចាត់ចែងដោយលោកស្រី ណាកាហ្គាវ៉ា កាស៊ូមី ប្រធានកម្មផ្សព្វផ្សាយ និង ការតស៊ូមតិ ផ្នែកច្បាប់របស់អង្គការ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។ លោកស្រី កាស៊ូមី មានគំនិតមួយថា រឿងអំពើហិង្សាខាងផ្លូវភេទក្នុងកំឡុងពេលរបបខ្មែរក្រហម គួរតែចងក្រងជាឯកសារឱ្យបានត្រឹមត្រូវ ដើម្បីទុកឱ្យមនុស្សជំនាន់ក្រោយបានដឹងផង។ បញ្ហានេះ គឺដោយសារតែលោកស្រីមានបទពិសោធន៍ដែលថា អំពើឃោរឃៅរបស់ ជប៉ុនទៅលើ ‘ស្ត្រីបំរើផ្លូវភេទ (ទាសករផ្លូវភេទសំរាប់ទាហានជប៉ុនក្នុងកំឡុងពេលសង្គ្រាមលោកលើកទី២)’ មិនត្រូវបានគេចងក្រងជាឯកសារត្រឹមត្រូវ ហើយក៏មិនត្រូវបានគេយកទៅសិក្សាតាម

សាលារៀនទៀតផង។ លោកស្រីបានផ្តល់ដំបូន្មានដល់ខ្ញុំថា យើងគប្បីរៀបចំជាឯកសារប្រវត្តិសាស្ត្រដើម្បីឱ្យមនុស្សជំនាន់ក្រោយបានដឹង និងចងចាំនូវប្រវត្តិសាស្ត្ររបស់ខ្លួន។ ផ្តើមចេញពី ដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលធនធានស្ត្រីជប៉ុន-អាស៊ី (AJWRC) មកកាន់ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាកាលពីខែមីនា ឆ្នាំ២០០៥ ដែលបានធ្វើការងារលើបញ្ហាស្ត្រី បំរើផ្លូវភេទក្នុងទ្វីបអាស៊ី។ ខ្ញុំ និង លោកស្រី កាស៊ូមី បានធ្វើការ ពិភាក្សាគ្នា មួយចំនួនដើម្បីសំរេចបាននូវគំនិតសិក្សា ស្រាវជ្រាវនេះ។

លោកស្រី រី ណាកាមូរ៉ា បុគ្គលិកវិទ្យាស្ថានសង្គមសេរី (OSI) ក្នុងខេត្តឈៀងម៉ៃ ប្រទេសថៃ បានលើកទឹកចិត្តឱ្យលោកស្រី កាស៊ូមី ដាក់សំណើសុំមួយនៅពេលលោកស្រីស្វះស្វែងរកមូលនិធិសំរាប់គំរោងនេះ។ បើគ្មានការលើកទឹកចិត្ត និង ការគាំទ្រពីលោកស្រី រី ទេ គំរោងនេះច្បាស់ជា មិនអាចសំរេចបានដែរ។ ខ្ញុំសូមថ្លែងអំណរគុណលោកស្រី ដែលបានគាំទ្រយ៉ាងកក់ក្តៅដល់បុគ្គលិករបស់យើងខ្ញុំ។

ក្រៅពីលោកស្រី កាស៊ូមី ក៏នៅមានមនុស្សជាច្រើនផ្សេងទៀត ចូលរួមអនុវត្តកម្មវិធីនេះដែរ។ លោកស្រី មាស សុខុម ប្រធានមជ្ឈមណ្ឌលធនធានស្ត្រី (WRC) នៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានផ្តល់ជំនួយបច្ចេកទេសដល់គំរោងនេះទាំងមូល។ មជ្ឈមណ្ឌលធនធានស្ត្រី មានបណ្តាញការងារទូលំទូលាយក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី ក្នុងខេត្តចំនួន៥ ហើយលោកស្រី មាស សុខុម បានជួយសំរួលការងារស្រាវជ្រាវតាមរយៈបណ្តាញការងារនេះ។ សមាជិកអ្នកស្រាវជ្រាវរួមមាន Bridgette Toy-Cronin, ជា កេណ្ឌារិទ្ធិ ហេង គាង. ហុង គុណ. Julien Rouyrre, លោក គីម ហឿន និងកញ្ញា ម៉ី សូម៉ាលី។ ខ្ញុំថ្លែង អំណរគុណយ៉ាងជ្រៀលជ្រៅ ចំពោះប្អូនៗនៃសាកលវិទ្យាល័យ បញ្ញាសាស្ត្រ ដែលបានជួយត្រួតពិនិត្យអត្ថបទនេះ ចុងក្រោយដែលមានឈ្មោះគីម សីហា មែន មុនីតារា ឃុន

ចាន់ដារ៉ាស៊ី សាមិត្ត វ៉ឌ្ឍនឧត្ដម សួង កញ្ញា និង នូ ច័ន្ទដាលីស។ ខ្ញុំសប្បាយចិត្តដោយបានឃើញក្រុមការងារគំរោងនេះធ្វើការងារ ប្រកបដោយប្រសិទ្ធភាព ទោះបីជាបានប្រឈមមុខនឹងការងារដ៏លំបាកក្នុងការរៀបចំជាឯកសារប្រវត្តិសាស្ត្រ ដែលមិនអាចរៀបរាប់បានរបស់កម្ពុជា នេះក៏ដោយ។ ខ្ញុំសប្បាយរីករាយផងដែរដោយបានឃើញការប្ដេជ្ញាចិត្តរបស់សមាជិក ក្រុមយុវជនចំពោះការងារស្រាវជ្រាវនេះ វាជាសញ្ញាយ៉ាងច្បាស់ថា យុវជនក៏ចង់ដឹងនូវព្រឹត្តិការណ៍ ដែលបានកើតមានចំពោះមាតាបិតារបស់ខ្លួនក្នុងរយៈពេលនៃរបបខ្មែរក្រហមផងដែរ។

យើងសូមថ្លែងអំណរគុណ ដល់អ្នកចូលរួមក្នុងការស្ទង់មតិដំបូង និងបទសម្ភាសន៍ ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ ដើម្បីចែករំលែកដល់យើងខ្ញុំនូវរឿងរ៉ាវដ៏ក្រៀមក្រំរបស់ខ្លួន។ យើងសូមថ្លែងអំណរគុណជាពិសេស ចំពោះភ្នាក់ងារឃ្លាំមើលអំពើហិង្សាក្នុងគ្រួសារ របស់មជ្ឈមណ្ឌលធនធានស្ត្រីនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលបានធ្វើការស្ទង់មតិបឋម និង ជួយសម្រួលដល់ការសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ។

ខ្ញុំសប្បាយរីករាយដោយបានបញ្ជូនរបាយការណ៍អំពីលទ្ធផល នៃអំពើហិង្សាទាំងនោះដល់អ្នកអាន។ ខ្ញុំមានសេចក្ដីសង្ឃឹម ដ៏ស្មោះត្រង់ថា របាយការណ៍នេះនឹងចូលរួមចំណែកដល់ការផ្សះផ្សាជាតិក្នុងរង្វង់ប្រជាជនកម្ពុជាយើង និង មនុស្សជំនាន់ក្រោយៗទៀត។

**សុក សំអឿន**

នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

*រាល់ឈ្មោះទាំងអស់ដែលប្រើក្នុងរបាយការណ៍នេះសុទ្ធតែជាឈ្មោះប្រឌិត*
*ដើម្បីរក្សាភាពសំងាត់ដល់អ្នកទាំងឡាយដែលបានចូលរួមក្នុងការងារស្រាវជ្រាវនេះ ។*

## មាតិកា

I. សេចក្ដីផ្ដើម ....................................................................................១១

II. អំពើរំលោភ ......................................................................................១៤

ក- រំលោភមុនពេលសំលាប់ ....................................................................១៦

ខ- ការប្រើអំណាចបំពាន-កម្មាភិបាល យោធា និង កងឈ្លប ........................២០

គ- រំលោភក្នុងគុក និង ក្នុងមណ្ឌលកសាង ..................................................២៨

ឃ- រំលោភសមាជិកក្រុមខ្លួន-រំលោភស្ត្រីកម្មាភិបាលខ្មែរក្រហម ...................៣១

III. អំពើរំលោភដទៃទៀត ........................................................................៣៤

ក-ការដាក់ទណ្ឌកម្មខាងផ្លូវភេទចំពោះទំនាក់ទំនងដែលមានការ ព្រមព្រៀងគ្នាហើយ ...........................................................................៣៦

IV. ការរំលោភផ្លូវភេទទៅលើបុរស ............................................................៣៧

V. អំពើហិង្សាខាងផ្លូវភេទ និង អាពាហ៍ពិពាហ៍ដោយការចាប់បង្ខំ ....................៣៩

ក- សេចក្ដីផ្ដើម ......................................................................................៣៩

ខ- ការរំលោភដោយអំពើចាប់បង្ខំ ............................................................៤២

គ- ការបង្ខំរួមភេទក្នុងចំណងអាពាហ៍ពិពាហ៍ ...............................................៤៣

ឃ- ស្ត្រីជារង្វាន់មួយ ..............................................................................៤៦

ង- សេចក្ដីសន្និដ្ឋាន ..............................................................................៥១

VI. ឱកាសសំរាប់ការកាត់ទោស ..................................................................៥២

ក- តើគេកាត់ទោសនរណាខ្លះ? ..................................................................៥២

ខ- បទឧក្រិដ្ឋ ........................................................................................៥៣

គ- បង្ហាញពីការទទួលខុសត្រូវ ...................................................................៥៤

*១- ការទទួលខុសត្រូវផ្ទាល់* ........................................................ **៥៤**
*២- ការទទួលខុសត្រូវរបស់ប្រធាន* ............................................. **៥៥**
ឃ- ជាឧទាហរណ៍គំរូមួយ-ការរំលោភជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ............................................................................ **៥៥**
ង- សេចក្តីសន្និដ្ឋាន .................................................................... **៥៦**
ច- សំដៅដល់អំពើហិង្សាខាងផ្លូវភេទ .......................................... **៥៧**
VII. អង្គការមិនមែនរដ្ឋាភិបាល យេនឌ័រ និង សាលាក្តីពិសេស ........................ **៥៨**
VIII. ការអប់រំសាធារណជន ................................................................... **៦២**
ក- ការអប់រំសុវត្ថិភាពសាធារណៈ ................................................ **៦៣**
ខ- អត្ថប្រយោជន៍សំរាប់ប្រទេសកម្ពុជាបច្ចុប្បន្ន ............................ **៦៥**
IX. សេចក្តីសន្និដ្ឋាន ........................................................................... **៦៦**
X. វិធីសាស្ត្រស្រាវជ្រាវ .......................................................................... **៦៧**
XI. ជំរើសឯកសារយោង ........................................................................ **៧១**

# I- សេចក្តីផ្តើម

ម្តាយរបស់ខ្ញុំ បានសួរខ្ញុំថាតើមនុស្សប្រុសប៉ុន្មាននាក់បានរំលោភខ្ញុំ? ហើយខ្ញុំបានប្រាប់គាត់ថាមានមនុស្សប្រុស២នាក់ បានរំលោភខ្ញុំ ហើយគាត់និយាយថា “ព្រះអើយ! កូននៅក្មេងណាស់...ហ្នះហើយយើងត្រូវអត់ធ្មត់ ដើម្បីជីវិតយើងរស់ ដូច្នេះយើងត្រូវតែស៊ូទ្រាំទទួលអ្វីដែលកើតមានចំពោះយើងទៅចុះ... យើងត្រូវតែ មានជីវិតរស់នៅតទៅទៀត...”

នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា ដែលប្រជាជនទូទៅស្គាល់ថាជាខ្មែរក្រហមនោះ បានដឹកនាំបដិវត្តន៍កុម្មុយនិស្តដាច់ខាតមួយដែលបានសំលាប់ប្រជាជនជាងមួយលាននាក់។ អ្នកដែលនៅរស់រវៀនមានជីវិតពីបដិវត្តន៍នោះ រស់នៅដោយមានស្លាកស្នាមលើរាងកាយ ហើយមានការចងចាំនូវអំពើហិង្សាភាពអត់ឃ្លាន ការភ័យខ្លាច និង ក្តីមន្ទិល។ អត្ថបទអក្សរសាស្ត្រដែលបានរ៉ាយរ៉ាប់ពីប្រវត្តិនៃការធ្វើបដិវត្តន៍ ដោយចេញពីទស្សនវិស័យផ្ទាល់ខ្លួន និង បែបសិក្សានោះ មានខ្លឹមសារត្រឹមត្រូវច្បាស់លាស់។ របាយការណ៍នោះ មានបំណងបន្ថែមសេចក្តីពិស្តារ និង ការយល់ដឹងឱ្យស៊ីជំរៅ ចំពោះទិដ្ឋភាព ពិសេសនៃបដិវត្តន៍នោះ ដែលទទួលការចាប់អារម្មណ៍ តិចតួច ដូចជាអំពើហិង្សាខាងផ្លូវភេទ។

នៅពេលកងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកគេបានបង្កឱ្យមានការវិនាសកម្ម និង ការឈឺចាប់ខ្លោចផ្សាដល់ប្រជាជនកម្ពុជា ដែលមានរយៈពេលប្រមាណ៣ឆ្នាំ និង បង្កឱ្យមានភាពអន្តរាយឥតគណនាដល់អនាគតប្រទេសជាតិ។ ពួកគេឱ្យឈ្មោះប្រទេសថ្មីនេះថាជា ‘កម្ពុជាប្រជាធិបតេយ្យ’។ រដ្ឋាភិបាលជឿជាក់ថា បដិវត្តន៍ក្នុងកម្ពុជា ប្រជាធិបតេយ្យ មិនត្រូវការរយៈពេលមួយដើម្បីធ្វើការផ្លាស់ប្តូរឡើយ គឺ ពួកគេធ្វើការផ្លាស់ប្តូរ

ប្រទេសនេះតែរយៈពេលមួយយប់ប៉ុណ្ណោះ។ ពួកគេធ្វើការជន្លាសប្រជាជនចេញពីទីក្រុង ដោយបញ្ជូនប្រជាជនថ្មី ឬ ១៧មេសា ជាអ្នករស់នៅទីក្រុងដែលមានកេរ្តិ៍វប្បធម៌ និងកេរ្តិ៍ជីវភាពរស់នៅ ដែលរដ្ឋាភិបាលជឿថាអាចគំរាមកំហែងដល់បដិវត្តន៍ឱ្យទៅរស់នៅតាមទីជនបទ ។ អ្នកទីក្រុងប្រមាណពី២ទៅ៣លាននាក់ បានចាកចេញពីទីក្រុងដោយថ្មើរជើងទៅទីជនបទរស់នៅជាមួយប្រជាជនមូលដ្ឋានជាកសិករ ដែលរដ្ឋាភិបាលចាត់ទុកថាជាជនមិនពុករលួយតាមគំនិតអ្នកក្រុង ហើយដែលជាអ្នកកាន់អំណាចក្នុងសណ្តាប់ធ្នាប់សង្គមថ្មីនេះ។

រយៈពេលជាច្រើនសតវត្សមកហើយ ដែលប្រជាជនកម្ពុជារស់នៅប្រកបមុខរបរកសិកម្មចិញ្ចឹមជីវិតក្នុងក្រុមគ្រួសារ។ ក៏ប៉ុន្តែរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបញ្ចូលកសិកម្មសហគមន៍ និង រៀបចំប្រជាជនតាមសហករណ៍កសិកម្មយ៉ាងឆាប់រហ័ស។ កម្ពុជាត្រូវបានចែកជាតំបន់រដ្ឋបាលចំនួន៧តំបន់ ក្នុងនោះមានជាតំបន់ ស្រុក ឃុំ និង សហករណ៍ ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងគ្រប់លំដាប់ថ្នាក់។ ប្រជាជនត្រូវឆ្លើយតបនឹងឆន្ទៈរបស់អំណាចរដ្ឋាភិបាលដែលមានឈ្មោះថា "អង្គការ"។ អង្គការមិនត្រឹមតែគ្រប់គ្រងការងារប្រជាជនប៉ុណ្ណោះទេ ថែមទាំងចូលដល់គ្រប់ទិដ្ឋភាពរស់នៅរបស់ប្រជាជនទៀតផង។ ក្រុមគ្រួសារ ត្រូវបានបំបែកចេញពីគ្នា ក្នុងនោះកូនឃ្លាតពីឪពុកម្តាយ ប្រជាជនត្រូវតែហូបរួមគ្នា មិនមានលុយចាយ និង មិនមានកម្មសិទ្ធិឯកជន អង្គការគ្រប់គ្រង និង រៀបចំអាពាហ៍ពិពាហ៍ឱ្យប្រជាជន ហើយទំនាក់ទំនងផ្លូវភេទ ក្រៅចំណងអាពាហ៍ពិពាហ៍ត្រូវហាមឃាត់ ។ ទណ្ឌកម្មចំពោះអំពើល្មើសទាំងនេះមានការងារជាទំងន់ បញ្ជូនទៅតំបន់ដាច់ស្រយាល ចាប់ដាក់គុក រឺ សំលាប់ចោល។ ខណៈពេលដែលបដិវត្តន៍ត្រូវអនុវត្តដោយកេរ្តិ៍ធ្ងន់ ឬស្រាលតាមតំបន់ផ្សេងក្នុងប្រទេស ពុំមាននរណាម្នាក់គេចផុតពីរយៈពេលនៃការ ផ្លាស់ប្តូរសង្គមដ៏ព្រៃផ្សៃ និងឆាប់រហ័សនេះបានឡើយ។ ក្នុងរយៈពេលជាច្រើនឆ្នាំនៃកម្ពុជាប្រជាធិបតេយ្យ

រដ្ឋាភិបាលបានដាក់គុក ធ្វើទារុណកម្ម និង សំលាប់មនុស្សរាប់ពាន់នាក់ដែលពួកគេចោទថាជាខ្មាំងរបស់បដិវត្តន៍ រួមទាំងកម្មាភិបាលខ្មែរក្រហមមួយចំនួន ដែលពួកគេជឿថាជាសត្រូវរបស់ខ្លួន។ នុស្សភាគច្រើនស្លាប់ដោយសារការធ្វើការងារហួសកំលាំង អត់អាហារ អត់ថ្នាំសង្កូវ ព្យាបាលជំងឺ។

ការសំលាប់សមាជិកគ្រួសារ ទុក្ខវេទនាក្នុងជីវិតប្រចាំថ្ងៃ ជាពិសេសការខ្វះការបង្អត់អាហារជាប្រចាំបានស្ថិតក្នុងអារម្មណ៍ចងចាំយ៉ាងខ្លាំងរបស់អ្នកនៅមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ។ អំពើហិង្សាខាងផ្លូវភេទ ទោះជាអ្នកដែលនៅមានជីវិត និង សាក្សីមិនបានលើកយកមកពិភាក្សាញឹកញាប់ក៏ដោយ ក៏ជាបញ្ហាសំខាន់ចំពោះបទពិសោធន៍របស់មនុស្សភាគច្រើនផងដែរ។ សង្គមកម្ពុជាចាត់ទុក អំពើហិង្សាផ្លូវភេទជាប្រធានបទមួយមិនគួរយកមកពិភាក្សាទេ។ ដូចសុភាសិតខ្មែរពោលថា បើសំពត់របស់អ្នករហែក ចូរកុំហែកវាបន្ថែមទៀត។ ការនិយាយអំពីអំពើហិង្សាផ្លូវភេទគឺគ្រាន់តែជាការបន្ថែមទំងន់ទៅលើជនរងគ្រោះតែប៉ុណ្ណោះ។ ការយល់ឃើញជារួមបែបនេះ អាចធ្វើឱ្យការសិក្សាពីអំពើហិង្សាផ្លូវភេទនៅកម្ពុជា និងនៅប្រទេសដទៃទៀតមានការលំបាក។ ឧបស័គ្គយល់ឃើញដទៃទៀតដល់ការសិក្សាអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺ ជាជំនឿដែលថា អំពើហិង្សាផ្លូវភេទមានជាកំរណាស់ នៅពេលរដ្ឋាភិបាលមានគោលនយោបាយយ៉ាងច្បាស់លាស់ប្រឆាំងនឹង ទំនាក់ទំនងផ្លូវភេទ ទោះជាព្រមព្រៀងគ្នា ឬមិនព្រមព្រៀងគ្នាក៏ដោយ។ ជាងនេះទៅទៀត មនុស្សភាគច្រើននៅកម្ពុជា ជឿថា ពុំមាននរណាម្នាក់នៅរស់ដើម្បីនិយាយរឿងអំពើហិង្សាផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ដូចជាអ្នកទាំងឡាយដែលប្រព្រឹត្តអំពើល្មើសនេះ ព្យាយាមបំផ្លាញភស្តុតាងស្លាកស្នាមនៃអំពើហិង្សាផ្លូវភេទទាំងអស់ដោយសំលាប់គ្រប់ជនរងគ្រោះ។

គោលបំណងជាចំបងនៃគំរោងនេះគឺ រិះរកឱ្យឃើញ និង រៀបរាប់ចំលើយកសិណសាក្សីនៃអ្នកដែលរួចផុតពីអំពើហិង្សាផ្លូវភេទ និង ចំលើយរបស់សាក្សីដែលបានឃើញអំពើឃោរឃៅទាំងនេះ។ របាយការណ៍នេះ ផ្អែកតាមបទសម្ភាសន៍ជាមួយអ្នករួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យជិត១០០នាក់ ដែលបានស្គាល់អត្តសញ្ញាណតាមរយៈការស្ទង់មតិមនុស្ស១៥០០នាក់ ដែលមានអាយុច្រើនជាង ១២ឆ្នាំ នៅពេលខ្មែរក្រហមឡើងកាន់អំណាច។ គេបានពិភាក្សាពីដំណោះស្រាយសំរាប់ជនរងគ្រោះ រួមមានឱកាសដើម្បីកាត់ទោសក្នុងសាលាជំរះក្តីពិសេសក្នុងតុលាការកម្ពុជា និង មតិយោបល់ចំពោះរបៀបអាចចែករំលែករឿងទាំងនេះ ឱ្យកាន់តែទូលំទូលាយជាមួយអ្នកអានឱ្យបានកាន់តែច្រើន។ ជាការពិតណាស់ មនុស្សភាគច្រើន ដែលត្រូវបានសួរសុខចិត្តនៅស្ងៀមមិននិយាយពីបទពិសោធន៍របស់ខ្លួន តែមនុស្សជាច្រើនទៀត រីករាយនឹងចែករំលែករឿងរបស់ខ្លួន។ ដូចលោក សូនី និយាយថា "ខ្ញុំសប្បាយរីករាយដោយលោកត្រូវគេសួរពីរឿងនេះ។ ខ្ញុំនឹងជំរាបប្រាប់លោករឿងទាំងអស់។ វាធ្វើឱ្យខ្ញុំមានអារម្មណ៍កាន់តែល្អ។"

## II. **ការរំលោភ**

តួលេខជាក់លាក់ពីចំនួនអ្នករងគ្រោះពីការរំលោភ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនបានដឹងពិតប្រាកដទេ។ ក្នុងការសិក្សាអំពីប្រជាជនកម្ពុជាដែលរស់នៅក្នុងជំរុំព្រំដែនថៃដ៏ធំបំផុតនោះ មានជនភៀសខ្លួនចំនួន១៧ភាគរយ ក្នុងចំណោម ៩៩៣នាក់ ដែលបានសម្ភាស បានទទួលរងការរំលោភផ្លូវភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បើសិនជាតួលេខនេះយកមក និយាយជាទូទៅដល់ប្រជាជនទាំងមូល នោះអាចមានមនុស្សរាប់ម៉ឺននាក់ដែលរងគ្រោះដោយការចាប់រំលោភ ឬតាមរូបភាពដទៃទៀតនៃអំពើហិង្សាផ្លូវភេទ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ខ្មែរក្រហមហាមឃាត់ជាផ្លូវការមិនឱ្យមានទំនាក់ទំនងផ្លូវភេទ ក្រៅចំណង អាពាហ៍ពិពាហ៍ ហើយបើសិនអង្គការរកឃើញនរណាម្នាក់ល្មើសនឹងបទបញ្ញត្តិនេះ អង្គការអាចដាក់ទណ្ឌកម្ម ឬសំលាប់ទាំងស្រីទាំងប្រុស។ គោលនយោបាយនេះ អនុវត្តដោយមិនគិតអំពីថាតើមានការព្រមព្រៀងគ្នាឬគ្មានឡើយ គឺអង្គការនឹងដាក់ទណ្ឌកម្ម ឬសំលាប់ទាំងជនរងគ្រោះទាំងជនល្មើស បើរកឃើញថាជាអំពើរំលោភ។

មិនមែនជាការបញ្ឈប់អំពើរំលោភ គោលនយោបាយខ្មែរក្រហមប្រឆាំងនឹងអំពើរំលោភបំពាន បង្កើតជាបរិយាកាស និទ្ទណ្ឌភាព ដល់ជនល្មើសទៅវិញ។ ជនរងគ្រោះ និង សាក្សីរក្សាអំពើល្មើសជាការសម្ងាត់ដោយភ័យខ្លាចការចាប់ដាក់គុក ឬសំលាប់ចោល។ ដូច្នេះ ជនល្មើសអាចប្រព្រឹត្តដោយគ្មានទោសដ៏រាបណាពួកគេអាចបិទបាំង បទល្មើសនេះ ពីប្រធានដែលអនុវត្តគោលនយោបាយនេះ។

សម្ភាសិតបានជំរាបប្រាប់អំពីរបៀប ដែលប្រធានអនុវត្តគោលនយោបាយប្រឆាំងនឹងទំនាក់ទំនងផ្លូវភេទ ទោះជាព្រមព្រៀងក្តី មិនព្រមព្រៀងក្តី។ លោកបូណា ដែលបានឃើញការរំលោភនារីក្មេងម្នាក់ បានពន្យល់ថា ជនល្មើសនឹងត្រូវសំលាប់ បើសិនខ្ញុំរាយការណ៍រឿងនេះទៅថ្នាក់លើ ពីព្រោះពួកគេធ្វើឱ្យខូចកិត្តិយសអង្គការ។ លោកចាន់ថុល ដែលបានជាប់គុកក្នុងរបបខ្មែរក្រហម បានពន្យល់ពីរបៀបនាយទាហានធ្វើទណ្ឌកម្មដល់កូនទាហាន បើសិនគេរកឃើញថា ទាហានទាំងនោះប្រព្រឹត្តបទល្មើសផ្លូវភេទ ដោយគេសម្រាលពាក្យថា ប្រព្រឹត្តខុសសីលធម៌។

ទាហានសក្តិតូចត្រូវបានសំលាប់ដោយទាហានសក្តិធំជាង បើគេរកឃើញថាទាហានសក្តិតូចជាងនោះប្រព្រឹត្តបទរំលោភ ហើយមុនសំលាប់ គេដាក់សញ្ញាលើខ្លួនទាហានទាំងនោះថា ‘ខ្ញុំបានប្រព្រឹត្តខុសសីលធម៌’ ហើយពួកគេត្រូវជីករណ្តៅដោយខ្លួនឯង។

ហេតុដូច្នេះ មិនមែនជារឿងភ្ញាក់ផ្អើលទេថា មនុស្សភាគច្រើនជឿថា អំពើរំលោភតែងកើតមានជាធម្មតា ឬក៏កើតឡើងនៅពេលមុនគេសំលាប់ស្ត្រីរងគ្រោះទាំងនោះ។ អ្នកឆ្លើយចំនួន៤២ភាគរយក្នុងការស្ទង់មតិនៃការស្រាវជ្រាវនេះនិយាយថាបានស្គាល់ស្ត្រី ដែលគេយកទៅរំលោភមុនពេលសំលាប់។ ការសំលាប់ជនរងគ្រោះគឺដើម្បីបំបិទមាត់ ហើយបន្ថយភាពប្រថុយប្រថាន ដែលថ្នាក់ដឹកនាំអាចរកឃើញពីការរំលោភគោល នយោបាយផ្លូវការនេះ។

## គ. រំលោភមុនពេលសំលាប់

យោធា និង កងឈ្លបមានភារកិច្ចខាងសំលាប់ ‘ខ្មាំង’ នៅទីកន្លែងដាច់ដោយឡែកពីគ្នានោះ មានឱកាសចាប់រំលោភស្ត្រី មុនពេលសំលាប់ ដែលមិនសូវមានគេដឹងឮពីការប្រព្រឹត្តនេះប៉ុន្មានទេ។
ខាងក្រោមនេះជារឿងមួយចំនួនដែលសម្ភាសិតបាន រៀបរាប់។

លោកប៊ុន ថា ជាអ្នកនេសាទត្រីតាមដងទន្លេសាប បានរៀបរាប់ថាបានឃើញការចាប់រំលោភ និង សំលាប់ស្ត្រីម្នាក់។ ក្រៅពីការងារនេសាទត្រី គាត់ប្រើទូករបស់គាត់ដើម្បីចម្លងមនុស្សទៅទីប្រហារជីវិតមួយ។ ‘ខ្ញុំត្រូវបានបញ្ជាឱ្យដឹកមនុស្សទៅដាំដំឡូង តែតាមពិត គេយកកុមារ និង មនុស្សចាស់ទាំងនេះទៅសំលាប់ចោលសោះ’។ លោក ប៊ុន ថា និយាយថា ‘ក្នុងឆ្នាំ ១៩៧៦ ពួកខ្មែរក្រហមចាប់ផ្តើមស្រាវជ្រាវរក និង សំលាប់ភ្នាក់ងារខ្មាំង ហើយបន្ទាប់មកស្ត្រីមកពីកងចល័ត។ គាត់បានរំលឹកពីឧប្បទ្ទវហេតុមួយនៅពេលគាត់ដឹកចម្លងស្ត្រីម្នាក់ដែលគាត់ស្គាល់ទៅទីប្រហារជីវិត។ ស្ត្រីនោះឈ្មោះ វិច្ឆ័រ៉ា ដែលចោទពីបទធ្វើជាភ្នាក់ងារខ្មាំងត្រូវបានរំលោភ មុនពេលសំលាប់។ យោធាបានស្នើរឱ្យខ្ញុំដឹកចម្លងនាងទៅឱ្យពួកវា ហើយខ្ញុំស្ថិតនៅចំងាយប្រហែល១០ម៉ែត្រពីកន្លែងរំលោភ និង សំលាប់នាងដោយយោធា

សក្តិទាប ចំនួន ៥នាក់។ ពួកគេរំលោភតែនារីស្អាតៗដែលបានបញ្ជូនមកកាន់ទីនោះ។ កន្លែង ដែលរំលោភនារីទាំងនោះគឺស្ថិតនៅឆ្ងាយពីភូមិ។ ថ្នាក់លើមិនបានដឹងថា យោធា ថ្នាក់ក្រោមរំលោភស្ត្រីឡើយ។ បើថ្នាក់លើដឹងថាយោធាថ្នាក់ក្រោមរំលោភស្ត្រី យោធាទាំងនោះ មុខតែត្រូវសំលាប់ដែរ។'

*លោកវណ្ណៈ ជាអតីតៈអ្នកយាម*

'អតីតអ្នកយាមសន្តិសុខខ្មែរក្រហមម្នាក់បានរាយការណ៍ថា បានចូលរួមឃើញការវាយប្រហារ និងរំលោភផ្លូវភេទ នារី ១៧មេសា ម្នាក់ក្នុងវាលស្រែ។ គាត់និយាយថា នារីនោះត្រូវគេរំលោភដោយក្រុមកម្មាភិបាល៨នាក់ ពេលនោះរូបគាត់ និង អ្នកយាម២នាក់ទៀតឈរមើល។ កម្មាភិបាលរំលោភនារីនោះ ហើយក៏រុញដងពូថៅចូលក្នុងផ្លូវភេទ បន្ទាប់មកចាក់ប្រេងដុតនាងទាំងរស់។ គាត់និយាយថា បើយើងចាត់ទុកនាងជាប្រពន្ធយើង បងយើង ម្តាយយើង យើងមុខជាអាណិតនាងជាមិនខាន។ ខ្ញុំពិតជាអាណិតនាងជាខ្លាំងព្រោះនាងជាស្ត្រីភេទ...។ ពួកគេប្រាប់ថាឱ្យរក្សារឿងជាសម្ងាត់។ បើខ្ញុំធ្វើឱ្យបែក ការពួកវាមុខ ជានឹងសំលាប់ខ្ញុំ'។

*លោក តេង ជាអតីតៈអ្នកយាម*

តេង ក៏ជាអតីតសន្តិសុខម្នាក់ក៏បានរៀបរាប់ឧប្បទ្ទវហេតុស្រដៀងនេះដែរ។ គាត់មានភារកិច្ចយាមកាមការសួរចម្លើយ ការរំលោភ និង ការសម្លាប់ស្ត្រីម្នាក់ ដែលត្រូវចោទប្រកាន់ថាបានរៀបការជាមួយទាហានលុនណុល។ គាត់មើលឃើញ នៅពេលពួកវាបោះកុមារអាយុ៣ឆ្នាំចូលក្នុងរណ្តៅ ហើយធ្វើទារុណកម្មលើម្តាយ ដើម្បី អោយឆ្លើយសារភាព។

'ខ្ញុំបានឃើញផ្ទាល់ភ្នែករៀបនឹងសំលាប់ហើយវាយកដែក អានោះដែកនឹង តែម្តងខ្ញុំឃើញ បាទ! ដែករុក តាមផ្លូវភេទ។ ខ្ញុំនៅជិតប្រហែល៣ម៉ែត្រ។ ខ្ញុំឃើញ

នៅពេល ដែលខ្ញុំត្រូវបានគេជ្រើសរើសអោយចូលកំលាំងយាមកាម។ មានទាហាន ប្រហែលជាប្អូនដប់... ហៅថាត្រឹម១០នាក់។ អាពួកធំៗគេសួរថា នាងឯងពី ជំនាន់៧៤.. ៧៧ ជាប្រពន្ធសក្តិពីរសក្តិបីអញ្ចឹងណា៎។ ខ្ញុំឃើញនៅឆ្នាំ១៩៧៧។ មានផ្សេងអ្នកទៀតពួកធ្វើបាបដែរ គេវះពោះ... គេវះពោះយកប្រមាត់។ មាន ទាហាន ១០នាក់ រួមទាំងអ្នកយាមកាម។ បន្ទាប់មកទៀតក៏មានតែប៉ុណ្ណឹង គ្រាន់តែ សំលាប់ អូ! សួរដែរថា មានកូនតូចមួយ បាទ!កូនហ្នឹងប្រហែលជាអាយុ៣ឆ្នាំចុះ ហើយក៏កូនហ្នឹងក៏ល្ងីល្ងើ បោះចូលក្នុងរណ្តៅ ចឹងទៅ វាសួរថា ឥឡូវស្តាយកូន ហឹស្តាយខ្លួនឯង សួរម្តាយណឹង ហឹ!កូននោះនៅក្នុង រណ្តៅ អង្គុយក្នុងរណ្តៅ រួចអោយឆ្លើយសារភាពម៉ោ បើសារភាព អាណឹងរស់ ហើយកូនកុំគិត កូនស្លាប់ៗចុះ រួចក៏គាត់និយាយថា គាត់សារភាព ប៉ុន្តែសារភាពនោះ ក្នុងន័យថាវង្វេង ធឹផ្លូវភេទណឹងវារួចម្តងទៅហើយ ក៏ត្រឡប់និយាយអត់ដឹងខុសត្រូវ។ អត់ចាប់ រំលោភទេ គឺយកដែកបោះ។ កូនក្មេង នោះងាប់។ នាងនោះមាន សំលៀកបំពាក់។ គេថា គេឈឺចាប់គេ នារីនោះដៀលគេថា “អាក្តអ្នកតា” ព្រោះគេ ខាងណឹងគេ នៅខាង តំបន់ខាងណោះ យើងនៅខាងណេះ ដូចថា ប្រឈមមុខដាក់គ្នាអញ្ចឹងគេ ឈឺចាប់ គេនិយាយថា ហង ជេរអាញ់ ”អាក្តងាប់ ”។ គេសើយសំពត់តែគេ ដោះអាវរវែងនៅតែអាវទ្រនាប់’។

សម្ភាសិតមួយចំនួនមិនច្បាស់ថា តើស្ត្រីដែលគេរំលោភនៅទីប្រហារជីវិត នឹងត្រូវកំណត់ឱ្យស្លាប់ ឬថាតើគេជ្រើសរើសយកស្ត្រីមួយចំនួនយកទៅរំលោភ ហើយសំលាប់ចោលដើម្បីបំបិទមាត់។

*នាងសុវណ្ណថារី*

នាងសុវណ្ណថារី បានឃើញគេចាប់រំលោភស្ត្រីម្នាក់ក្នុងឆ្នាំ១៩៧៨ នៅពេលនាងធ្វើការជាមួយកងចល័តនារី។ នាងបានឃើញយោធារំលោភ និង សំលាប់ស្ត្រីម្នាក់ តែនាងមិនដឹងថាតើហេតុអ្វីបានជាគេជ្រើសរើសយកស្ត្រី នោះយកមកធ្វើអញ្ចឹង។

'ពេលនោះគេអោយក្រុមខ្ញុំទៅស្ទូងស្រូវ គេចាប់អ្នកស្រីនោះមាឌធំ គ្នានៅសំរាកពេទ្យ (ពេទ្យឃុំ) គេចាប់យកពី ពេទ្យម៉ោ យកម៉ោ មានព្រៃមួយធំ ហើយទៅគេអោយពួកខ្ញុំទៅស្ទូងក្នុងទឹកត្រឹមនេះ ស្រាប់តែ ពួសួរសំលេងស្រែកក្នុងព្រៃនោះឯង។ ពួសួរសំលេងស្រែក ៥នាក់ជាមួយខ្ញុំនេះអើតមើលទៅឃើញវាធ្វើបាបស្ត្រី។ អាមួយចាប់ដៃអាមួយចាប់ជើង ហើយសំរាតពីខ្លួនអស់រលីង ហើយវារំលោភរួចវា..អើ..វះយកប្រមាត់ វះយកប្រមាត់រួចចឹងទៅវាបញ្ចូលស្ត្រីហ្នឹងទៅ ក្នុងឡគេធ្វើឡដុតធ្យូង ចូលទៅវាយកទៅដុត ហើយខ្ញុំឃើញ ចឹងទៅ ខ្ញុំភ័យ ខ្ញុំហែលតាមទឹក មិនអោយរលកទឹក ហើយខ្លាចវាឃើញវាយកទៅសំលាប់ ដល់ពេលខ្ញុំត្រឡប់មកវិញ ពួកខ្ញុំត្រឡប់មកវិញ ភ័យអត់ហ៊ាននិយាយទេ ភ័យ ហើយយប់ឡើងឈ្លបនោះវាមកកន្ទ្លែង រោងខ្ញុំច្រើនណាស់ វាមកកន្ទ្លែងរោងខ្ញុំ ហើយខ្ញុំអត់ហ៊ាននិយាយអី ទាំងអស់'។

*នាងរច្ចនី*

'យប់មួយមេកងហៅបងថ្លៃរបស់នាងឈ្មោះសុភាអាយុ១៨ឆ្នាំ និងមិត្ររបស់សុភា។ នាងរច្ចនីមានការសង្ស័យក៏ដើរ តាមអ្នកទាំង២ និង មេកង។ មេកងនាំអ្នកទាំង២ទៅវត្តក្បែរនោះ ហើយប្រគល់អ្នកទាំងនោះទៅយោធា៤នាក់ធ្វើការកសាង។ បន្ទាប់មក មេកងក៏ចេញទៅបាត់។ រច្ចនីក៏លាក់ខ្លួនក្រោយដើមឈើមួយ

ដែលអាចមើលឃើញសុភាច្បាស់ ហើយឃើញយោធា នោះយកក្រមាចងមាត់សុភា ហើយសម្រាតខោអាវចេញ។ យោធាម្នាក់ចាប់សុភា ហើយម្នាក់ទៀតរំលោភ។ រច្ចនី ក៏រត់ចេញ ដោយខ្លាចគេចាប់រំលោភនាងទៀត តែនាងត្រឡប់មកវិញនៅវេលាព្រឹកឡើង ដោយធ្វើជាឃ្វាលគោ ដើម្បីរកមើលបងថ្លៃ នាង។ នាងបានឃើញសាកសពអាក្រាតរបស់សុភាដេកក្បែរវត្តនោះ។

*នាងណារី*

ណារីជាប្រធានកងចល័តនារីដែលមានគ្នា៣០នាក់។ ណារី និង កងចល័តទទួលបញ្ជាឱ្យទៅការិយាល័យឃុំដើម្បីផ្លាស់ប្តូរ និងកសាង។ នៅពេលពួកនាងមកដល់សាលាឃុំ ឃើញមានយោធាខ្មែរក្រហមកាន់អាវុធគ្រប់ដៃចំនួន៣នាក់ ហើយបញ្ជាឱ្យពួកនាងឈរតំរង់ជួរ។ ណារីមើលយោធាចាប់ផ្តើមជ្រើសរើសស្ត្រីពីរជួរដោះខោអាវចេញ ហើយរំលោភតែម្តង។ ណារី និយាយថានាងលបគេចចេញមិនឱ្យគេដឹង ហើយរួចខ្លួនដោយបានប្រធានឃុំជួយ ហើយដោយបន្លំខ្លួននាងនិងឱ្យនាងរៀបការ នៅភូមិក្បែរនោះ។ នាងទទួលដំណឹងពីអ្នកជិតខាងមកថា យោធាបានសំលាប់នារីកងចល័តទាំងអស់ ហើយបានកប់សាកសព ទាំងនោះហើយ។

## ខ. ការបំពានអំណាច-មន្រ្តី យោធា និង កងឈ្លប

អ្នកដែលត្រូវគេរំលោភទាំងអស់ មិនសុទ្ធតែត្រូវគេសំលាប់ចោលទេ។ ប្រការដែលថាអង្គការនឹងដាក់ទណ្ឌកម្ម ឬសំលាប់ជនរងគ្រោះ បើសិនជននោះធ្វើឱ្យបែកការណ៍ មានន័យថាជនល្មើសទុកចិត្តថាជនរងគ្រោះមិននិយាយពីអំពើល្មើសរបស់ពួកវាឡើយ។ អ្នកដែលមានអំណាចថ្នាក់មូលដ្ឋានអាចទុកចិត្តជាពិសេសថាគ្មាននរណាម្នាក់រាយការណ៍អំពីពួកគេទេ ទោះជាពួកគេមិនភ័យខ្លាចពីទណ្ឌកម្មដែលត្រូវទទួលក៏ដោយ ក៏ជនរងគ្រោះមិនដឹងរាយការណ៍ទៅនរណាដែរ។ រឿងនេះ

អាចពន្យល់ពីការចាប់រំលោភជាច្រើន ដែលសម្ភាសិតនិយាយថា ប្រព្រឹត្តដោយមន្ត្រីថ្នាក់ភូមិ និងឃុំ។

នៅពេលដែលសម្ភាសិតមួយចំនួនជឿថា អ្នកចាប់រំលោភ និងថ្នាក់លើរបស់វាបានសហការគ្នានោះ សម្ភាសិតបានដឹងជាទូទៅថា អំណាចគ្រប់គ្រងទាំងស្រុងស្ថិតនៅក៏រិតមូលដ្ឋាន ហើយមិនដឹងអ្នកថ្នាក់លើដឹងពីបញ្ហាការរំលោភនេះឬអត់ទេ។ ឧទាហរណ៍ គេចាត់ទុកជនរំលោភដែលជាមេឃុំថាជាអ្នកមានអំណាចខ្ពស់បំផុត ហើយដូច្នេះមិនមាននរណាផ្សេងត្រួតពិនិត្យ ពីសកម្មភាពរបស់គេទេ។

សម្ភាសិតក៏បានរាយការណ៍ផងដែរថា កងឈ្លបក៏ប្រព្រឹត្តបទល្មើសរំលោភជាច្រើនដែរ។ កងឈ្លបមុខជាជឿជាក់ថា ជនរងគ្រោះនៅស្ងៀមមិននិយាយ ឬអាចមានការគាំទ្រពីតាមរូបភាពណាមួយ ចំពោះអំពើរបស់ខ្លួនពីសំណាក់អាជ្ញាធរមូលដ្ឋាន។ បទល្មើសច្រំដែលធ្វើដោយកងឈ្លបដដែល១យ៉ាងហោចណាស់បង្ហាញពីការឯកភាពពីអាជ្ញាធរមូលដ្ឋានដែរ។

*នាងចិន្តា*

អាកងរយបានរំលោភនាងចិន្តានៅផ្ទះរបស់នាង និងនៅមុខកូនរបស់នាង។

‘ខ្ញុំ ដើមដំបូងបង្អស់គេយកប្តីខ្ញុំទៅវាយចោលឃើញទេ ហើយក៏ខ្ញុំណឹងនៅផ្ទះនៅផ្ទះ សុំច្បាប់គេពីរថ្ងៃ កូនឈឺដល់ពេល ហើយ...ស្អែកឡើងគេមកទាន់ គេថាល្ងមទៅធ្វើការធ្វើអីហើយ នៅផ្ទះចង់តែយកទៅវាយចោលទេ យកទៅវាយចោលដូចប្តីទៀត។ ខ្ញុំថា "កូនខ្ញុំឈឺមិត្តអើយ ខ្ញុំសុំមួយថ្ងៃទៀតចុះ"។ ពេលអញ្ចឹងហើយក៏គេអត់ថា អី ដល់ពេលល្ងាចម៉ោ ពេលល្ងាចម៉ោ២នាក់ បុរស១ណាំ ម្នាក់នោះកងហាម្នាក់កងរយ។ មិនបាច់ និយាយឈ្មោះទេ។ កងហាឡើងម៉ោមុន ម៉េចបងនារីគ្រាន់ធូរទេកូន ចៅ! ខ្ញុំថា គ្រាន់បន្តិចហើយ អញ្ចឹងគេ អោយទៅធ្វើការណា។ ខ្ញុំថាចាំ

ដល់ពេលនោះ អាកងរយវាថា អាឌីម ឯងចុះម៉ោ បានហើយ..ឯងទៅមុន ទៅទុកអោយអាញ់ ឡើងសួរគាត់ម្តង ដល់ពេល អាមួយ កងហាឈ្មោះឌីមក៏ចុះទៅ អាកងរយឡើង មកវិញ ម៉េចហើយមិត្តនារី គេថាអញ្ចឹងណាំ បានសំរាកនៅផ្ទះប៉ុន្មានថ្ងៃគ្រាន់ ធូរទេ មានបាយហូបគ្រប់គ្រាន់ទេ។ ខ្ញុំថា គ្រប់គ្រាន់ហើយអត់អីទេ គេថាមានគេអោយ បាយហូបទេ។ ខ្ញុំថាអោយ ប៉ុន្តែខ្ញុំកុហក អត់មានអោយទេ ដល់ពេលគេនិយាយ អញ្ចេះមួយអញ្ចុះពីរ គេថា យីស! នៅមានសាច់ល្អទៀតទំ។ ខ្ញុំក៏អត់មាត់ដែរ។ និយាយ ចុះនិយាយឡើង គេថា បើព្រមស្រលាញ់គេ គេអោយរួចខ្លួន គេអត់យកទៅ សំលាប់ទេ គេថាអញ្ចឹង។ ខ្ញុំថា "ខ្ញុំអត់ស្រលាញ់ទេៗ"។ ប្តីខ្ញុំទើបតែ យកទៅណាបាត់មិនទាន់ដឹងដំណើងផង ខ្ញុំសុខចិត្តស្លាប់។ ខ្ញុំមិន ស្រលាញ់សោះហើយ សង្គមណឹងដឹងស្រាប់ហើយ ខុសសីលធមិងាប់អត់មានសល់មួយទេ ខ្ញុំថាអញ្ចឹងណាំ។ ខ្ញុំនិយាយនេះនិយាយទាំងចងកំហឹងអត់មានមើលមុខទេ ហើយវាក៏តាំង...កូនខ្ញុំនៅ ប៉ុណ្ណឹងនែ៎ តូចជាងណឹងបន្តិចវាក្រោកៗ គេចាប់កូនខ្ញុំលេង ហើយវានិយាយថា ប៉ាអ្ហែងជិតមកវិញហើយ ប៉ាឯងទៅលីងពោត តិចម៉ោវិញ ហើយនៅជាមួយម៉ែអូនអែងទៅ។ និយាយអញ្ចឹង ខ្ញុំក៏អត់តអត់តាំង អីដែរ។ កូនខ្ញុំឈ្មោះប៊ូឡូ វាអាយុ ៤ឆ្នាំហើយ។ គេថាអ្ហែងចុះដីអូន ចុះដីទៅចាំពូ អោយដំឡូងហូប ល្ងាចពូធ្វើដំឡូងអោយអូនហូប កូនខ្ញុំក៏ចុះដី ពេលនេះ វាឡើងទៅ លើផ្ទះចាប់ខ្ញុំរំលោភ ទោះបីខ្ញុំរើយ៉ាងណាក៏ដោយ វាយកក្រមាពីកវាញុកមាត់ខ្ញុំយក ក្រមាចងកនិងមាត់ យើងទៀត ពេលរំលោភខ្ញុំរើក្តុងក្តាំងៗកូនខ្ញុំវាឡើងមក ពូកុំធ្វើអីម៉ាក់ខ្ញុំ ពូកុំធ្វើអីម៉ាក់ខ្ញុំ លែងម៉ាក់ខ្ញុំទៅ ដល់វាមិនព្រម លែងប្រទះប្រទែងៗ វាបានតប់កូនខ្ញុំធ្លាក់ទៅដីទៅ ចោះផ្ទះយើងទាបហើយតូច ផ្ទះប៉ុលពត ធ្វើអោយយើងនៅ។ ហើយវាឡើងមកទៀតកូនខ្ញុំណឹង ក៏វាវាយទៀត ទាញស្វាយកាំភ្លើងវាយដល់សន្លប់ ខ្ញុំយំខ្ញុំថា បើមិត្តឯងធ្វើបាបកូនខ្ញុំ របៀបនេះ សំលាប់ខ្ញុំទៅ ខ្ញុំថាអញ្ចឹង ខ្ញុំអត់ចង់រស់

នៅទេ មិត្តឯងអីក៏ចិត្តខ្មៅម្លេះខ្ញុំថាអញ្ចឹង រំដោះពួកខ្ញុំម៉ោថារំដោះអោយរស់ពេលឥឡូវធ្វើបាបអញ្ចឹង យកប្តីខ្ញុំទៅវាយចោលអស់ហើយ ម៉ោធ្វើបាបខ្ញុំនិងកូនខ្ញុំទៀត ខ្ញុំនិយាយអញ្ចឹងខ្ញុំយំ។ វាថាអត់អីទេ ថាអញ្ចឹងវាយកកូនខ្ញុំ ទៅបាត់ទៅមិនដឹងយកទៅណា បាត់រហូតដល់សព្វថ្ងៃហ្នឹង' ។

សម្ភាសិតមួយចំនួនទៀតបានប្រាប់ពីការឃើញអាជ្ញាធរមូលដ្ឋានរំលោភស្ត្រីតាមផ្ទះ។ ឧទាហរណ៍ បុប្ផា ជាយោធាស្រីនិយាយថា គណៈឃុំស្នើរឱ្យនាងយាមផ្ទះដែលមានក្មេងស្រីម្នាក់រស់នៅ នៅពេលវាដើរចូលទៅក្នុងផ្ទះនោះ។ វាជាពេលយប់ងងឹត ដែលមានតែគណៈឃុំ និងក្មេងស្រីនោះក្នុងផ្ទះ។ បុប្ផាឮសំលេងក្មេងស្រីនោះស្រែកថា 'កុំរំលោភខ្ញុំអី' តែនាងនោះនៅស្ងៀម ព្រោះខ្លាចប្រធាននាងសំលាប់ចោល។ បុប្ផាបានយាមកាមផ្ទះនោះ២យប់ជាប់គ្នា ដោយគណៈឃុំរំលោភក្មេងស្រីនោះរហូត។ នៅថ្ងៃទី៤ក្មេងស្រីនោះក៏បាត់ទៅ ហើយបុប្ផាក៏លែងឃើញក្មេងនោះទៀត។

*នាងតារា*

តារាមានអាយុ១២ឆ្នាំ នៅពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។ ឪពុកនាងធ្លាប់ជាមន្ត្រីតូចតាចក្នុងរបប លុន ណុល ដែលនៅមុនរបបខ្មែរក្រហម។ ខ្មែរក្រហមសំលាប់គាត់ នៅសល់តែនាង ម្តាយនាង និង ប្អូនប្រុសស្រីនាងមិនមានអ្នកថែទាំ។ រយៈពេលមិនយូរប៉ុន្មានក្រោយពីឪពុកនាងស្លាប់ ឈ្លប៤នាក់ចូលរំលោភម្តាយនាងក្នុងផ្ទះ នៅពេលក្រុមគ្រួសារនាង កំពុងគេងលក់។ នាងតារាព្យាយាមជួយម្តាយតែឈ្លបដែលកាន់កាំបិតគំរាមកំហែងនាង។ នាងគ្រាន់តែអាចនៅចាំរហូតទាល់តែឈ្លបទាំងអស់រំលោភម្តាយនាងហើយ។ ពីរបីយប់ក្រោយមក នៅពេលម្តាយនាងកំពុងធ្វើការឯវាលស្រែ ឈ្លបនោះមក រំលោភនាងតារា។

‘ខ្ញុំព្យាយាមការពារខ្លួនខ្ញុំដោយធ្មេញតជើង តែពួកវាព្យាយាមហែកជើងខ្ញុំវិញ។ ដូច្នេះ ខ្ញុំមិនហ៊ានរើបំរះ ព្រោះខ្លាចពួកវា បំបាក់ជើងខ្ញុំ។ ខ្ញុំទុកឱ្យពួកវាធ្វើស្រេចតែចិត្តទៅ។ មានតែគ្នាវាម្នាក់ទេដែលអាចរំលោភខ្ញុំបានសំរេច។ អ្នកទីមួយមិនអាច ព្រោះប្រដាប់ភេទវាធំពេក។ អាទីមួយនោះនិយាយថា “ថ្ងៃនេះ អញមិនបានសំរេចសោះ តែពេលក្រោយអញនឹង ធ្វើឱ្យប្រដាប់ភេទវាធំជាងនេះ”។ បន្ទាប់មកវាទុកឱ្យអាម្នាក់ទៀតរំលោភខ្ញុំ។ ក្រោយពីរំលោភហើយ ពួកវានិយាយថា “បើឯងហ៊ានប្រាប់គេពីរឿងនេះ គ្រួសារឯងនឹងស្លាប់ទាំងអស់ ព្រោះអង្គការចាត់ទុកគ្រួសារឯងទាំងអស់ជាសត្រូវ រួចទៅហើយ” ’។

ម្តាយតារានៅតែភ័យខ្លាចពួកខ្មែរក្រហម ហើយព្យាយាមឱ្យនាងតារាគេចចេញពីការសម្ភាសន៍។ នាងតារានិយាយថា ‘ខ្ញុំ មានបំណងផ្តល់បទសម្ភាស ព្រោះខ្ញុំចង់ប្រាប់រឿងនេះ...ខ្ញុំមិនខ្លាចទេ’។

*លោកកុសល*

កុសលជាយោធាក្នុងរបបខ្មែរក្រហម បាននិយាយថា ‘វាជារឿងទូទៅសំរាប់ពួកកម្មាភិបាលខ្មែរក្រហមដែលហៅនារីទៅប្រជុំ ហើយរំលោភតែម្តង។ ឃើញគ្រប់កន្លែង ឃើញនៅគ្រប់កន្លែងកង ប៉ុន្តែដល់ឃើញទៅអត់ហ៊ាន ព្រោះយើងឋានៈតូចជាងគេ ឃើញគឺយើងដើរគេចចេញ។ កាលណាគេហៅទៅ គេហៅទៅប្រជុំ ឧទាហរណ៍ថា គេត្រូវការនារីដូចជា ស្ម្មាលាទោសដូចជានាងអញ្ចេះណា ទៅគេហៅទៅដូចថា គេត្រូវហើយហៅនាងឯងទៅប្រជុំ ប៉ុន្តែទៅប្រជុំ ណឹង មិនមែនហៅទៅប្រជុំទេ គឺហៅទៅនិយាយតែពីរបីមាត់ គេចាប់រំលោភហើយ។ គេហៅតែមួយៗទេ។ ទាហានតែមួយហៅនារីតែមួយ។ ខ្ញុំឃើញលួច មើលទៅ លួចមើលប្រធានកងខ្ញុំហៅថា ប្រធានវរៈខ្ញុំលួចមើល ដើរធ្វើការផង នៅកន្លែងអង្គភាព នៅកន្លែងអង្គភាព

ខ្ញុំដើរល្បាតមើល អង្គការគេទុកចិត្តឈ្មោះណា ហើយគេអោយដើរមើលទៅ ហៅថា ៤ឬ៥នាក់ទៅ ៤ឬ៥នាក់នោះក៏ ដើរមើលទៅឃើញអត់មាននរណាហ៊ាននិយាយទេ កាលណានិយាយគេបាញ់យើងចោល បើមិនបាញ់យើងចោលទេ គេដាក់គុកយើង ខ្លាចយើងដឹងរឿងគេ។ ឧទាហរណ៍ថាក្នុងមួយថ្ងៃហ្នឹងគេហៅអញ្ចេះម៉ោ ហើយពីរ បីបួនថ្ងៃទៀត គេទំនាក់ទំនងទៅគេហៅផ្សេងទៀតម៉ោ។ បើហ៊ាននិយាយគឺបាញ់ ចោល បើអត់និយាយនៅស្ងៀមក៏គេហីទៅ។

បើសិនជាស្ត្រីរងគ្រោះមានផ្ទៃពោះដោយសារការរំលោភ នោះអាចមានគ្រោះ ថ្នាក់ ព្រោះអង្គការច្បាស់ជាដឹងហើយនឹងសំលាប់ជនរងគ្រោះ និងជនល្មើស។ បើសិន ជនល្មើសដឹងមុនថាជនរងគ្រោះមានផ្ទៃពោះ ជនរងគ្រោះក៏អាចគ្រោះថ្នាក់ដែរ ព្រោះ ជនល្មើសអាចសំលាប់ដើម្បីបិទបាំងកំហុស។

*នាងសុជាតិ*

សុជាតិមានបំណងជួយស្ត្រីម្នាក់ដែលមានផ្ទៃពោះដោយសារប្រធានក្រុមចាប់រំ លោភ។ ស្ត្រីនោះដឹងថា អង្គការនឹងសំលាប់ បើសិនមានគេដឹងថាគាត់មានផ្ទៃពោះ ហើយគាត់បានសុំឱ្យសុជាតិជួយ ពីព្រោះសុជាតិមានបទពិសោធន៍ជាឆ្មប។ សុជាតិ ពន្យល់នូវរឿងរ៉ាវដែលកើតឡើង។

‘ប្រធានក្រុមបានចាប់រំលោភក្មេងស្រីស្អាតម្នាក់ ហើយនាងនោះមកផ្ទះខ្ញុំ យំនៅមុខខ្ញុំ ហើយខ្ញុំសួរនាងហេតុអ្វីបានជាឯង យំ ឯងឈឺមែនទេ? នាងឆ្លើយថាទេ ខ្ញុំមិនឈឺទេ តែខ្ញុំត្រូវប្រធានក្រុមរំលោភ។ ខ្ញុំពិនិត្យនាង ហើយដឹងថានាងមានផ្ទៃ ពោះ ដូច្នេះខ្ញុំឱ្យនាងផឹកថ្នាំខ្មែរ។ មានតែម្រេច និង ឈើភ្លឹងដើម្បីរលូតកូនវិញ តែមិន បានសំរេចសោះ’។

សុជាតិនៅតែមានអារម្មណ៍ថា ខ្លួនមានកំហុសអំពីការបរាជ័យនៃវិធីប្រើថ្នាំរបស់នាង ដោយក្រោយមកបន្តិច ស្ត្រីនោះ បាត់ខ្លួនទៅ ជឿថាប្រធានកងបានដឹងថានាងមានផ្ទៃពោះ។

*នាងទូច*

នៅពេលនាងទូចមានអាយុ១៦ឆ្នាំ នាងជាសមាជិកកងចល័តនារីខេត្តបាត់ដំបង។ គណៈកង និង ឈ្លបបានហៅនាង និងក្មេងស្រី៤នាក់ទៀតដែលទាំងអស់គ្នាមានអាយុពី១៦ ដល់១៨ឆ្នាំឱ្យទៅប្រជុំ។ មានឈ្លប៥នាក់នៅក្នុងផ្ទះ ហើយពួកវាហៅ នារី២នាក់ចូលក្នុងដោយប្រាប់នាងទូច និង នារីដទៃទៀត រងចាំខាងក្រៅ។ នាងទូចបានលបមើលឃើញឈ្លបរំលោភនារីទាំង ២នាក់នោះ។

'ខ្ញុំភ័យណាស់ ដូច្នេះខ្ញុំចង់ត្រឡប់ទៅផ្ទះវិញ។ នារី២នាក់ទៀតសួរខ្ញុំថាហេតុអ្វីបានជាចង់ទៅផ្ទះវិញ ក្រែងគេហៅ ឱ្យមកប្រជុំឬ? ខ្ញុំនិយាយថា ប្រជុំស្អី? ពួកវាកំពុងដេកជាមួយ នារី២នាក់នោះ។ បើឯងមិនជឿទៅមើលទៅ។ នៅពេលនារីទាំង៣នាក់ត្រឡប់មកវិញ គេបាននិយាយថាឈ្លបទាំងនោះប្រើកាំភ្លើងសំលុត ហើយរំលោភតែម្តង។ នារីម្នាក់ក្នុងចំណោម៣នាក់មានផ្ទៃពោះ ហើយក៏បាត់ខ្លួនទៅ។ នាងទូចជឿថា ជនល្មើស ឬអង្គការដឹងថាមានផ្ទៃពោះ' ។

សម្ភាសិតជាច្រើនជឿថា ការមានផ្ទៃពោះដោយសារការរំលោភ មានន័យថាជាការស្លាប់ដោយស្វ័យប្រវត្តិ ដោយដៃរបស់អង្គការ ឬដៃជនល្មើស។ នាងទូចបាននិយាយថា 'ពួកវាមិនទុកនារីរងគ្រោះឱ្យសម្រាលកូនទេ គ្មានជនរងគ្រោះដោយសារការរំលោភបានសម្រាលកូនឡើយ' ។ តែការរកឃើញថាមានការរំលោភ និងមានផ្ទៃពោះមិនសុទ្ធតែស្លាប់ទេ។ មន្ត្រីថ្នាក់ក្រោមខ្លះអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន

ហើយចេះអត់អោន។ នាងរក្សាជាស្ត្រីមេម៉ាយមានកូនតូច២នាក់ នៅពេលមេភូមិនាងរំលោភនាងនៅផ្ទះចំនួនបីបួនពេល។ នាងមិនតបតទេដោយខ្លាចថាវាសំលាប់នាង។ នៅពេលនាងប្រាប់អ្នកដទៃ អង្គការចោទនាងថាខុសសីលធម៌ ហើយដាក់គុក៣ខែ។ គេដាក់ច្រវ៉ាក់នាងពេលយប់ ហើយបង្ខំឱ្យធ្វើការពេលថ្ងៃ។ ក្នុងគុកនាងដឹងថាមានផ្ទៃពោះដោយសារការរំលោភ។ គេដោះលែងនាងវិញនៅថ្ងៃផុតទោស ហើយសម្រាលបានកូនស្រីមួយ។ អង្គការក៏បានចាប់មេភូមិដាក់គុកដែរ។

សម្ភាសិតក៏បានរាយការណ៍ថាមេភូមិបានផ្តល់អង្ករ ឬខោអាវដល់នារីដើម្បីប្តូរនឹងការរួមភេទ។ នាងទួនពន្យល់ថា 'នារីខ្លះត្រូវការអាហារសំរាប់រស់ក៏យល់ព្រមរួមភេទជាមួយពួកវា'។ ពួកវាឱ្យខោអាវស្អាត១ តែក្រោយមកបន្តិច ពួកវាសំលាប់នារីទាំងនោះចោលអស់។ បើគេមិនរួមភេទជាមួយប៉ុល ពត គេច្បាស់ជាគ្មានស្អីហូប និង គ្មានខោអាវឡើយ។ ប្រហែលមួយខែក្រោយមក ពេលពួកវាធុញទ្រាន់នឹងនារីទាំងនោះ ពួកវាក៏សំលាប់ចោលតែម្តង'។

ចាន់ណារីពណ៌នារបៀបដែលមេក្រុមចង់រំលោភនាង។ នាងព្យាយាមគេចដោយលាក់ខ្លួនអស់រយៈពេលជាច្រើនថ្ងៃ។ នាងនិយាយថា:

'គេបានធ្វើបាបនារីមានច្រើនជាងខ្ញុំទៀតចាំ។ ដឹងព្រោះជម្លៀសទៅទាំងអស់គ្នា អ្នកទៅជាមួយខ្ញុំ គេប្រាប់។ ហើយ នោះពីចិរិតស្រីទេ មេស្រីវាអោយផង។ ដូចថាដូចថាស្រីនោះវាអត់ខឹង អត់ខឹងដូចខ្ញុំ អត់ខ្លាចដូចខ្ញុំណាំ។ គេវ័យ ចំណាស់ជាងខ្ញុំគេអត់ខ្លាច។ ខ្ញុំក្មេង ខ្ញុំខ្លាច ខ្ញុំខ្លាចចេះតែរត់ទៅ។ គេដូរយកអង្ករ ហូប ចាំគេអត់ហូបឃ្លានណាស់ៗអត់មានអីហូបទេ គេអោយដេកជាមួយ គេអោយអង្ករទៅហូប ប៉ុន្តែចំណែកខ្ញុំ ខ្ញុំអត់ចង់ហូបទេអង្ករ ខ្ញុំតស៊ូបេះស្លឹកឈើ ហូប ខ្ញុំអត់ត្រូវការទេ យកខ្លួនខ្ញុំទៅដូរយកអង្ករ ខ្ញុំអត់ដូរ ចំពោះស្រីដទៃគេដូរបាន ខ្ញុំដូរអត់បានទេ ព្រោះខ្ញុំស្តាយ

ណាស់ភាពក្រមុំ ភាពបរិសុទ្ធរបស់មនុស្ស របស់ស្ត្រីយើងភាពល្អណាស់ ថាធ្វើអោយទាបថោកយ៉ាប់ ' ។

ដូច្នេះការរំលោភ និង អំពើហិង្សាផ្លូវភេទមិនសុទ្ធតែប្រព្រឹត្តទៅលើអ្នកដែលត្រូវស្លាប់ទាំងនោះទេ។ អ្នកដែលអាចរក្សា ការរំលោភសម្ងាត់ពីថ្នាក់លើដែលអាចអន្តរាគម ជាពិសេសអ្នកមានអំណាចក្នុងមូលដ្ឋាន អាចប្រព្រឹត្តបទល្មើសផ្លូវភេទដោយ គ្មានទោសពៃទេ។ ភាពស្ងៀមស្ងាត់របស់សាក្សី និង ជនរងគ្រោះត្រូវធានាដោយគោលនយោបាយមួយដែលកំណត់មិនឱ្យមានការរំលោភ តែមានន័យថាបើពួកវានិយាយ ពួកវាច្បាស់ជាស្លាប់ផងដែរ។

## គ. ការរំលោភក្នុងគុក និង មណ្ឌលកែប្រែ

នារីងាយរងគ្រោះជាពិសេសក្នុងគុក ដែលពួកគេគ្មានកំលាំងអ្វីនឹងទប់ទល់អាជ្ញាធរគុក។ អ្នកដែលត្រូវចោទប្រកាន់ពី ទោសប្រឆាំងនឹងអង្គការតែងតែត្រូវដាក់គុកក្នុងសាលាកែប្រែខេត្ត ឬមន្ទីរកែប្រែ។ គុកដ៏ល្បីបំផុតរបស់ខ្មែរក្រហមគឺ ស-២១ ស្ថិតក្នុងទីក្រុងភ្នំពេញ។ លោក ដាវីត ចាន់ល័រ និយាយទាក់ទងនឹង ស-២១ ថា 'បុគ្គលិកគុកយកចំលើយសារ ភាពដោយ ជួនកាលយាយី និង ធ្វើបាបអ្នកទោសស្រី។ ជាពិសេសអ្នកទោសស្រីជនជាតិវៀតណាមងាយនឹងរងគ្រោះណាស់' ។ លោក ចាន់ល័រ លើកឡើងនូវឧប្បទ្ទវហេតុពានៃការរំលោភអ្នកទោស ហើយនិយាយថា 'ទោះជាការរំលោភអ្នកទោសមិនសូវបានចងក្រងជាឯកសារក៏ដោយក៏ការធ្វើឱ្យបាត់តម្លៃមនុស្សដល់អ្នកទោស និង លក្ខណៈអ្នកមានសីលធម៌ដែលកំណត់ទៅលើបុគ្គលិកគុកនោះនឹងបង្ហាញពីការធ្វើទុក្ខបុកម្នេញជាញឹកញាប់' ។

សម្ភាសិតដែលជាអតីតអ្នកទោសក្នុងគុកខេត្ត និង មណ្ឌលកែប្រែ រាយការណ៍ថាបានឃើញឆ្មាំ និងបុគ្គលិកគុកនាំយកស្ត្រីចេញទៅរំលោភ។ ជាពិសេស នាងពិសី

យើញឆ្នាំគុកសម្រាតខោអាវនារី១ ហើយនាំយកចេញទៅ។ 'មូលហេតុដែលខ្ញុំគិតថា គេយកស្ត្រីស្អាត១ទៅរំលោភ ពីព្រោះគ្នាវាចាប់ស្រាត ចាប់អីស្រេចទៅហើយ' ។

សម្ភាសិតមួយចំនួនក៏ជាជនរងគ្រោះដោយការរំលោភក្នុងមណ្ឌលទាំងនេះដែរ ឬជាសាក្សីទីមួយនៃរឿងនេះ។ ក្នុងបទសម្ភាសន៍ប្រកបដោយទឹកភ្នែកមួយនាង ស៊ីណា ពន្យល់ពីរបៀបប្រធានមន្ទីរកសាងរំលោភនាង។ គេបានចាប់នាងយកទៅ មន្ទីរកសាងក្រោយពីអង្គការចាប់បុរស ដែលបង្ខំឱ្យរៀបការជាមួយនាងដោយចោទ ថាបានក្បត់ នឹងអង្គការ។ នាងស៊ីណាត្រូវធ្វើការជាទំងន់ជាមួយនារីដទៃទៀត ដែលមានទោសផ្សេង១។ ប្រហែល២សប្តាហ៍ក្នុងគុក នាងទទួលសារថានាងត្រូវទៅ ជួបប្រធាន ដើម្បីទទួលការងារថ្មី។ នាងសង្ស័យថាប្រធានរៀបចំប្រជុំដើម្បីរំលោភ នាងហើយ។

'ខ្ញុំអត់មានធ្វើអីទេ ខ្ញុំស្រែកយំ ខ្ញុំបម្រុងចេញមកវិញ ប៉ុន្តែយើងចេញអត់កើត គេធ្វើបាបយើង គេមានគ្រោងការស្រេចហើយ។ គេហៅយើងទៅជួបមួយភ្លែតណឹង យើងដូចមិនចង់ហ៊ានចូលដែរពេលណឹង ដល់ពេលថា នឹកថា ប្រហែលជាមិនអី ក៏តាំងស្មារតីថាត្រូវចូលទៅជួបអញ្ចឹង ដល់ចូលទៅវាមានផែនការរួច ស្រេចហើយ។ ចូលទៅយើងអង្គុយក៏មិនចង់ ហ៊ានអង្គុយដែរ ព្រោះដូចខ្លាចដែរ កន្លែងណឹងកន្លែង កសាង ហើយម្នាក់ឯងទល់អញ្ចឹងផងភ័យ។ ខ្ញុំយំ ហើយខ្ញុំតទៅដែរ ប៉ុន្តែគេមិនស្តាប់ យើងទេ។ មិនដឹងនិយាយអីខ្លះទេកាលណឹង ខឹងផង យំផង ស្រែកប្រកែកផង។ ដូចថាវាឃោរឃៅពេក។ គាត់យកកាំភ្លើងដាក់លើតុអោយ យើងឃើញ ហើយគេមក ចាប់យើង យើងប្រវាយប្រតាយគ្នា ហើយគេទះ កំភ្លៀងយើងមួយដៃ ហើយយើង ស្រែក រត់ចេញក៏មិនរួច គ្រាន់តែស្រែកឮ១ខ្ញុំ ដើម្បីអោយគេនៅក្បែរខាង និយាយរួម ថា អ្នកនៅណឹង អ្នកទោស អ្នកណាក៏ដោយអោយឮ អោយដឹងថា វាធ្វើម៉េច។

ដៃមនុស្សប្រុសធូនចាប់ម៉ោ អោប យើងរើអត់រួចទេ។ គេចាប់ដោះខោអាវយើង យើងអត់ព្រមទេយ៉ាងណាក៏អត់ព្រមដែរគេចាប់ទាញត្រណាត់ត្រណែង។ មានគ្រែនៅក្នុងបន្ទប់គេណឹង ដូចថាចាប់ច្រានយើង។ ក្រោយមកខ្ញុំឈឺពេញខ្លួន។ គេបានដាក់លិង្គចូលក្នុងប្រដាប់ភេទ របស់ខ្ញុំ ' ។

នាងស៊ីណាឃើញគេហៅនារីម្នាក់ទៀតទៅការិយាល័យប្រធាន នាងនោះត្រូវចោទពីបទព្យាយាមគេចចូលប្រទេសថៃ នាងជឿថាប្រធានមុខជារំលោភអ្នកទោសនោះហើយ។

លោកវ៉ាសនារៀបរាប់ពីការឃើញគេរំលោភនារីម្នាក់ នៅពេលគាត់ជាប់គុកក្នុងមណ្ឌលកែប្រែ។ គាត់កាត់ស្មៅក្នុងបរិវេណ មណ្ឌលនោះ ក៏ឃើញយោធាខ្មែរក្រហមរំលោភស្ត្រីម្នាក់ក្នុងក្រុមគាត់។ គាត់គិតថាជនល្មើសមុខជាសំលាប់នាងនោះក្រោយពេលរំលោភហើយ។ 'ខ្ញុំឃើញគេចាប់រំលោភដោយផ្ទាល់ភ្នែកខ្ញុំ គេយកទៅទាំងយប់ យកទៅខាងក្រោយ។ បុរសរំលោភ អ្នកយកទៅ ឱកាសខ្ញុំឡើងទៅបត់ជើង ឃើញគេដើរនាំទៅ គេចងស្មើរណឹង១ខាងក្រោយ ខ្សែអង្រឹងយើង។ អត់ឃើញមកវិញទេ គេរំលោភហើយគេសំលាប់ចោល អត់មានអ្នកណាជួយបានទេ។ ខ្ញុំឃើញម្តង' ។

លោក ចាន់ ថុល បានឃើញការរំលោភជាច្រើន នៅពេលគាត់ជាប់ច្រវ៉ាក់ក្នុងគុកសន្តិសុខរយៈពេល៦ខែ ៣ថ្ងៃ។ អង្គការ បានរកឃើញខ្សែភ្លើងក្នុងផ្ទះគាត់ ហើយចោទគាត់ថាប្រើខ្សែភ្លើងនោះ ដើម្បីទាក់ទងទាហានលុន ណុលទំលាក់គ្រាប់បែក ក្នុងភូមិ ។ គាត់មានអារម្មណ៏ច្រាស់ច្រានពេលសម្ភាស ព្រោះគាត់នៅខ្លាចខ្មែរក្រហម តែគាត់ ចង់ចែករំលែកអ្វីដែលគាត់បានឃើញ។

‘វាហ៊ានហៅអោយមើលទៀតនាង ថាពួកអាអស់ណឹងសុទ្ធតែអ្នកងាប់ អ្នកជាប់ជើងណឹងណា៎។ នៅពេលដែលគេហៅ អោយមើល ខ្ញុំអង្គុយជាប់ជើង។ គ្រាន់តែហៅថា ប្រាប់ទៅអ្នកណាឬមើលទៅអ្នកណា ដេក១ទៅ។ ចំងាយប្រហែល ៤ឬ៥ម៉ែត្រ គ្រាន់តែមានបាំងអីតិចណឹង បាំងដូចជាដើមឈើទេ មិនមែនបាំង ជញ្ជាំងទេ។ អត់ឃើញទាំងអស់ទេ ដូចថា វាមានដើមទ្រាំងខែតមួយដុំ របៀបដូចគល់ស្លឹកគ្រៃខ្ញុំចឹងនែ៎។ ក្រាលក្រណាត់កៅស៊ូតិចណឹង ឬកន្ទេលសកញ្ចាស់។ គេនាំទៅចងអញ្ចេះនែ៎ ស្រាតតែសំពត់ទេ។ គេហៅត្រង់ ណឹងនៅគុកអូរអង្គុញ ស្រុកត្បូងឃ្មុំ។ នាងស្លៀកពាក់ខ្មៅ។ គេ ស្រាតនៅកន្លែងគេអោយដេក។ គេនាំនាងទៅ អោយដេកហើយស្រាតតែម្តង។ វាមិនចងទេ វាមានគ្នាបីនាក់ ចាប់ដៃ អាមួយជិះពីលើទៅហើយកាលណា ដែលមិនព្រម ម៉ោវិញដាក់ខ្នោះជើង ហើយយកកន្ទុសគោបត់ជាពីរហើយវាយ ៤ឬ៥រំពាត់។ ខ្ញុំឃើញញយ សឹងរាល់ថ្ងៃ ខ្ញុំជាប់៦ខែ’ ។

លោកចាន់ ថុល និយាយថា សន្តិសុខស្រុកក៏រំលោភស្ត្រីផងដែរ។ ‘ពេលខ្លះថ្នាក់លើក៏ប្រព្រឹត្តអញ្ចឹងដែរ នៅពេលពួកវា ឃើញនារីណាស្អាត ពួកវាយកនារីនោះទៅដេកជាមួយបីបួនថ្ងៃ ហើយនាំយកមកដាក់គុកវិញ’ ។

## ឃ. ការរំលោភសមាជិកខ្លួនឯង_ការរំលោភកម្មាភិបាលនារីខ្មែរក្រហម

មានភស្តុតាងថា ពួកខ្មែរក្រហមមិនត្រឹមតែប្រព្រឹត្តអំពើហិង្សាផ្លូវភេទលើជនស៊ីវិលប៉ុណ្ណោះទេ តែថែមទាំងរំលោភកម្មាភិបាលនារីផងដែរ។ ជនស៊ីវិលមិនមានអំណាចអ្វីក្នុងរឿងការរំលោភដោយពួកមានអំណាចឡើយ តែកម្មាភិបាលក៏មិនអាចរាយការណ៍ពីបទល្មើសនោះដែរ ទោះជាមិនមានការគំរាមកំហែងថា អង្គការក៏នឹងដាក់ទោសពួកគេដែរ។ ឪពុកនាងឈុំបានចូលរួមបដិវត្តន៍ក្នុងឆ្នាំ១៩៦៧ ហើយបាននាំនាងឈុំអាយុ១៤ឆ្នាំទៅរស់នៅក្នុងព្រៃជាមួយគាត់ដែរ។ ពេលភ្នំពេញធ្លាក់ក្នុងដៃ

ខ្មែរក្រហម មេថ្នាក់ខ្ពស់ម្នាក់នាំនាងទៅរស់នៅជាមួយសុផល ជាប្រធានភូមិភាគ។ សុផលព្យាយាមរំលោភនាងឈុំជាច្រើនដង។

'វាចាប់រំលោភលើយើងតែម្ដងពេល ដែលអោយប្ដីទៅឆ្ងាយចឹងទៅ វានៅហើយនៅជាមួយគ្នានោះ ផ្ទះនៅជាមួយគ្នានោះឯង គ្រាន់តែវាអោយបន្ទប់យើងផ្សេងដល់ពេលយប់អញ្ចេះប្រពន្ធវាដេកលក់វាចូលទៅ តែយើងរើបំរះ ប៉ុន្តែធម្មតាស្រីវារើទៅ ទោះយ៉ាងណាក៏មិនបានដូចបំណងយើង ដល់ពេលវារំលោភយើងអត់បានទៅ អាំ! អាំ! រំលោភ ដូចថាមុនធម្មតា គ្រាន់ថា យើងទាញអីៗអត់បានទាន់ ប៉ុន្តែវានៅពីលើយើងបាត់ទៅហើយដល់ចឹង យើងរកស្រែកអីទៅ វាខ្លាចប្រពន្ធវាឮវាឈប់។ ដល់ថ្ងៃក្រោយទៀត ខ្ញុំកំពុងអង្គុយ ត្បាញនោះ វាទៅស្រាតខោស្រាតអីអស់រលីង រហូតដល់ស្រក់ទឹកកាមយ៉ាងពេញ ខ្ញុំនៅតែអត់ទៅរហូត។ ដើម្បីការពារខ្លួនបាន នាងបានរៀបការជាមួយកងការពាររបស់ សុផល តែសុផលបញ្ជូនប្ដីនាងទៅឆ្ងាយ។ ពេលប្ដីនាងមិននៅ សុផល បានរំលោភនាងបីបួនដង តែសុផលមិនដែលបានដល់កិរិតកំពូលទេព្រោះនាងស្រែក ដើម្បីឱ្យប្រពន្ធគាត់ដឹង។ ពេលនោះសុផលខឹងនាងឈុំ ហើយក៏បញ្ជូននាងទៅជួបប្ដីនាង:

នៅយប់នោះវាហៅយើងទៅគក់ច្របាច់អោយវា ដល់ពេលចឹងទៅវាចង់ចាប់រំលោភទៀត ប៉ុន្តែយើងរើ ព្រោះគ្នា ច្រើនទៅ យើងរើ យើងអីទៅ អាចឮមាត់ទៅ វាចាប់អត់បាន ដល់ចឹងវាបណ្ដេញ ខ្ញុំទាំងយប់ អោយខ្ញុំទៅកន្លែងប្ដីខ្ញុំនៅ ឯចំការកាហ្វេ តែតាមការពិតវាអត់អោយយើងទៅជួបទេ ដល់អាអំពើ វាក្ដៅក្រហាយថាវាមិនបានបំពេញបំណងវា វាបណ្ដេញយើងទាំងយប់តែម្ដង' ។

ប្ដី និង ឪពុកនាងឈុំត្រូវគេសំលាប់ ហើយគេបញ្ជូននាងមកដាក់គុកក្នុងភ្នំពេញរហូតដល់កងទ័ពវៀតណាមចូល។

សម្ភាសិតក៏បានរាយការណ៍ពីការរំលោភផ្លូវភេទ ក្នុងជួរខ្មែរក្រហមមុនរបប កម្ពុជាប្រជាធិបតេយ្យ។ លោកនីមុល ជាយោធាខ្មែរក្រហម ក្នុងឆ្នាំ១៩៧៣ ហើយ រៀបរាប់អ្វីដែលគាត់បានឃើញៈ

‘ខ្ញុំឃើញកាលពីឆ្នាំ១៩៧៣ ខ្ញុំបានទៅរស់នៅស្រុកវ៉ារិន៣ខែ អាណុះមាន ចៅហ្វាយ..ប្រធានស្រុកម្នាក់គាត់បានរំលោភ នារីមិនមែនតិចទេណាស់ ច្រើនណាស់ បែកការនឹងនារីម្នាក់អស់ចំនួន៧០ក្បាល។ ខ្ញុំបានចូលរួមចលនាតស៊ូនៅឆ្នាំ ១៩៧៣។ អ្នករំលោភនារីគឺជាទាហាន ប៉ុលពត។ គាត់ឈ្មោះ សួន។ គាត់ជា ប្រធានស្រុកវ៉ារិន ក្នុងខេត្តសៀមរាបឆ្ងាយ ពីទីរួមខេត្ត។ ខ្ញុំកាលនោះទាហានគេអោយទៅនៅឯនោះ ៣ខែ។ ក្នុងការរំលោភនោះ គេយកទៅហៅថា បញ្ចូលជា កម្មាភិបាលដើម្បីតំឡើង ដូចជាកម្មាភិបាលអ្នកដឹកនាំ ទៅគេអោយនារីនោះ ចូលទៅក្នុងបន្ទប់គេទៅ គេសំរាត អស់ទៅណាំ ម្តងមួយៗ។ សួនជាប្រធានស្រុក។ កម្មាភិបាលហ្នឹងឈ្មោះសួន។ យកនារីដើម្បីតំឡើង ហៅថា តំឡើងបុណ្យសក្តិ គេតំឡើងបុណ្យសក្តិកាលណា អោយនារីនោះអោយគេរួមភេទទៅបានគេតំឡើងបុណ្យសក្តិអោយ។ ធ្វើកម្មាភិបាល ដូចធ្វើជាអ្នកដឹក នាំចឹងណាំ បានគេតំឡើងអោយ។ អត់មាននរណាហ៊ាននិយាយទេ ដល់បែកការនឹងនារីម្នាក់ក្រោយទៅនារីនោះអត់ហ៊ាន អត់ព្រមអោយបែកការទៅ។ នារីគេបញ្ចូលម្នាក់ម្តងៗ។ យូរៗម្តង គាត់ទទួលធ្វើជាអ្នកដឹកនាំ។ នារី ប៉ុលពត ហៅថា កូនសមាជិក អ្នកដឹកនាំក្នុងជួរគេ គេធ្វើការតំឡើងបុណ្យសក្តិហើយទៅគេ បញ្ចូលអញ្ចេះ ឯងទៅ’ ។

III. **អំពើហិង្សាផ្លូវភេទដទៃទៀត**

អំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម មិនមែនត្រឹមតែការរំលោភប៉ុណ្ណោះទេ។ សម្ភាសិតបានប្រាប់ពីរឿងបទល្មើសផ្លូវភេទដទៃទៀតដូចជាៈ ការកាត់អវៈយវៈផ្លូវភេទ និង ការបង្ខំសម្រាតសំលៀកបំពាក់។ នាងប៊ុណ្ណារី រំលឹកពីកម្មាភិបាលម្នាក់ដែលបង្ហាញនាង និង ក្រុមស្ត្រីមេម៉ាយនូវរូបថតតួកុនស្រីខ្មែរឈ្មោះ សោម វ៉ាន់សូដានី 'គេថតអោយយើងមើល អត់ឃើញ ផ្ទាល់ទេគ្រាន់តែគេយករូបថតមកអោយយើង រូបថតឈរស្រាត គេជៀវសាច់ជៀវអីចឹងណាំ ។ គេថាតួកុនណឹងពីដើមលេង រឿង រឿងប្រឌិត ឥឡូវគេអោយវាដើរតួជារឿងពិត ចាំគេធ្វើអញ្ចឹងគេធ្វើបាបចឹងទៅណាំ។ គេយកកាំបិទភ្លាស សាច់មួយដងមួយដុំ តែនៅភ្នែកភ្លឹស១ទឹកភ្នែកហូររហូតគេចង។ អត់មានស្លៀកពាក់ខោអាវទេ ហើយយើង ឃើញគេថតយក ឬស្សីមួយដាក់ពីក្រោមទ្វារយើង។ គេថតពីមុខ មើលឃើញទាំងអស់។ កម្មាភិបាលភូមិ មេភូមិគេណឹងយករូបថតមកសួរយើងថា មានស្គាល់ទេ។ គាត់ឈ្មោះ អៀម'។

*នាងម៉ានី*

ម៉ានី ដែលមានអាយុ១២ឆ្នាំ ហើយពេលកំពុងដើររកម្តាយនាង ស្រាប់តែឃើញគេធ្វើទារុណកម្មស្ត្រីម្នាក់ៈ

'នៅយប់នោះ ខ្ញុំឃើញរឿងដ៏សែនរន្ធត់មួយ។ ខ្ញុំឃើញទាហានខ្មែរក្រហមយកស្ត្រីម្នាក់ចងជាប់នឹងដើមត្នោតដោយគ្មានសំពត់ នាងមានតែខោជើងវែងប៉ុណ្ណោះ។ ពួកវាដុតដែកឱ្យក្តៅ ហើយដាក់ដោះនាង។ ពួកវាដកក្រចកដៃក្រចកជើងនាង តែខ្ញុំមិនបានឃើញអ្វីទៀតទេ ព្រោះខ្ញុំភ័យខ្លាច ហើយក៏រត់ចេញទៅ។'

សម្ភាសិតផ្សេងទៀតនិយាយពីការឃើញសាកសពដែលមានស្នាមកាត់អវៈយវៈភេទ។ ឧទាហរណ៍ ស្ត្រីអាក្រាតម្នាក់ដែលមានឈើលានចេញពីប្រដាប់ភេទនាង ឃើញឈ្លបដាក់ស្ត្រីអាក្រាតចុះក្រោម ហើយកាត់ដោះ ហើយឃើញក្រុមឈ្លបជៀរសាច់ គូទប្រុសម្នាក់ និង ស្រីម្នាក់ដែលលុតជង្គង់ខ្លួនអាក្រាត និង ដៃជើងជាប់ច្រវ៉ាក់ក្នុងព្រៃ’ ។

សម្ភាសិតរាយការណ៍ការនូវហេតុការណ៍បង្ខំឱ្យអាក្រាតកាយ ជាពិសេសក្នុងគុក។ ណារិទ្ធិ ជាប់គុក២ដងក្នុងរបបខ្មែរក្រហម និយាយថា: ‘គេបង្ខំខ្ញុំឱ្យស្រាតខោអាវអស់។ ស្ត្រីដទៃទៀតក្នុងគុកក៏ដូច្នេះដែរ។ បន្ទប់ងងឹត។ ខ្ញុំត្រូវតែនៅក្នុងបន្ទប់នោះខ្លួនទទេចំនួន៧ថ្ងៃ’ ។ តែការបង្ខំឱ្យអាក្រាតកាយមិនមែនមានតែក្នុងគុកទេ។ នាងមាលាដែលរស់នៅលើកោះខ្សាច់ជន្លា ដែលនាង ម៉ម កល្យាណ ពណ៌នាថាជាកោះមេម៉ាយ បានរៀបរាប់របៀបដែលគេបង្ខំនាង និងនារីឱ្យដោះសំលៀកបំពាក់ចេញ។

មុនដំបូងវាមកលេងផ្ទះខ្ញុំអញ្ចឹង ផ្ទះអាពតតូចៗណឹងណា៎ មកលេង..លេងៗចឹង...ប្រាជ្ញព្រោកគ្នា ចឹង ដល់វាអត់អីទេ ដល់ពេលនេះវាឃើញខ្ញុំនៅក្មេងណា៎ ខ្ញុំអាយុ៣០ជាង នៅពេញនេះ...ណា៎ ហើយដល់នេះ វាក៏ មើលខ្ញុំយូរៗ គ្នាខ្ញុំបីនាក់ វាពីរនាក់ប្រុសៗពីរនាក់ ដល់ហៅខ្ញុំចឹង លេងសើចៗ ដល់នោះ វាហៅខ្ញុំថា ម៉ែមេ ស្រីឃើញសាច់ម៉ែមេស្រីឯងរលោង ណាស់ ដល់នោះអោយខ្ញុំណឹងដោះអាវ ខ្ញុំថាអត់ដោះទេ វាថាដោះ ទៅ អត់អីទេ ខ្ញុំសុំមើលសាច់ ដល់ហើយខ្ញុំ យើងខ្លាច គេណា៎ ខ្លាចគេបាញ់យើងចោល ខ្ញុំយំផងអីផង ខ្ញុំថាខ្ញុំអត់ ដោះទេថាចឹង ដល់ហើយវាថាដោះទៅវាអត់ធីអីទេវាថាចឹង ចោះ ដល់ហើយវាអោយខ្ញុំដោះ។ ដល់ដោះហើយ ខ្ញុំថាបើចង់អោយខ្ញុំដោះ បែរមុខចេញទៅចឹងអ្ហា ដល់ហើយខ្ញុំថា ពូឯង បែរមុខចេញទៅ

ដល់ហើយវាបែរ មុខចេញ ដល់បែរមុខចេញ ខ្ញុំដោះអាវ ខ្ញុំស្រាតខោ វាអោយដោះទាំងអស់ ចាំ!ដល់ ហើយខ្ញុំបត់ជើង ប្រណំធ្វើ ចឹងទៅ ដល់ហើយវាបាត់អស់ហើយ ខ្ញុំវាធាត់ចោះ ដល់ខ្ញុំធាត់វាអត់ឃើញប្រដាប់ប្រដាខ្ញុំទេ ឃើញតែគូទខ្ញុំពីក្រោយ ពីមុខវាអត់ឃើញប្រដាប់ខ្ញុំទេ ដល់ហើយវាបែរម៉ោវាក្រឡឹងខ្ញុំជុំវិញចឹងទៅ។ ខ្ញុំខ្លាចវារំលោភ វាបាត់អស់ហើយ ខ្ញុំខ្លាចវារំលោភខ្ញុំ វាមើលយូរដែរ ប៉ុន្តែមានគេដើរម៉ោចឹង ខ្ញុំថាខ្ញុំពាក់អាវវិញ ដល់ហើយវាថា ដោះពាក់អាវវិញ ដល់ហើយខ្ញុំអោយវាបែរមុខទៅនោះវិញទៅ អោយខ្ញុំពាក់អាវ។ ខ្ញុំសំពះ។ ដល់ហើយវាថា "មិនបាច់ទេកុំអាល។" វាមើលអស់ចិត្ត ខ្ញុំខ្លាចវាចាប់ផ្តាយើងរំលោភដល់ហើយវាអត់។ ដល់អត់ចឹងគ្នាខ្ញុំពីរនាក់បត់ទន្ទឹមគ្នាចឹងទៅ ដល់ហើយពាក់អាវវិញទៅ។ ខ្ញុំញ័រអស់ហើយខ្ញុំភ័យ ខ្ញុំថាមិនដឹងវារំលោភអ្វី ឬមួយវាធ្វើបាបយើងយ៉ាងម៉េចក្នុងចិត្ត គេយកទៅសំលាប់អស់ហើយ នៅតែគ្នាខ្ញុំប៉ុន្មាននាក់ ខ្ញុំភ័យពេក ដល់ហើយខ្ញុំសំពះវាថា អោយពាក់អាវពាក់អាវវិញ កុំអីមានគេដើរម៉ោ បានវាអោយពាក់ កុំអីវាអត់ អោយពាក់ទេ។

## ក. ការដាក់ទណ្ឌកម្មខាងផ្លូវភេទចំពោះទំនាក់ទំនងដែលមានការព្រមព្រៀងគ្នាហើយ

ការពិភាក្សាត្រង់ចំនុចនេះបានលើកឡើងតែទំនាក់ទំនងផ្លូវភេទដែលមិនមានការព្រមព្រៀងគ្នា។ បញ្ញត្តិប្រឆាំងនឹង ទំនាក់ទំនងផ្លូវភេទមិនត្រឹមតែមានចំពោះទំនាក់ទំនងមិនបានព្រមព្រៀងប៉ុណ្ណោះទេ តែថែមទាំងទំនាក់ទំនងមានការព្រមព្រៀងទៀត។ អង្គការចាត់ទុកស្នេហាគឺជាការខាតបង់ដែលបន្ថយផលិតភាព និងសម្មិទ្ធផល របស់បដិវត្តន៍។ បញ្ញត្តិអនុញ្ញាតឱ្យមានទំនាក់ទំនងគ្នាតែរវាងបុរសស្ត្រីដែលរៀបការហើយ ហើយទោះជាមានការពន្យល់ដូចខាងលើនេះហើយក៏ដោយក៏មានការគ្រប់គ្រងតាមដានយ៉ាងតឹងរឹងដែរ។ ទណ្ឌកម្មចំពោះទំនាក់ទំនងស្នេហាដែលមានការព្រមព្រៀងក្រៅអាពាហ៍ពិពាហ៍ មានដូចជាការធ្វើបាបផ្លូវកាយ និង

ការសំលាប់ចោល។ ឧទាហរណ៏ នាងចាន់ យា បានឃើញមន្ត្រីមូលដ្ឋានចងបុរសម្នាក់ ដែលអង្គការចោទថាមានទំនាក់ទំនងស្នេហាជាមួយនារីម្នាក់ នៅពីក្រោយរទេះគោ ហើយបរទេះអូសតែម្តង។ មនុស្សជាច្រើនទៀត បានរាយការណ៏ថាមិត្តភ័ក្ត និង សមាជិកគ្រួសារ បានបាត់ខ្លួន នៅពេលអង្គការចោទថាខុសសីលធមិ។

ក៏ប៉ុន្តែ នាងតារាចាត់ទុកអំពើហិង្សាផ្លូវភេទជាទណ្ឌកម្ម។ នៅពេលត្រឡប់ពីស្រែពេលយប់ នាងបានទៅមាត់បឹងមួយ ពេលនាងឮសំលេងស្រែកនៅទីនោះ។ នាងបានឃើញនារីម្នាក់ និង បុរសម្នាក់ដែលនាងដឹងថាអង្គការបានចោទថា ខុសសីលធមិ ដោយសារការស្រឡាញ់គ្នា។ នាងបាននិយាយអ្វីដែលនាងបានឃើញ:

‘ខ្ញុំឃើញគេដើរចល័តគ្នាច្រើន រួចទៅគ្នាណឹងស្គាល់គ្នា ស្គាល់គ្នាក៏សួរមិត្តឯងទៅណាណឹង ហឹខ្ញុំទៅ ស្ទូងខាងនោះ។ រួចទៅ មេគេថា អាណនអ្នកនោះប៉ះសីលធមិជាមួយអ្នកនេះហើយ ទៅចាប់គ្នាម៉ោ យកមកវ៉ាយ។ មិនដឹងប៉ះសីលធមិគេណឹងពីថ្ងៃណាខែណាម៉ោ ឃើញម៉ោជុំគ្នា៤ឬ៥គូចឹងទៅ ខ្លះទៅក៏អាគ្នាវ៉ា ដែលវ៉ាធ្វើការណឹងវ៉ាយកជំពុសទុងស្រោតអាមួយទៅ ទៅបិទអាមួយ កៀបអាមួយ អាមួយទៅកៀបអាមួយ។ វ៉ាកៀបពីអាមួយ ទាញចឹងទៅ សួរថាឈឺទេ កៀបអា ណឹងធ្វើចឹងទៅ ទៅកៀបអាប្រុស កៀបអាប្រុស សួរថាឈឺទេ! អាណឹងឃ្លានទៀតទេ។ ឃើញណឹង ខ្ញុំមកពីមើលក្របី មើលក្របីម៉ោវ៉ាយប់ យប់ខែភ្លឺ ខែភ្លឺគេ នៅលើកដីពួកអ្នកប៉ះសីលធមិណឹង គេអត់អោយឈប់ទេ។ អត់មានបាន ស្គាល់ឈ្មោះគេទេ គ្រាន់តែបានថា ចំណាំមុខគេ’ ។

## IV. ការរំលោភផ្លូវភេទទៅលើបុរស

មានរបាយការណ៏ជាច្រើនស្តីអំពីអំពើហិង្សាផ្លូវភេទប្រឆាំងបុរសក្នុងការស្ទង់មតិលើកដំបូង តែមានករណី ចំនួន៣ ដែលគេបានឃើញផ្ទាល់ភ្នែក ហើយបាន

បញ្ចូលក្នុងរបាយការណ៍នេះ។ នាងមាលាបានប្រាប់រឿងក្មេងប្រុសអាយុ១៧ឆ្នាំម្នាក់ដែលបង្ខំ រួមភេទជាមួយស្ត្រីចំណាស់អាយុ៤៥ឆ្នាំម្នាក់។ ស្ត្រីនោះជាប្រធានហិរញ្ញវត្ថុប្រចាំតំបន់នោះ។ មាលារៀបរាប់ថាៈ

វាចេះតែមកប្រាប់ខ្ញុំថា មីងអើយជួយខ្ញុំផងខ្ញុំខ្លាចណាស់ថាចឹងណាំ ហើយខ្លាចក៏មិនយកទៅណាគ្នា ចេះខ្លាច ខ្ញុំក៏មិនដឹងយកវាទៅណា គ្នាក៏មិនដឹងទៅណា បើកន្លែងណឹងវាមុខតែស្លាប់ហើយវាថាចឹង ហើយដល់ យាយណឹងពោះធំ យាយណឹងអាយុ៤៥។ ដល់បានពោះធំពីរខែ ចេះចាប់វា វាទៅកន្លែងណាចាប់វាកន្លែងណឹង។ ដល់ទៅដេកហូបបាយ ហូបអី ហើយចឹង ហៅវាទៅនេះទៅនោះ ហើយវាខ្លាចក្មេង វាចេះណឹងវាចេះតាម ដល់តាម១ឈ្លបគេឮ ដល់ឈ្លបគេដឹងថា អាណឹងនិងយាយណឹងស្រឡាញ់គ្នា ហើយគ្នាដាក់ធុងសាំង ធុងសាំងយើងណឹងធំដាក់គ្របនៅលើណឹង ហើយយកដុំថ្ម សង្កត់គ្នាសឹងដាច់ខ្យល់ ខ្លាចកុំអោយគេដឹង ដល់ ហើយគ្រប់គ្នាយំ ដល់ពេលនេះខ្ញុំដើរក្បែរណឹង វាគោះធុងហៅខ្ញុំ ថាមីងអើយជួយស្រាយខ្ញុំផងដល់ខ្ញុំទំលាក់ អាធុងណឹងវាចេញ។ ដល់លុះត្រាគេចាប់វាខ្លាំងពេកគេដឹង គេយកទៅដាក់ឃុំក្នុងគុក គេដឹងគេយកទៅដាក់ ក្នុងគុក ដាក់ក្នុងភ្នំល្អាង ដល់យកទៅ ដាក់ក្នុងគុកយាយណឹងយកបាយទៅអោយស៊ី ហើយគេវាយគ្នាអើយ វាយ ហើយយាយណឹងយកបាយទៅអោយហូបរាល់ថ្ងៃ ដល់ហើយពេលនោះ យកទៅដាក់គុក ដល់ពេលគេចេញទៅចប់ មិនដឹងទៅណាមកណា មិនដឹងគេសំលាប់ស្លាប់ ឬយ៉ាងណាក៏មិនដឹងទៅបាត់រហូតដល់ឥឡូវ។

ពួកខ្មែរក្រហមលើកតំកើងសមភាពផ្លូវការរវាងបុរស និង ស្ត្រី ហេតុដូច្នេះហើយស្ត្រីមានមុខងារក្នុងរដ្ឋអំណាចខ្លះដែរ។ ដូច្នេះពួកគេអាចប្រើអំណាចប្រព្រឹត្តបទល្មើសផ្លូវភេទដូចបុរសដែរ។ មានរឿងក្តី២ទៀតដែលបានឃើញផ្ទាល់ភ្នែករវាង

បុរស និង បុរស ហើយទាក់ទងនឹងកងឈ្លបម្នាក់ជៀវសាច់កំប៉េះគូទ និងទាញលឹង្គបុរសម្នាក់។ ពិបាកសន្និដ្ឋានថាតើអំពើហិង្សាផ្លូវភេទបែបនេះ កើតឡើងញឹកញាប់យ៉ាងណានោះ។ ពុំមានទិន្នន័យជាតួលេខលើប្រធានបទនេះទេ ហើយដោយអំពើល្មើសផ្លូវភេទ ប្រឆាំងបុរសរឹតតែជាការហាមឃាត់ទៅទៀតក្នុងសង្គមកម្ពុជាជាងបទល្មើសប្រឆាំងនឹងស្ត្រីភេទ ដូច្នេះមិនមានរបាយការណ៍ គ្រប់គ្រាន់ក្នុងចំណោមសម្ភាសិតទាំងនេះ។

## V. **អំពើហិង្សាខាងផ្លូវភេទ និង អាពាហ៍ពិពាហ៍ចាប់បង្ខំ**

### **ក. សេចក្តីផ្តើម**

ពួកខ្មែរក្រហមអនុញ្ញាតឱ្យមានទំនាក់ទំនងស្នេហា តែក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុណ្ណោះ។ តែប្រជាជនមិនមានសិទ្ធិ ជ្រើសរើសគូស្រករដោយខ្លួនឯងឡើយ ដោយអង្គការមានគោលនយោបាយមួយថា អង្គការជាអ្នករើសឱ្យ ហើយរៀបការឱ្យថែមទៀត។ ខណៈពេលដែលយើងប្រមូលរឿងរៀបការក្នុងរបបខ្មែរក្រហមដោយមិនបានរៀបរាប់ពីរបៀបរៀបចំពិធីការទេ ព្រោះចំនុចសំខាន់ទីនេះ គឺផ្តោតលើអំពើហិង្សាផ្លូវភេទដែលមានទំនាក់ទំនងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ។

សម្ភាសិតមានចរិតរឹងតឹងក្នុងការញែកអាពាហ៍ពិពាហ៍ទាំងនេះពីប្រពៃណីខ្មែរដែលឪពុកម្តាយជាអ្នករៀបចំអាពាហ៍ពិពាហ៍ឱ្យ។ ដោយឡែកបទសម្ភាសន៍សង្កត់ធ្ងន់ថា វាមិនដូចអាពាហ៍ពិពាហ៍រៀបចំដោយមាតាបិតាទេ ដែលគូស្រករយល់ព្រមចំពោះគ្នាទៅវិញទៅមក តែក្នុងរបបខ្មែរក្រហម ប្រជាជនគ្មានជំរើសអ្វីទាំងអស់គេរៀបការជាមួយមនុស្សដែលអង្គការជ្រើសរើសឱ្យ។ អ្នកដែលមិនព្រមរៀបការត្រូវចោទថាជាខ្មាំងប្រឆាំងនឹងអង្គការ។ នាងចាន់យ៉ានិយាយថា ‘បើអ្នកមិនយក

គូស្រករនោះទេ អ្នកពិតជាមិនមែនមនុស្សស្រលាញ់អង្គការឡើយ ហើយគេស្គាល់ថា ជាសត្រូវប្រឆាំងប្រទេសជាតិទៀតផង' ។

អ្នកដែលទទួលបន្ទុករៀបចំពិធីការ ឆ្លើយតបនឹងការបដិសេធដោយធ្វើការគំរាមកំហែងជាអំពើហិង្សា ឬជាអំពើហិង្សាជាក់ស្តែង ក្នុងនោះមានការវាយតប់បង្ខំឱ្យធ្វើការងារ និង សំលាប់ចោលទៀតផង។ ផល្លានិយាយថា 'គេបានដាក់ច្រវ៉ាក់ និង វាយដំខ្ញុំ ហើយសុខា ក៏បាននិយាយដែរថា ខ្ញុំដឹងបើខ្ញុំមិនព្រមរៀបការ គេច្បាស់ជាកាត់កខ្ញុំមិនខាន ព្រោះខ្ញុំឃើញករណីនេះជាច្រើនដង ហើយ'។ ថាវីរ៍ ជាដំបូងមិនព្រម រៀបការ តែខ្លាចទទួលផលវិបាកផ្សេងៗ។ នាងបានរៀបរាប់ដូច្នេះថា:

'ខ្ញុំនិយាយដែរតើតែគេថាបើយើងមិនព្រម គេអោយទៅជីកលើទំនប់អ៊ីណាឆ្ងាយអីទៅណាស់ គេយកមនុស្សយកអី ដាក់អូសតាមសេះតាមអី ខ្ញុំខ្លាចទៅ ខ្ញុំក៏ព្រមព្រៀងទៅ' ។

ពិធីរៀបការក៏ខុសគ្នាយ៉ាងខ្លាំងពីប្រពៃណីខ្មែរ តែតាមការសិក្សា វាមានទំរង់ស្រដៀងគ្នាក្នុងខេត្តទាំងអស់។ អង្គការ កោះហៅប្រជាជនឱ្យចូលរួមពិធីការ ហើយកូនក្រមុំកូនកំលោះឈរជាជួរ ស្ត្រីមួយជួរ បុរសមួយជួរ។ គូស្រករភាគច្រើនជាមនុស្សប្រភេទដូចគ្នា ដូចជា: អ្នក១៧ មេសា រៀបការជាមួយអ្នក១៧មេសាដូចគ្នា។ គូស្រករដែលមិនដែលឃើញគ្នាពីមុន មកចាប់ដៃគ្នា ហើយសូត្រការប្តេជ្ញាចិត្ត និងស្មោះត្រង់ចំពោះគ្នា និង ចំពោះអង្គការ។ អង្គការមិនបានឱ្យដំណឹង ឬអញ្ជើញគ្រួសារសាមីខ្លួនទេ ហើយមិនមានការជប់លៀងអ្វីដែរ។ សម្ភាសិតម្នាក់ឈ្មោះបុប្ផានិយាយថា 'អង្គការមានមាន់ខ្លួនឯង តែគ្មានអ្វីផ្សេងទៀតសំរាប់គូស្រករម្នាក់ៗទេ' ។ ពិធីរៀបការខ្មែរតាមប្រពៃណីមានរយៈពេលវែង ហើយធំដោយមាន ការចូលរួមពីមិត្តក្រុមគ្រួសារ និង គូស្រករ។

ការរៀបរាប់ជាប្រចាំអំពីពិធីការពីកន្លែងមួយទៅកន្លែងមួយបានបង្ហាញពីគោលនយោបាយក៏រិតខ្ពស់នៃអាពាហ៏ពិពាហ៏ដោយបង្ខំ។ មានការប្រែប្រួលខ្លះៗពីក៏រិត អនុវត្តគោលនយោបាយនេះដោយអាជ្ញាធរមូលដ្ឋាន។ សុផន និយាយថាៈ

'គេបង្ខំអោយខ្ញុំទៅប្តេជ្ញាបីដង រៀបការបីដង ទៅលើកទីមួយ ខ្ញុំថាអត់មានខោអាវខ្មៅពាក់ ខោអាវចឹង អត់មាន ខ្ញុំថាខ្ញុំអត់ទេ ចង់បានអាណឹង ចង់បានកន្សែងកាលនោះគេអត់ គេថាអោយខ្ញុំប្តេជ្ញា ខ្ញុំថាខ្ញុំអត់ទេ លើកទីមួយ។ ដល់លើកទីពីរទៀត គេហៅខ្ញុំទៅម្តងទៀត តែមិនមែនប៉ាវាណឹងទេ គឺផ្សេងទៀត គឺយើង១៧ដូចគ្នា អ្នកជម្លៀសទៅចឹង ណា៎ មិនគូណឹងដដែលទេ គូផ្សេង គេហៅយើងទៅទៀតខ្ញុំទំនាស់ចឹង ទៀត អត់បាន ទើបតែបានគូក្រោយណឹងទេ។ ស្រុកណឹងស្រួលណាស់ស្រុកកំពង់ត្រាច ស្រួលដោយកន្លែង កន្លែងណាធ្វើបាបធ្វើណាស់ កន្លែងណាអត់ធ្វើអត់ទេ' ។

សូម្បីតែកន្លែងនេះ ក៏មានគោលនយោបាយនេះដែរ តែការអនុវត្តមានការប្រែប្រួលខ្លះ។

សម្ភាសិតមួយចំនួនតូចអាចនិយាយពីហេតុផលណាមួយនៃគោលនយោបាយនេះ តែវាសំដៅដល់ការគ្រប់គ្រងលើបុគ្គល ធានាឱ្យមានការបន្តពូជ តែក៏មានបំណងរំលាយទំនាក់ទំនងស្នេហា និង គ្រួសារ ដែលចាត់ទុកថាធ្វើឱ្យខាតបង់ដល់គោលដៅរបស់បដិវត្តន៍។ ពួកខ្មែរក្រហមផ្តល់ឱកាសទំនាក់ទំនងតិចតួចណាស់ រវាងគូស្រករដែលរៀបការហើយ ដោយទុកឱ្យនៅជាមួយគ្នារយៈពេលពីរបីថ្ងៃប៉ុណ្ណោះ ក្រោយពីរៀបការរួច តែបន្ទាប់មកឱ្យជួបគ្នាតាមកាលកំណត់។

### ខ. ការចាប់រំលោភដោយបង្ខំ

សម្ភាសិតភាគច្រើនរាយការណ៍ថា អំពើហិង្សាមិនមែនផ្លូវភេទជាការដាក់ទណ្ឌកម្មមួយ ឬការគំរាមកំហែងចំពោះការមិនព្រមរៀបការ។ តែសម្ភាសិតមួយចំនួនរាយការណ៍ ពីការរំលោភដើម្បីបង្ខំ ឬដាក់ទណ្ឌកម្មស្ត្រីដែលមិនព្រមរៀបការ។ នាង ចន្នី រៀបរាប់ពីរបៀបដែលគេយកនាងទៅមន្ទីរសន្តិសុខ នៅពេលនាងមិនព្រមរៀបការជាមួយប្តីនាងដែលអង្គការជ្រើសរើសឱ្យនាង។ ក្នុងមន្ទីរសន្តិសុខស្រុក មានយោធាម្នាក់ ដែលនាងនិយាយថាជាមនុស្សចិត្តល្អ បាននាំនាងទៅមើលស្ត្រីដែលគេរំលោភៈ

'រៀបការជំនាន់ណឹងដោយសារគេចាប់បង្ខំ។ ប្តីប្រពន្ធមីងពីរនាក់ មីងអត់ដែលស្គាល់គ្នា ស្រលាញ់គ្នា ទេណា៎ ដល់ពេលរួចទៅគេចាប់បង្ខំ ដល់មីងអត់ព្រម ដល់មីងអត់ព្រមទៅ វាចាប់ចងមីង ចាប់ចងមីង ស្លាបសេកទៅក្រោយចឹង ដាក់ច្រវ៉ាក់ជើងមីងទៀតណា៎គ្រប់៣ថ្ងៃ។ គេអត់ប្រាប់មុនទេ។ មីងស្គាល់ ប៉ុន្តែមីងអត់ដឹងថារៀបការអោយម្នាក់ណឹងផង។ គេថាបើយើងមិនព្រមយកទេ គេយកយើងទៅដាក់គុក..គេយក យើងទៅសំលាប់ចោល។ ប្តីគាត់នៅធ្វើកម្មករ ជៀរជ័រដែរ ចំការកៅស៊ូទាំងអស់គ្នា។ បើមីងមិនព្រមចុះ ដំណេក យ៉ាងម៉េច បើខុសពីនោះ អត់មានចុះដំណេក នារីដទៃ ទៀតយកគ្នាដាក់សន្តិសុខ ពួកអាទាហានអាពត ចាប់គ្នារំលោភដោយជើងជាប់ចំណង។ ស្រាតខោស្រាតអាវចាប់គ្នា រំលោភតែម្តង ជើងជាប់ចំណងនៅក្នុងគុក។ មីងឃើញផ្ទាល់តែម្តង គេនាំមីងទៅមើលថាចង់ធ្វើគំរូដូចគេ ឬអត់។ ទៅណឹងមិនឃើញគេចាប់រំលោភទេ ប៉ុន្តែគេសំរាតអាវសំរាតខោមើលណា៎ ហើយទៅគេអោយយើងឈរមើលទៅ ថាចង់ ធ្វើដូចគេណឹងអត់ អាណឹងគេរំលោភរួចហើយ។ ហើយដៃគ្នាចងឆ្កាងចេះនែ៎ ហើយជើងសុទ្ធតែជាប់ខ្នោះ ត្រដាងរហូត

ហើយសុទ្ធក្រមុំៗស្អាតចឹងនែ៎ ហើយគេយកគ្នាទៅវាយចោលទៀត។ ពួកទាហាន ដែលវាសំលាប់ហ្នឹង វាទៅប្រាប់មីងថា បើមិនតាមអង្គការគេយកពួកប៉ុន្មាននាក់ ដែលមិត្តឯងឃើញចូលរណ្តៅអស់ហើយ’ ។

នាងលេណារៀបរាប់ដោយឃើញគេរំលោភក្មួយស្រីនាង ព្រោះនាងមិនព្រម រៀបការជាមួយប្តីដែលអង្គការជ្រើសរើសឱ្យនាង។ ពេលនាង លេណា ធ្វើដំណើរទៅ ធ្វើការនៅស្រែ ក៏ឮសំលេងយំ ហើយឃើញទាហានខ្មែរក្រហម៣នាក់កំពុងរំលោភ ក្មួយស្រីនាង។ ទាហាន២នាក់ចាប់ ហើយម្នាក់ទៀតរំលោភ។

‘គេស្រាតខោអាវហើយរំលោភតែម្តង ស្រែកអោយជួយ ទៅជួយម្តេចកើត ឃើញនឹងភ្នែកចឹងម៉ង បង្ខំអោយរៀបការ ហើយអត់ព្រមរៀបការនោះ អត់ព្រមការ ការម្តង៥០គូ ម្តង២៥គូ ចាប់ការតែម្តង ឃើញ នឹងភ្នែកចឹងម៉ង តែមិន ព្រមសំលាប់យើងចោល។ ឃើញរឿងហ្នឹង យើងដើរទៅ ឧទាហរណ៍ដូចជាយើងទៅ ធ្វើការចឹងទៅ ឃើញតែម្តង ឈរមើលចឹងទៅគេដេញយើង គេថាឈរមើលអី? ចង់ម៉េច ចង់ងាប់ដែរអី? ’

នាងលេណាលែងបានឃើញក្មួយស្រីនាងទៀតឡើយ ហើយគិតថាច្បាស់ជា ទាហានទាំងនោះ រំលោភ ហើយសំលាប់។

## គ. ការបង្ខំរួមភេទក្នុងចំណងអាពាហ៍ពិពាហ៍

ការបង្ខំនេះ មិនមែនត្រឹមតែបង្ខំមនុស្សឱ្យរៀបការប៉ុណ្ណោះទេ តែនៅបន្ត ទៀត ក្រោយពេលរៀបការរួចហើយ។ អ្នកទើបរៀបការហើយមានពេលជួបគ្នាតែ ដំបូង ហើយបីបួនយប់ទៀតតែប៉ុណ្ណោះ។ ចំពោះគូស្រករដែលពីមុនមិន ដែលស្គាល់ គ្នាយប់ដំបូងមានការលំបាកណាស់។ អ្នកផ្តល់ពតិមានស្ទើរតែទាំងអស់ និយាយថា ពួកគេយល់ថា អង្គការទាមទារឱ្យពួកគេរួមភេទ ជាមួយគូស្រករខ្លួន។ ឈ្លបមក

តាមដាននៅក្រោមផ្ទះផ្សំដំណេកដែលរៀបចំដោយអង្គការ ដើម្បីមើលថាតើគូស្រករទាំងនោះ ឈ្លោះគ្នា ឬកំពុងគេងជាមួយគ្នា។ សុផុន ដែលត្រូវបង្ខំឱ្យរៀបការក្រោយពីបានបដិសេធ ២ដង ហើយនិយាយថា 'ក្រោយរៀបការរួច ឈ្លបមកមើលថាតើយើងគេង ជាមួយគ្នាឬអត់ បើអត់គេនឹងយកយើងទៅកសាង។ យើងទាំងពីរនាក់មានបំណង គេងជា មួយគ្នាដោយខ្លាចអង្គការ' ។

អ្នកផ្តល់ពត៌មានជាច្រើននិយាយថា ទោះជាពួកគេដឹងថា ពួកគេត្រូវតែគេងជាមួយគ្នា ក៏ពួកគេធ្វើមិនកើតដែរ ព្រោះពួកគេខ្មាស់អៀន ឬភ័យខ្លាចគ្នា។ សុវណ្ណថារី និយាយថាៈ

'យប់ថ្ងៃរៀបការ គេមកលបស្តាប់ក្រែងយើងមិនត្រូវគ្នា។ ដឹងថាគេម៉ោពេលដែលយើងក្រោកបត់ជើង ចឹងទៅបើកទ្វារ ឃើញគេនៅយាមឃើញផ្ទាល់ភ្នែក។ ទោះបីថាឃើញវាហើយ ទោះបីជាយើងមិនទាន់ជា បានរួមដំណេកជាមួយគ្នា ក៏ដោយ រួមដំណេកគ្នាក៏ដោយ ខ្លាចណាស់ ភ័យខ្លាចសូម្បីថា អត់រៀងខ្លួនមិនអោយ មានបញ្ហាទេ ក្រែងវាយកទៅធ្វើបាប។ គាត់សួរខ្ញុំមុនថា គាត់រៀបជាមួយខ្ញុំហ្នឹង តើខ្ញុំមានបញ្ហាអ្វី ឬក៏មិន ស្រលាញ់គាត់អីហ្នឹងណា។ ខ្ញុំថាខ្ញុំតាមអង្គការ អង្គការរៀបអោយខ្ញុំតាមអង្គការ ហើយគាត់ក៏ដូចគ្នាដែរ ទោះបីថាយើងមិនស្គាល់គ្នាក៏ដោយ គឺថាអង្គការ គេរៀបហើយ យើងខ្លាចគេយកទៅសំលាប់ ដូច្នេះចេះត្រូវតែរស់នៅជាមួយគ្នាទៅ។ ខ្ញុំនិយាយអោយអស់ទៅ ថ្ងៃទីពីរ ទើបបានរួមដំណេកគ្នា គឺថានៅខ្លាចរៀងខ្លួនភ័យណាស់ ភ័យរៀងខ្លួន' ។

អ្នកឆ្លើយសំណួរភេទប្រុសម្នាក់ឈ្មោះ បូណា ពន្យល់ថា គាត់ និងប្រពន្ធថ្មីរបស់គាត់មិនបានគេងជាមួយគ្នាទេនៅយប់ដំបូង ព្រោះស្ត្រីខ្មែរតែងអៀនខ្មាស់

ហើយខ្ញុំក៏មិនហ៊ានធ្វើឱ្យនាងខឹងដែរ ព្រោះពេលនោះនាងអាចប្រាប់អង្គការ ហើយគេអាចសំលាប់ខ្ញុំដែរ’ ។

តែគូស្រករដទៃទៀតច្រើនមានការបង្ខិតបង្ខំ។ នាងចាន់ ណារីពន្យល់ថា:

‘ពេលស្នាក់នៅជាមួយប្ដីថ្មី រួមរ័ក្ស តែរួមដោយបង្ខំ ខាងប្រុសគេរួមរ័ក្សក៏ប៉ុន្តែរួមដោយបង្ខំខ្ញុំ គេធ្វើបាប.. គេធ្វើបាប គេវាយ វាយយ៉ាងត្រង់ភ្លឹង យើងរើអត់រួចទេ គេវាយខ្លាំងឈឺ ឈឺលើកជើងអត់រួចទេ គេវាយជាមួយដៃ។ ដល់ពេលណាយើងឈឺ យើងរើអត់រួច ដល់គេដេកជាមួយយើងទៅ’ ។

នាងបូណារីរៀបរាប់ ពីរបៀបកម្មាភិបាលខ្មែរក្រហមប្ដីថ្មីរបស់នាងរំលោភនាង ពេលនាងមិនព្រមគេងជាមួយគាត់:

‘យើងអត់ត្រូវគ្នា ស្អែកឡើងប្ដីណឹងទៅប្រាប់កម្មាភិបាលថាយើងអត់ត្រូវចឹងណាំ។ យើងអត់អោយគេដេកនៅជាមួយ យើងចឹងទៅណាំ។ គេចង់តែយើងអត់ចង់ យើងអត់ពេញចិត្តហើយណា មួយយើងពិបាកដូចថាប្ដីមុនស្លាប់មិនដឹងម៉េចៗ យើងអត់ចង់បានចឹងទៀតណាំ។ ដល់ចឹងទៅគេអោយយើង រំលោភនៅមុខវាអោយមើលចឹងយើងមានការឈឺចាប់។ ខ្លាចដែរខ្លាចគេវាយចោល។ ពេលខ្ញុំបដិសេធគេនាំទៅកន្លែងគេណឹង។ គាត់អត់ធ្វើបាបទេ តែព្រឹកឡើងគាត់ទៅរាយការណ៍។ ក្រោយមកគេហៅយើងទៅ គេហៅយើងទៅសួរ ប្រសិនបើយើងអត់ទៅ គេបញ្ជូនយើងទៅកន្លែងថ្មីទៀត គេយកទៅវាយចោល ហើយសុខចិត្តព្រមនៅដេកជាមួយគេចឹងទៅ គេគំរាមកំហែង កាំភ្លើងកាន់នៅដៃ។ ដល់ហើយយើងព្រម កុំអោយគេយកយើងទៅវាយចោល។ គេបញ្ជាអោយយើងដេកនៅជាមួយគេ គេថាអោយយើងដោះអាវ

ដោះខោអោយគេរំលោភចឹងណា៎ បើយើងព្រមគេដើរចេញ បើយើងអត់ព្រមគេនៅមើលយើង ដល់ហើយ យើងឆ្លើយ ថាព្រម ។ យើងមានអារម្មណ៍ខ្មាស់គេ' ។

ការរំលោភក្នុងចំណងអាពាហ៍ពិពាហ៍ ក៏បង្ហាញឱ្យឃើញមួយចំណែកដែរក្នុងទស្សនៈប្រពៃណីខ្មែរដែលថា ស្ត្រីត្រូវតែរួមភេទជាមួយប្តីខ្លួន។ នាងចាន់ ណារីបានពន្យល់ នៅពេលសួរថាតើហេតុអ្វីបានជាគិតថា ប្តីខ្លួនឯងរំលោភ? នាងឆ្លើយថា 'គាត់បង្ខំឱ្យខ្ញុំរួមភេទជាមួយគាត់ ព្រោះគាត់មានសិទ្ធិរួមភេទ' ។ តែការយល់ជាប្រចាំរបស់សម្ភាសិតដែលថា ពួកគេត្រូវឱ្យរួមភេទជាមួយគូស្រករថ្មីរបស់ខ្លួន បង្ហាញឱ្យឃើញថា វាជាគោលនយោបាយខ្មែរក្រហមដែលគូស្រករដែលពួកវាបង្ខំឱ្យរៀបការត្រូវតែរួមភេទ។ ក្នុងករណីច្រើនណាស់ ដែលមានការបង្ខិតបង្ខំនោះរួមមានការតាមដាន និង ការកសាង តែក៏មានការបង្ខិត បង្ខំដោយផ្ទាល់ដូចជាការរំលោភមកលើនាងប៉ុណ្ណារីជាដើម ។ ការបង្ខំរួមភេទក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំយ៉ាងហោចណាស់ក៏ធ្វើឱ្យគេយល់ឃើញថា ជាមូលហេតុចំបងនៃអាពាហ៍ពិពាហ៍ជាការបន្តពូជខ្លះដែរ ។

## ឃ. ស្ត្រីជារង្វាន់មួយ

រដ្ឋការផ្តល់សិទ្ធិដល់យោធា និង យោធិនពិការជ្រើសរើសស្ត្រីមករៀបការ ។ ចំនួនសម្ភាសិតដែលជាអតីតកម្មាភិបាលខ្មែរក្រហមមានតិចតួច និង ភូមិសាស្ត្រមានកំរិតពេកដោយមិនអាចនិយាយថា ការអនុវត្តន៍បែបនេះមានលក្ខណៈជាទូទៅទេ រាល់អ្នកដែលនិយាយរឿងប្រាប់យើងសុទ្ធតែនៅភូមិភាគកណ្តាល និង ខាងកើតក្នុងសម័យខ្មែរក្រហម ។ សម្ភាសិតមួយចំនួនដែលជាអតីតយោធា ឬយោធិនពិការនិយាយថា ពួកគេមិនមានសិទ្ធិជ្រើសរើសប្រពន្ធទេ ។ លោកនិមុលដែលពិការភ្នែកក្នុងការប្រយុទ្ធគ្នាមុនឆ្នាំ១៩៧៥ រាយការណ៍ថាបានរៀបការជាមួយស្ត្រីត្រឹមត្រូវម្នាក់ក្នុងឆ្នាំ១៩៧៧។ 'ប្រុស១ទាំងអស់សុទ្ធតែជា ទាហានពិការខ្មែរក្រហមទាំងអស់ តែស្រី១

មិនមែនពិការទេ' ។ គ្មាននរណាម្នាក់ឱ្យឱកាសគាត់ជ្រើសរើសប្រពន្ធទេ ហើយគាត់មិនដែលជួបគ្នាសោះមុនពេលរៀបការ ។ 'ខ្ញុំសួរប្រពន្ធខ្ញុំពីរថ្ងៃមុនពេលរៀបការថា តើនាងស្រឡាញ់ខ្ញុំឬអត់' ។ នាងនិយាយថា នាងគោរពបញ្ជាអង្គការ' ។ លោកកុសល ជាអតីតទាហានខ្មែរក្រហមនិយាយថា លោកបានទទួលបញ្ជាពីអង្គការថាឱ្យគាត់រៀបការជាមួយស្ត្រីម្នាក់ដែលមានសក្តិធំជាង។ 'ខ្ញុំនិយាយទៅកាន់អង្គការ ព្រោះខ្ញុំមិនព្រមរៀបការទេ ពេលនោះ អង្គការចាប់ខ្ញុំដាក់គុក។ អង្គការប្រាប់ខ្ញុំថា អ្នកត្រូវតែរៀបការព្រោះអ្នកមានប្រវត្តិប្រយុទ្ធ ដូច្នេះអង្គការត្រូវតែរៀបចំការឱ្យអ្នក' ។

វីកគីរី មានយោបល់ថា ការរៀបការជារង្វាន់ចំពោះកម្មាភិបាល និង អតីតយោធិនមិនអាចជាទូទៅទេ ព្រោះបញ្ញត្តិហាមឃាត់មិនឱ្យមានទំនាក់ទំនងស្នេហាក្រៅអាពាហ៍ពិពាហ៍ និងកំរិតការរៀបការចំពោះមនុស្សដែលមានប្រភេទសង្គមដូចគ្នា ត្រូវបានអនុវត្តយ៉ាងតឹងរឹង ហើយទំនងជាមានវិសាលភាពតិចតួចចំពោះការរៀបការដែលគេថាដោយបង្ខំរវាងទាហានបដិវត្តន៍ និង ជន្ទាសជននារី។ តែការហាមឃាត់ចំពោះការរួមភេទក្រៅ អាពាហ៍ពិពាហ៍មិនល្មើសនឹងគោលនយោបាយនេះទេ។ លោក វណ្ណៈ ជាអតតីកូនទាហានខ្មែរក្រហមនិយាយថាៈ

'ព្រោះខ្ញុំ ខ្ញុំយល់ថា គេប្រហែលជា គេថា គេល្អមួយផ្នែកដែរ ព្រោះហៅថារំលោភបំពានណឹង គេផ្តាច់សីលធមិមិន អោយការរំលោភបំពាន ហើយអង្គការជំនាន់ណឹង អង្គការប្រសិនបើគេនេះ គេរៀបអោយទាំងគូ១តែម្តង ត្រង់ការរំលោភគឺគេផ្តាច់សីលធមិ គេឃើញគេត្រូវផ្តន្ទាទោស ឬក៏សំលាប់ចោល។ រឿងសិទ្ធិគឺអត់មាន ប៉ុន្តែសំរាប់អង្គការគេ រៀបចំអោយតែម្តង បើគេផ្តល់យោបល់ថា ឥឡូវស្ត្រីបុរសយ៉ាងម៉េច១ គេទំនាក់ទំនងខ្លួនផ្ទាល់យើង យើងអាចទៅ ទំនាក់ទំនងដល់ស្ត្រីផ្ទាល់ ' ។

ការអនុញ្ញាតឱ្យកម្មាភិបាលជ្រើសរើសប្រពន្ធ មិនជាការល្មើសនឹងគោលនយោបាយលើសកម្មភាពផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ទេ។ ការរួមភេទក្នុងអាពាហ៍ពិពាហ៍ មិនត្រឹមតែអាចទទួលយកបានទេ ថែមទាំងគោរពប្រពៃណីខ្មែរ និងនយោបាយរដ្ឋាភិបាលថែមទៀតផង (ដូចដែលការពិភាក្សាបានបង្ហាញខាងលើ)។ នយោបាយនេះអនុញ្ញាតឱ្យមានការរួមភេទដោយបង្ខំ បំភ័ន្តពីក្រោយអាពាហ៍ពិពាហ៍ដោយបង្ខំ។ បញ្ញត្តិក៏រឹតអាពាហ៍ពិពាហ៍ចំពោះមនុស្សប្រភេទដូចគ្នាមិនមែនជាការល្មើសទេ បើសិនជាការរៀបចំនេះត្រូវបានចាត់ទុកថាជាប្រពន្ធ័រង្វាន់មួយ។ ស្ត្រីដ៏ស្អាតបំផុតតែងចាត់ទុកថាជាប្រជាជនថ្មី ជាស្ត្រីដែលមិនធ្លាប់ធ្វើការងារដោយកំលាំង។ ជាជាងក៏រឹតជំរើសចំពោះកម្មាភិបាលដទៃទៀត រង្វាន់នេះគឺអនុញ្ញាតឱ្យយោធិន និងអតីតយោធិនឱ្យ មានសិទ្ធិជ្រើសរើសស្ត្រីតាមចិត្ត។

*នាងកល្យាណ*

កល្យាណ ដែលជាប្រជាជនថ្មី និយាយថាមានទាហានខ្មែរក្រហមម្នាក់បានសុំឱ្យអង្គការរៀបការគាត់ និង នាង។

'បើដឹងរត់បាត់ហើយអត់ដឹង ចាប់ដាក់ទន្ទឹមគ្នា ចាប់ដាក់មួយគូៗទៅ អាវអត់អោយទេ អានេះ អត់អោយទេ អានេះក៏ អត់អោយដែរ*(ធ្វើកាយវិការប្រាប់)* កាលណានឹកឃើញឡើងខឹង អានេះក៏អត់ដែរ អានេះក៏អត់ដែរ ខោអាវរហែក។ គាត់*(ប្តី)*មេម៉ាយ ពោះម៉ាយកូន៥ ខ្ញុំនៅលីវអាយុក្រៃលដែរហើយកាល នោះណាំនៅក្រមុំណាំ ខ្ញុំនៅក្រមុំទេ។ ខ្ញុំអត់ដឹងថាគេចង់រៀបការជាមួយខ្ញុំទេ គេមេៗគេចាប់យើងទេ គេចាប់យើងទេ គេស្រលាញ់ខ្លួនគេ គេចាប់យើងទៅរៀបការ ប្រុសត្រូវចិត្តយើង យើងអត់ត្រូវ បើយើងស្រលាញ់ គេរៀបអោយតែមួយគូទេ យើងអត់ត្រូវទេ គេចាប់ពាគូមួយសារណឹង គេបង្ខំយើង។ ខ្ញុំបានរួមដំណេកហើយ បានជាមានកូន

បើមិនបានរួមទេ គេតាមដាន គេមកតាមស្តាប់ ណាំ។ គេមកស្តាប់ ខ្ញុំប្រឆាំងជាមួយគេពាយប់ ប្រឆាំងពាយប់ស្រាប់តែគេតាម គេតាមទៅ គេហៅគ្រួសារប្រុសហើងយកទៅព្រមានយកទៅកសាង គេថា ម៉េចប្តីប្រពន្ធដែលរៀបហើយ គ្រួសារដែលរៀបហើយ ពួថាអត់ចុះដំណេក។ ខ្ញុំអត់ចុះ ដល់ខ្ញុំអត់ចុះ ប្តីខ្ញុំគេយកទៅ ដល់ពេលយកទៅណែនាំទៅ គេថាបើគ្រួសារមិនចុះ ដំណេកពីត្រឹមថ្ងៃនេះទេ គេដកយក ហើយគេយក ទៅហើយ គេយកទៅសំលាប់ចោលហើយ បានជាខ្ញុំបានរួមរ័ក្សនឹងប្តីទៅ។ គាត់(ប្តី) ប្រាប់ថាកុំអោយប្រឆាំង ចឹងទៀតព្រោះអីគេប្រុងយកទៅសំលាប់ កាលណាគេសំលាប់ខ្ញុំទៅ គាត់ក៏មិនបានសុខដែរ។ បើមិនរួមអត់សុខទេត្រូវស្លាប់។ ខ្ញុំអត់ចង់បានប្តីទេ ឃើញលំបាកណាស់ ខ្ញុំយំច្រើនណាស់ណាំ ខ្ញុំយំស្រក់ទឹកភ្នែកភ្លុក១ ហើយប្រធាន កងគេមួលចេះនែ កុំអោយយំខ្លាចគេឃើញប្រយ័ត្នងាប់ ’ ។

*នាងសុឃុន*

សុឃុន ជាប្រជាជនថ្មីម្នាក់។ ប្តីនាងត្រូវបានគេយកទៅកសាងក្នុងឆ្នាំ១៩៧៥ ហើយ នាងលែងបានឃើញរហូតមក។ តាំងឆ្នាំ១៩៧៧ ប្រធានបានសុំរៀបការជាមួយនាងជាញឹកញាប់ តែនាងខិតខំទប់ស្កាត់មិនរៀបការជាមួយ ដោយហេតុផលថាប្តីនាងនៅរស់នៅឡើយ គេបានប្រាប់នាងថា គេយកប្តីនាងទៅកសាង។ មនុស្សដែលចង់រៀបការជាមួយនាងគឺជាចុងភៅ។ គាត់បំរើ ប្រធានបានល្អណាស់ ហើយគាត់បានឃើញនាងនៅពេលប្រពន្ធគាត់ជិតស្លាប់ក្នុងមន្ទីរពេទ្យមួយ។ ‘ប្រធាននិយាយមកខ្ញុំថា "អ្នក ឯងត្រូវតែបង្កើតគ្រួសារឱ្យអង្គការ" ។ ពិធីរៀបការចាប់ផ្តើមនៅ ម៉ោង៨ល្ងាច ដោយកងឈ្លបព័ទ្ធជុំវិញ។ ខ្ញុំភ័យតក់ ស្លុត ហើយពិបាកព្រោះយើងមិនដែលស្គាល់គ្នា។ ព្រឹកស្អែកឡើង ប្តីខ្ញុំនិយាយថាគាត់បារម្ភខ្លាចអង្គការបញ្ជូន ខ្ញុំទៅឆ្ងាយព្រោះខ្ញុំមិនព្រមគេងជាមួយគាត់...ខ្ញុំក៏ព្រួយបារម្ភដែរ ហើយអាណិតគាត់ទៀត

ព្រោះគាត់សុភាព ដូច្នេះនៅទី បញ្ចប់ ខ្ញុំក៏យល់ ព្រម...ខ្ញុំគេងជាមួយគាត់នៅយប់ទីបី' ។ នៅពេលកងទ័ពវៀតណាមចូលកម្ពុជា នាងសុឃុន នៅក្នុងមន្ទីរពេទ្យ ហើយប្តីនាងមិន ស្តាប់បញ្ជាការជន្លាសទៅប្រទេសថៃ ហើយក៏ត្រឡប់មករកនាងវិញ។

*នាងធីតា*

ធីតាពន្យល់ថាបុរសខ្លះ ដែលពិការក្នុងពេលប្រយុទ្ធគ្នា ក៏មានសិទ្ធិជ្រើសរើសប្រពន្ធដោយឱ្យអង្គការរៀបការឱ្យ។

ប្តីរបស់ខ្ញុំជាជនពិការ គាត់ដាច់ជើងជំនាន់យើង៧៦។ ពិការគេជំរុញគាត់ទៅធ្វើការនៅ.. លើកទំនប់ ជីកប្រឡាយ កំពង់ចាមទទួលដើរជាន់មីន។ ខ្ញុំអត់ដឹងពីមូលហេតុដែលគេចង់អោយខ្ញុំរៀបការជាមួយគាត់ដែរ តែគ្រាន់ថាគាត់នេះ គាត់ថាគេអ្នកធំ ឃុំស្រុកអីចឹង គេថាឥឡូវអោយគាត់យកប្រពន្ធទៅណា៎ យកប្រពន្ធចឹងទៅក៏គេអោយគាត់ដើរជ្រើស រើស តើចិត្តគាត់ស្រលាញ់អ្នកណា អោយគាត់ដើររើសដល់ពេលណឹងទៅក៏ម៉ោ ដូចថាសំឡឹងឃើញដូចថា ម៉ោចល័តទាំងអស់ ឃើញថាខ្ញុំចឹងណា៎អាចថាចិត្តបានគាំទ្រគាត់ ចឹងទៅ គាត់ស្នើឃុំស្រុកគេណឹងទៅ តែយើងអត់ដឹងទេ យើងអត់ ដឹងថាគេណឹងគេសុំយើងរៀបការឬមួយ អីយើងអត់មានដឹងសោះ។ គេអោយសិទ្ធិគាត់ជ្រើសរើសប្រពន្ធព្រោះគាត់ពិការ។ គាត់ពិការក្នុងអំឡុងប៉ុលពតប្រើទៅ។ គេបង្ខំ វាថាបើសិនជាយើងមិនរៀបការជាមួយជនពិការ យើងជៀសវានៅក្នុងប្រទេសកម្ពុជាមិនបានទេ ត្រូវតែស្លាប់តែចឹង។ បើមិនយកគេ សំលាប់យើង។ នៅពេលទទួលដំណឹងមួយថ្ងៃមុនអំពីការរៀបការនេះ ខ្ញុំក្រៀមក្រំណាស់ តែពួកវាគំរាមកំហែងខ្ញុំ ហើយខ្ញុំនឹងត្រូវគេ សំលាប់មិនខាន បើខ្ញុំមិនយល់ព្រម' ។

*លោកវណ្ណៈ*

វណ្ណៈបានឃើញគេរំលោភស្ត្រីម្នាក់ ដែលមិនព្រមរៀបការជាមួយមេបញ្ជាការយោធាម្នាក់។ វណ្ណៈជាកងការពារពិសេស សំរាប់មេបញ្ជាការនោះ។

អ្នកផ្តល់ពត៌មាន និយាយថា មេបញ្ជាការនោះបានព្យាយាមចែចង់ស្ត្រីនោះតែនាងនោះមិនព្រមព្រោះ ខ្លាចទទួលទណ្ឌកម្មពីបទខុសសីលធម៌។ មេបញ្ជាការនោះបានស្នើឱ្យស្ត្រីនោះមកកាន់ការិយាល័យ ហើយអ្នកផ្តល់ព័ត៌មានអាចឃើញ និងឮការសន្ទនាគ្នារវាងមេបញ្ជាការ និង នារីនោះ នៅពេលគាត់ឈរយាម ព្រោះមាត់បង្អួចបើក។ មិត្តឯងគួរតែយកគ្រួសារទៅ ព្រោះសម័យអង្គការរៀបចំអោយ ប្រសិនជាស្ត្រីឯងព្រមព្រៀង រៀបចំនឹងខ្ញុំទៅ។ នារីហ្នឹងបានបញ្ជាក់ហេតុផលថា ខ្ញុំមិនទាន់យកទេ ហើយខ្ញុំវានៅវ័យក្មេងផង ហើយម្យ៉ាងម្តាយឪពុកនៅឆ្ងាយ។ គាត់និយាយថា ស្ត្រីនេះ ប្រសិនបើដោយខ្ញុំទៅ ព្រមព្រៀងនឹងខ្ញុំនោះ ខ្ញុំអោយស្ត្រីឯងរស់ស្រួលហើយមិនអាចទៅលី ទៅសែងអីធំធ្ងន់ៗទេ។ ដល់អញ្ចឹងនាងអត់តដែរ បាត់មាត់ទៅតែមើលទៅគ្នាវា ភ័យតត់ស្លុតគ្នា នាងហ្នឹងចេះតែងាក មើលចុះមើលឡើង គ្នាវាប្រុងស្រែកអីមិនដឹង ឬក៏យ៉ាងម៉េច គ្នាមិនហ៊ាន។ ពេលនោះមេបញ្ជាការក៏រំលោភនាង។ ១០ថ្ងៃក្រោយមក នាងនោះក៏បាត់ខ្លួន ហើយគាត់គិតថាច្បាស់ ជាស្លាប់ហើយ។ សន្មត់ថា មេបញ្ជាការ នោះអាចឱ្យអង្គការរៀបការឱ្យតាមសំណើរបស់ខ្លួន។

## ខ. សេចក្តីសន្និដ្ឋាន

នយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ នាំឱ្យមានអំពើហិង្សាផ្លូវភេទថែមទៀត។ ក្នុងករណីខ្លះ ខ្មែរក្រហមប្រព្រឹត្តអំពើហិង្សាផ្លូវភេទ ដើម្បីបង្ខំឱ្យស្ត្រីរៀបការហើយដាក់ទណ្ឌកម្មចំពោះអ្នកដែលមិនព្រម។ ពេលរៀបការរួចហើយ ខ្មែរក្រហមនៅតែបន្តជ្រៀតជ្រែកតទៅទៀត។ បំណងចំបងនៃអាពាហ៍ពិពាហ៍ទាំងនេះគឺធានា

ឱ្យមានការបន្តពូជ។ ការបង្ខំរួមដំណេកជាផ្នែកចាំបាច់នៃអាពាហ៍ពិពាហ៍។ សូម្បីតែអ្នកមិនធ្លាប់ឆ្លងកាត់អំពើហិង្សាផ្ទាល់ក៏មានការគាបសង្កត់ឱ្យរួមដំណេកជាមួយគូស្រករថ្មី ដោយគេជឿថា ពួកខ្មែរក្រហមកំពុងតាមដានខ្លួន ហើយដឹងថាមានអ្វីកើតឡើងចំពោះអ្នកមិនព្រម។ ក្នុងករណីខ្លះ នយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំគឺធ្វើឱ្យការរំលោភស្របច្បាប់។ នៅពេលនយោបាយរដ្ឋាភិបាលហាមឃាត់មិនឱ្យមានការរួមភេទមិនមានការយល់ព្រមក្រៅអាពាហ៍ពិពាហ៍ ពេលរៀបការហើយ ការរួមភេទទាំងអស់ត្រូវចាត់ទុកថាជាការយល់ព្រម។ អ្នកដែលខ្មែរក្រហមអនុញ្ញាតជ្រើសរើសប្រពន្ធអាចធ្វើសកម្មភាពផ្លូវ ភេទដោយមិនចាំបាច់មានការយល់ព្រម ដោយមូលហេតុថានឹងរៀបការ។

## VI. ឱកាសសំរាប់ការផ្តន្ទាទោស

នៅ២០០៧ សាលាជំរះក្តីពិសេសនៃតុលាការកម្ពុជានឹងចាប់ផ្តើមធ្វើការចោទប្រកាន់ទោសចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម។ការចោទប្រកាន់ទោសលើអំពើហិង្សាផ្លូវភេទនឹងទទួលស្គាល់ពីការឈឺចាប់ ដែលបទឧក្រិដ្ឋទាំងនេះបានកើតឡើងមកលើប្រជាជនកម្ពុជា។ វាជាការបញ្ជូនសារច្បាស់លាស់មួយទៅកាន់តុលាការវិសាមញ្ញកម្ពុជា និង ប្រជាជនកម្ពុជាថា បទឧក្រិដ្ឋធ្ងន់ធ្ងរទាំងនេះត្រូវយកមកកាត់ទោស។ តែឱកាសកាត់ទោសបទល្មើសហិង្សាផ្លូវភេទ ត្រូវកំរិតដោយការប្រើពាក្យពេជន៍នៃច្បាប់ស្តីពីការបង្កើតសាលាជំរះក្តីពិសេសក្នុងតុលាការខ្មែរ ដើម្បីកាត់សេចក្តីបទឧក្រិដ្ឋដែលកើតមានក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

### ក. តើគេកាត់ទោសនរណាខ្លះ?

ច្បាប់បង្កើតសាលាជំរះក្តីនេះបានចែងយ៉ាងជាក់លាក់ថា មានតែមេដឹកនាំកំពូល និង អ្នកដែលទទួលខុសត្រូវខ្លាំងជាងគេបំផុតអាចយកមកកាត់ទោសក្នុង

តុលាការនេះបាន។ ភស្តុតាងដែលប្រមូលបានក្នុងរបាយការណ៍នេះ មិនបានបង្ហាញថា អ្នកដែលត្រូវចាត់ទុកថា ជាមេដឹកនាំកំពូលទទួលខុសត្រូវផ្ទាល់ពីបទអំពើហិង្សាផ្លូវភេទទេ តែពួកគេអាចទទួលខុសត្រូវតាមរយៈទ្រឹស្តីនៃការទទួលខុសត្រូវរបស់ប្រធាន ដែលនឹងពិភាក្សាខាងក្រោមនេះ។ ក៏ប៉ុន្តែការពិភាក្សាក្នុងរយៈពេលព្រាងច្បាប់អំពីការបង្កើតសាលាជំរះក្តីនេះបាន និយាយច្បាស់ថា ការបញ្ចូលពាក្យ 'អ្នកទទួលខុសត្រូវបំផុត' តែដើម្បី ធានាថាប្រធានគុក ឈ្មោះ ឌុច (កាំង ហ្គិច អៀវ) អាចយកមកកាត់ទោសពីបទឧក្រិដ្ឋប្រព្រឹត្តក្នុងគុក ស-២១។ មិនមានចេតនាដាក់បញ្ចូលមនុស្សដទៃទៀត ដែលអាចជាអ្នកទទួលខុសត្រូវបំផុត តែមិនមែនកាន់ជាតំណែងថ្នាក់ដឹកនាំកំពូលទេ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាទំនងជាចោទប្រកាន់ទោសលើមនុស្សមួយចំនួនតូចប៉ុណ្ណោះ។

អ្នកដែលត្រូវកាត់ទោសនៅសាលាក្តីពិសេសនេះ គឺត្រូវតែកាត់ទោសនូវបទល្មើសដែលមានចែងក្នុងច្បាប់បង្កើតសាលាក្តីនេះ។ បន្ថែមលើការបង្ហាញថាមានបទល្មើសកើតឡើងសហព្រះរាជអាជ្ញាក៏ត្រូវបង្ហាញថា អ្នកដែលត្រូវបានចោទប្រកាន់នោះ ជាអ្នកទទួលខុសត្រូវលើបទល្មើសនោះ។

## ខ. បទឧក្រិដ្ឋ

ច្បាប់សាលាក្តីពិសេសអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ទោសបានតែចំពោះបទល្មើសមួយចំនួនប៉ុណ្ណោះ ក្នុងនោះមានការធ្វើទារុណកម្ម អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ និង ការល្មើសដ៏ធ្ងន់ធ្ងរលើអនុសញ្ញាក្រុងសឺណែវឆ្នាំ១៩៤៩។ ច្បាប់នេះមិនបានរៀបរាប់ពីការចាប់រំលោភអំពើហិង្សាផ្លូវភេទ និង អាពាហ៍ពិពាហ៍ដោយបង្ខំ ជាបទល្មើសដាច់ដោយឡែកទេ។ អំពើហិង្សា ផ្លូវភេទបានលើកឡើងជាក់លាក់តែក្នុងមាត្រាស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តែវាអាច

មានក្នុងនិយមន័យនៃអំពើអមនុស្សធម៌ និង ការធ្វើទារុណកម្មដទៃទៀត ដែលមានក្នុងផ្នែកនានានៃច្បាប់នេះ។ សហព្រះរាជអាជ្ញាក៏ ត្រូវបង្ហាញថាចន្លោះ ឆ្នាំ១៩៧៥ ដល់ ១៩៧៩ នៅពេលដែលបទល្មើសនេះកើតឡើង ហើយវាជាអំពើខុសច្បាប់។ គេហៅឱ្យឈ្មោះថា គោលការណ៍នីត្យានុកូល ហើយមានបំណងធានាថាមិនកាត់ទោសមនុស្ស ដែលបានប្រព្រឹត្តបទល្មើសក្រៅរយៈពេលនេះ។ ជនដែលបានប្រព្រឹត្តអំពើនោះត្រូវអាចដឹង (បើទោះជាពួកគេពិតជាមិនបានដឹង) ថាទង្វើរបស់ខ្លួនជាអំពើល្មើស។

## គ. បង្ហាញពីការទទួលខុសត្រូវ

បន្ថែមលើការបង្ហាញដែលថា ជនបានប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់សាលាក្តីនោះ សហព្រះរាជអាជ្ញាក៏ត្រូវបង្ហាញជននោះ ទទួលខុសត្រូវជាបុគ្គលផងដែរ។ ក្នុងសាលាក្តីនេះ គេអាចទទួលខុសត្រូវដោយផ្ទាល់ ឬទទួលខុសត្រូវតាមរយៈទ្រឹស្តីនៃច្បាប់ហៅថា ការទទួលខុសត្រូវរបស់ប្រធាន។

*១- ការទទួលខុសត្រូវផ្ទាល់*

សាលាក្តីពិសេសនេះអាចឃុំខ្លួនជនសង្ស័យណាមួយ ដែលទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល បើសិនជននោះមានគំរោង ការញុះញង់ បញ្ជា ជួយ និង ផ្សំគំនិត ឬ ប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងច្បាប់សាលាក្តីនេះ។ ឧទាហរណ៍ តាមទ្រឹស្តីនៃការទទួលខុសត្រូវនេះ សហព្រះរាជអាជ្ញាអាចបង្ហាញថា ជនជាប់ចោទនោះទទួលខុសត្រូវចំពោះការរៀបចំផែនការនយោបាយរំលោភអ្នកទោសស្រី ដើម្បីបានចំលើយសារភាព។

*២- ការទទួលខុសត្រូវរបស់ប្រធាន*

ទ្រឹស្តីច្បាប់ស្តីពីការទទួលខុសត្រូវរបស់ប្រធានមានន័យថា សាលាក្តីនេះអាចឃុំខ្លួនមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តដោយមន្ត្រីថ្នាក់ក្រោម។ ប៉ុន្តែដើម្បីធ្វើបែបនេះ បានសហព្រះរាជអាជ្ញាត្រូវតែបង្ហាញពីធាតុផ្សំចំនួន៣គឺ:

ក- ប្រធានមានអំណាចបញ្ជា ឬអំណាចគ្រប់គ្រងជាក់ស្តែងលើបុគ្គលិក ឬអាជ្ញាធរ និង អំណាចគ្រប់គ្រងលើបុគ្គលិក

ខ- ប្រធានបានដឹង ឬមានហេតុផលនឹងដឹងថា បុគ្គលិករបស់ខ្លួនរៀប នឹងធ្វើ ឬបានធ្វើអំពើនោះមែន

គ- ប្រធានខកខានមិនបានចាត់វិធានការណ៍ចាំបាច់សមរម្យណាមួយ ដើម្បីទប់ស្កាត់អំពើទាំងនោះ ឬដើម្បីដាក់ទោសជនដែលបានប្រព្រឹត្តបទល្មើសនោះ។

ដូច្នេះ ប្រធានមិនពាក់ព័ន្ធផ្ទាល់ក្នុងអំពើល្មើសនោះទេ តែពាក់ព័ន្ធដោយប្រយោល។ ការទទួលខុសត្រូវមានចំពោះប្រធានដែលខកខានមិនបានចាត់ការនៅពេលដែលខ្លួន បានដឹង ឬគប្បីដឹងថាបុគ្គលិករបស់ខ្លួនបានប្រព្រឹត្តអំពើណាមួយ។

## ឃ- ឧទាហរណ៍គំរូមួយ-ការរំលោភជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

ការពិចារណានូវលទ្ធភាពកាត់ទោសអំពើរំលោភជាបទល្មើសប្រឆាំងមនុស្សជាតិអាចជួយបង្ហាញការស្មុគស្មាញ និង ការលំបាកនានា ដែលសហព្រះរាជអាជ្ញានឹងប្រឈមមុខ ក្នុងការចោទប្រកាន់ទោសចំពោះអំពើហិង្សាផ្លូវភេទ។

បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិពាក់ព័ន្ធនឹងការប្រព្រឹត្ត អំពើជាក់លាក់ណាមួយប្រឆាំងនឹងជនស៊ីវិលដូចជា: ការធ្វើទារុណកម្ម ការរំលោភ និង អំពើអមនុស្សធមិដទៃទៀត។ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញថា ការរំលោភមួយកើតមាន

ហើយថា ការរំលោភនោះត្រូវតែស្ថិតក្នុងនិយមន័យនៃអំពើរំលោភរវាងឆ្នាំ ១៩៧៥ និង ១៩៧៩។ ការកំណត់និយមន័យនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិក៏ទាមទារថា ការរំលោភជាផ្នែកមួយនៃការវាយប្រហារបែបរាលដាល ឬតាមប្រព័ន្ធច្បាស់លាស់ ហើយថា ការវាយប្រហារនោះ សំដៅទៅលើជនស៊ីវិលដោយមូលហេតុសញ្ជាតិ នយោបាយ ជនជាតិ ពូជសាសន៍ ឬ សាសនា។ វាច្បាស់ណាស់ដែលថា ការរំលោភ និង អំពើហិង្សាផ្លូវភេទធ្វើឡើងប្រឆាំងមនុស្សដោយមូលហេតុនយោបាយ គឺអ្នកណា ដែលមិនគាំទ្របដិវត្តន៍តែងតែទទួលនូវការវាយរឺធ្វើបាប។

សហព្រះរាជអាជ្ញាក៏ត្រូវតែបង្ហាញថា អ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវបំផុត អោយទទួលខុសត្រូវចំពោះអំពើរំលោភនោះ។ វាអាចនឹងមានការពិបាកចំពោះបង្ហាញថា ពួកគេទទួលខុសត្រូវផ្ទាល់ ព្រោះមានភស្តុតាងច្បាស់លាស់បង្ហាញថា ពួកគេមានគោលនយោបាយមួយប្រឆាំងនឹងទំនាក់ទំនងស្នេហាក្រៅអាពាហ៍ពិពាហ៍ រួមទាំងទំនាក់ទំនងស្នេហាដែលមិនមានការព្រមព្រៀង។ តែព្រះរាជអាជ្ញាអាចបង្ហាញថា អ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវបំផុតបានដឹង ឬគប្បីដឹងអំពីអំពើហិង្សាផ្លូវភេទ ហើយមិនបានបញ្ឈប់ ឬដាក់ទោសចំពោះទង្វើនោះ ដូច្នេះហើយទទួលខុសត្រូវតាមរយៈទ្រឹស្តីនៃការទទួលខុសត្រូវរបស់ប្រធាន។ តែសម្ភាសិតជាច្រើនជឿថា មាននយោបាយប្រឆាំងនឹងការរំលោភ ហើយថានៅពេលប្រធាន ឬថ្នាក់លើរកឃើញថាមានការរំលោភ ពួកគេនឹងដាក់ទោសជនល្មើសដោយដាក់គុក ឬសំលាប់។

## ខ. សេចក្តីសន្និដ្ឋាន

មានបញ្ហាប្រឈមមុខខាងផ្លូវច្បាប់មួយចំនួន ដែលសហព្រះរាជអាជ្ញានឹងជួបប្រទះក្នុងកាចោទប្រកាន់អំពើហិង្សាផ្លូវភេទ។ សហព្រះរាជអាជ្ញាត្រូវបង្ហាញថា

អ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវបំផុត បានប្រព្រឹត្តបទល្មើសដែលបានកំណត់ក្នុងច្បាប់សាលាក្ដីនេះ ហើយត្រូវតែបង្ហាញផងដែរថា ជនជាប់ចោទត្រូវតែទទួលខុសត្រូវចំពោះបទល្មើសនោះ។ អាចមានការចោទប្រកាន់ទោសផ្សេងៗគ្នាជាច្រើន ហើយការចោទប្រកាន់និមួយៗមានភាពស្មុគស្មាញ និង ការលំបាកដ៏ខ្លាំងក្លា។ នៅពេលសហព្រះរាជអាជ្ញាមានសេចក្ដីក្លាហាន ធ្វើការស៊ើបអង្កេតបទល្មើសទាំងនោះ ពេញលេញប្រមូលភស្តុតាង និង អភិវឌ្ឍន៍ទ្រឹស្ដីចោទប្រកាន់ទោសនោះវាពិតជាថា ពួកគេនឹងអាចធ្វើការចោទប្រកាន់ទោស ចំពោះអំពើហិង្សាផ្លូវភេទក្នុងតុលាការនេះ ដោយជោគជ័យ។

## ច. *សំដៅដល់អំពើហិង្សាខាងផ្លូវភេទ*

សហព្រះរាជអាជ្ញាមិនអាចរកភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់ អ្នកដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវបំផុត ចំពោះអំពើហិង្សាផ្លូវភេទ ព្រះរាជអាជ្ញា នៅអាចទទួលស្គាល់ភស្តុតាងនៃបទល្មើសទាំងនេះបាន។ ឧទាហរណ៍ក្នុងរឿងក្ដី Kayishema និង Ruzindana ក្នុងសាលាឧក្រិដ្ឋអន្តរជាតិសំរាប់ប្រទេសរ៉ាវ៉ាន់ដា សហព្រះរាជអាជ្ញាមិនអាចចោទប្រកាន់ទោសចុងចោទអំពី អំពើហិង្សាផ្លូវភេទ។ តែក្នុងសាលក្រមតុលាការបានពិភាក្សាអំពើឃោឃៅរមួយចំនួន ហើយបានធ្វើសេចក្ដីសំអាងមួយចំនួនចំពោះការរំលោភ និង ផលវិបាកនៃអំពើហិង្សាផ្លូវភេទ។ បើទោះជាសហព្រះរាជអាជ្ញាមិនបានចោទប្រកាន់ចុងចោទជាក់លាក់លើបទល្មើសទាំងនេះ ក៏ពួកគេអាចធ្វើជាផ្នែកមួយនៃសាលក្រមរបស់សាលាក្ដីនេះបានដែរ។ ការបញ្ចូលក្នុងសាលក្រមតុលាការនេះ មានន័យថាអំពើហិង្សាផ្លូវភេទអាចបង្កើតជាផ្នែកមួយនៃកំណត់ហេតុជាប្រវត្តិសាស្ត្រ។ បណ្ដាញពត៌មាន និង អ្នកតាមដានសាលាក្ដីនេះអាចរាយការណ៍ខ្លឹមសារនៃសាលក្រមបាន ដើម្បីឱ្យប្រជាជនកម្ពុជា

ដឹងថា សាលាក្ដីនេះបានទទួលស្គាល់ថា អំពើហិង្សាផ្លូវភេទគឺជាអំពើឃោរឃៅមួយ ដែលកើតមាន ក្នុងរបបខ្មែរក្រហម។

## VII. អង្គការមិនមែនរដ្ឋាភិបាល យេនឌ័រ និង សាលាក្ដីពិសេស

អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកសិក្សាធិការ និង ប្រទេសម្ចាស់ជំនួយ អាចក្បៀបសង្កត់សាលាក្ដីនេះឱ្យធានាថា អំពើហិង្សាផ្លូវភេទត្រូវបានទទួលស្គាល់ ហើយថា សាលាក្ដីនេះបានគិតគូដល់ជនរងគ្រោះដោយត្រឹមត្រូវ។ បើទោះជាសហព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ជាពិសេសចំពោះអំពើហិង្សាផ្លូវភេទ ក៏ចំណាប់អារម្មណ៍លើអំពើហិង្សាផ្លូវភេទនៅតែពាក់ព័ន្ធ ព្រោះសាក្សីដែលបានផ្ដល់ភស្ដុតាងដើម្បីគោលបំណងផ្សេងណាមួយ អាចធ្លាប់ឆ្លងកាត់អំពើហិង្សាផ្លូវភេទនេះ។ ឧទាហរណ៍ ក្នុងសាលាឧក្រិដ្ឋអន្តរជាតិសំរាប់ប្រទេសរ៉ាវ៉ាន់ដា គេបានកោះហៅសាក្សីម្នាក់ឱ្យផ្ដល់ភស្ដុតាង ហើយពេលនោះក៏បានបង្ហាញ កសិណសាក្សីថា គាត់បានឃើញគេរំលោភកូនស្រីគាត់ ដោយកងជីវពលក្នុងអំពើប្រល័យពូជសាសន៍នៅរ៉ាវ៉ាន់ដា។ ការធ្វើអន្តរគមអាចមានដោយធានាឱ្យជនរងគ្រោះ និងសាក្សីបានចូលរួមក្នុងដំណើរការនៃសាលាក្ដីនេះ ដោយមានការការពារជនរងគ្រោះ និង សាក្សី ហើយដោយធ្វើការតាមដានការប្រតិបត្តិរបស់តុលាការ ចំពោះជនរងគ្រោះ និង សាក្សី។

ជនរងគ្រោះក្នុងរបបខ្មែរក្រហមនឹងមិនមានអារម្មណ៍ថា យុត្តិធម៌មិនមែនកើតឡើងដោយសារតែមានការចោទប្រកាន់ទោសប៉ុណ្ណោះទេ តែវាបានសំរេចឡើងដោយសារដំណើរការក្ដីទាំងមូលផងដែរ។ ជាញឹកញាប់ណាស់ក្នុងដំណើររឿងក្ដីផ្លូវច្បាប់ទាំងតុលាការជាតិ ទាំងអន្តរជាតិចាត់ទុកជនរងគ្រោះជាមធ្យោបាយមួយ ដើម្បីឈានដល់ការចោទប្រកាន់ទោស។ មានសាក្សី ម្នាក់បានបង្ហាញកសិណសាក្សីនៅក្នុងសាលាឧក្រិដ្ឋអន្តរជាតិសំរាប់ប្រទេសរ៉ាវ៉ាន់ដា និយាយថា: ‘ពេលពួកគេត្រូវការយើង

ពួកគេថ្នាក់ថ្នមយើងដូចពងមាន់ ហើយនៅពេលពួកគេប្រើយើងចប់ ពួកគេត្រវែង យើងចូលធុងសំរាម' ។ សាក្សីដែលចូលរួមក្នុងការស៊ើបអង្កេត ឬបង្ហាញភស្តុតាង ចំពោះ មុខសាលាក្តីនេះ ត្រូវតែចូលរួមក្នុងដំណើរការទាំងមូល។ ការធ្វើបែបនេះ ដើម្បីបញ្ជាក់ថា ពួកគេទទួលព័ត៌មានពេញលេញអំពីតួនាទីរបស់ខ្លួន ដើម្បីផ្តល់សេវា គាំទ្រ ផ្នែកចិត្តសាស្ត្រ និង ដើម្បីឱ្យពួកគេដឹងពីការរីកលូតលាស់ និង លទ្ធផលនៃការ កាត់ក្តីដែលពួកគេបានចូលរួមផងដែរ។

សាលាក្តីនេះត្រូវការពារជនរងគ្រោះ និង សាក្សីឱ្យបានសមរម្យ។ ជនរង គ្រោះ និង សាក្សីនៃអំពើហិង្សាផ្លូវភេទ គឺគ្រាន់តែបង្ហាញជាកសិណសាក្សី ហើយគប្បី លើកទឹកចិត្តឱ្យធ្វើបែបនេះ បើសិនជាសាលាក្តីនេះផ្តល់ការការពារគ្រប់គ្រាន់ដល់ពួក គាត់ ។ ជនរងគ្រោះណាដែលបង្ហាញជាកសិណសាក្សីក្នុងតុលាការ អាចមានការ ព្រួយបារម្ភជាច្រើន ដូចជា: ភ័យខ្លាចការសង សឹករបស់ជនល្មើស គ្រួសារជនល្មើស ការខ្មាស់អៀន និង ការភ័យខ្លាចសហគមន៍មានប្រតិកម្មចំពោះការបង្ហាញកសិណ សាក្សីរបស់ខ្លួន។ សាក្សីក៏អាចបាត់ការចងចាំនូវអ្វីដែលកើតមានចំពោះខ្លួន ហើយការ ដែលខំរំលឹកឡើងវិញអាចធ្វើឱ្យមានការឈឺ ចាប់ថែមទៀត និង ការរំខានដល់ជីវិត រស់នៅរបស់ពួកគាត់។

ការការពារដល់ជនរងគ្រោះក្នុងសាលាក្តីនេះមានតិចតួច តែវិធានដែលធ្វើ ដោយចៅក្រមនេះអាចបំពេញចំនុចខ្វះខាតទាំងនោះបាន។ កិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ទាក់ទងនឹងសាលាក្តីនេះចែងថា:

សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង សាលាក្តីពិសេសត្រូវតែ ផ្តល់ឱ្យមានការការពារដល់ជនរងគ្រោះ និង សាក្សី។ វិធានការណ៍ការពារនេះត្រូវ រាប់បញ្ចូលដោយមិនមានកំរិត នូវដំណើការសវនាការដែលមានការបង្កប់ម៉ាស៊ីន ថតរូប និង ការការពារអត្តសញ្ញាណជនរងគ្រោះ ឬសាក្សី។

នៅឯគណៈកម្មការផ្សះផ្សា និង សច្ចៈធម៌សំរាប់ប្រទេសសៀរ៉ាឡេអូន ស្ត្រីដែលនិយាយអំពីអំពើហិង្សាផ្លូវភេទ ទទួលបានជំរើស៣គឺៈ បង្ហាញភស្តុតាងតាមម៉ាស៊ីនថត (សវនាការបិទជិតដែលហាមឃាត់មិនឱ្យសាធារណជនចូលស្តាប់) និយាយក្នុងសវនាការសាធារណៈតែនៅខាងក្រោយវាំងនន ឬនិយាយចំពោះមុខសាធារណជនដែលចូលរួមស្តាប់សវនាការដោយមិនមាន វិធានការណ៍ការពារអត្តសញ្ញាណរបស់ខ្លួន។ ជំរើសទាំងនេះ អាចឱ្យជនរងគ្រោះដោយការរំលោភជ្រើសរើសរបៀបបង្ហាញភស្តុតាងជាសាធារណៈ ឬជាឯកជន ដែលជាការពិចារណាដ៏សំខាន់មួយចំពោះស្លាកស្នាមទុរយសមានចំពោះជនរងគ្រោះ ដោយការរំលោភ។

កិច្ចព្រមព្រៀងនេះក៏បានលើកឡើងផងដែរថា រដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវផ្នែកការពារ និង សន្តិសុខដល់ជនរងគ្រោះ និង សាក្សី។ សាលាក្តី និង រដ្ឋាភិបាលកម្ពុជាអាចផ្តល់ការការពារគ្រប់គ្រាន់បាន តែបទពិសោធន៍ក្នុងសាលាក្តីអន្តរជាតិ និង ចំរុះសំណូមពរថាពួកគេត្រូវការជំនួយ។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលអាចដើរតួនាទីសកម្មក្នុងការគាំទ្រ និង ការពារ សាក្សីដែលជាជនរងគ្រោះពីបទល្មើសនានារួមទាំងអំពើហិង្សាផ្លូវភេទ ដោយធានាថា សាលាក្តីនេះគិតគូយ៉ាងយកចិត្តទុកដាក់ដល់អ្នកទាំងឡាយណា ដែលរាយការណ៍ពីបទល្មើស និង ការពារសិទ្ធិ និង សន្តិសុខរបស់ពួកគាត់។

បទពិសោធន៍ក្នុងតុលាការកម្ពុជាបង្ហាញថា សមាជិកភាគច្រើននៃតុលាការ និង គណៈមេធាវីមានការយល់ដឹងតិចតួចអំពីបញ្ហាយេនឌ័រ។ តុលាការកម្ពុជាតែងបកស្រាយខុសពីតំរូវការផ្លូវច្បាប់ចំពោះបទរំលោភ ឧទាហរណ៍ ទាមទារឱ្យមានការប្រព្រឹត្តទៅជ្រៅ ហើយបាត់បង់ព្រហ្មចារីសំរាប់ដាក់ទោសអំពើរំលោភ តែច្បាប់មិនរាប់បញ្ចូលសេចក្តីត្រូវការនេះទេ។ ពេលខ្លះចៅក្រមអនុញ្ញាតឱ្យមេធាវីការពារក្តីសាកសួរជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ អំពីដំណើររឿងមុនរួមភេទ។ ចៅ

ក្រុម និង មន្ត្រីតុលាការត្រូវការឱ្យមានការបណ្តុះបណ្តាលត្រឹមត្រូវស្តីពីការយល់ដឹងបញ្ហាផ្នែកយេនឌ័រ និងច្បាប់ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ ហើយអ្នកតាមដានជួយធានាឱ្យពួកគេគោរពតាមស្តង់ដារអន្តរជាតិដោយធ្វើការសង្កេត និង រាយការណ៍លើបញ្ហាយេនឌ័រ ក្នុងសវនាការ ។

ខាងក្រោមនេះ ជាសំណើអំពីរបៀប ដែលអង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ជំនួយជាក់ស្តែងដល់ជនរងគ្រោះនិង សាក្សី ដែលចូលរួមក្នុងសាលាក្តីនេះ ។

• ផ្តល់ព័ត៌មានលំអិត អំពីការស៊ើបអង្កេត និង ដំណើរការជំរះក្តីដល់ជនរងគ្រោះ និង សាក្សី ។ ជាទូទៅ ការរំពឹងទុក របស់ពួកគេមិនឆ្លើយតបនឹងការពិតទេ ហើយអ្នកតាមដានអាចជួយឱ្យពួកគាត់យល់ពីដំណើរការរបស់តុលាការ ។ បញ្ហានេះអាចបញ្ចូលព័ត៌មានអំពីការស៊ើបអង្កេត និង ដំណើរការជំនុំជំរះ ពេលវេលាកំណត់ច្បាស់លាស់ គ្រោះថ្នាក់ និង ការការពារ ដែលអាច ឬមិនអាចផ្តល់ឱ្យ ។

• អមដំណើរជនរងគ្រោះ និង សាក្សីទៅកាន់ការស៊ើបអង្កេត និង កាលបរិច្ឆេទរបស់តុលាការ ។ ចំណែកនៃអារម្មណ៍ តានតឹងក្នុងការផ្តល់ភស្តុតាងគឺការធ្វើដំណើរទៅកន្លែងមិនស្គាល់ និង ជួបមនុស្សមិនដែលស្គាល់ ហើយអង្គការអាចជួយបន្ថយ អារម្មណ៍ទាំងនេះបានដោយអមដំណើរជនរងគ្រោះ និង សាក្សី ។

• ដើរតួជាមនុស្សសំរាប់ទាក់ទង ដើម្បីជួយជនរងគ្រោះ ឬសាក្សីដែលភ័យខ្លាច ឬទទួលការគំរាមកំហែង ។ បើទោះជាអង្គការមិនអាចចាត់ការដោយខ្លួនឯងក៏អង្គការអាចទាក់ទងស្ថាប័នដែលអាចជួយបាន ។

• ទាក់ទងសេវាគាំទ្រផ្នែកចិត្តសាស្ត្រ បើមានការចាំបាច់ និង អាចរកបាន ។

• តាមដានការស៊ើបអង្កេត និង ដំណើរការតុលាការ ហើយរាយការណ៍ពីការរំលោភសិទ្ធិជនរងគ្រោះ និង សាក្សី ។

• ធានាឱ្យជនរងគ្រោះ ឬ សាក្សីមានសេចក្តីក្លាហាន ក្នុងការបង្ហាញភស្តុតាងអំពីបទពិសោធន៍ដ៏ឈឺចាប់ ។

• ទាក់ទងជនរងគ្រោះ ឬសាក្សីជានិច្ចបន្ទាប់ពីដំណើរការជំរះក្តីរួចដើម្បីជូនដំណឹងដល់ពួកគេអំពីការវិវត្តន៍ក្នុងការកាត់ក្តី និងផ្តល់ការគាំទ្រជាបន្ត ។

## VIII. ការអប់រំសាធារណជន

ដំណោះស្រាយនៅមានកំរិត ចំពោះការចោទប្រកាន់ទោសពីបទឧក្រិដ្ឋអាចផ្តល់ឱ្យ ។ គោលបំណងនៃការចោទប្រកាន់ទោសពីបទឧក្រិដ្ឋជាបឋមគឺ ដើម្បីស្វែងរកអ្នកទទួលខុសត្រូវជាបុគ្គលចំពោះអំពើជាក់លាក់ណាមួយ ។ នៅពេលឆ្លងកាត់ដំណើរការនេះ តុលាការបង្កើតឱ្យមានកំណត់ហេតុប្រវត្តិសាស្ត្រមួយ តែវាមិនមែនជាគោលបំណងចំបងទេ ។ សាលាក្តីពិសេសផ្តោតទៅលើរបៀបស៊ើបអង្កេតស្វែងរកយុត្តិធម៌ ដែលមានន័យថា ស្វែងរកសច្ចៈធម៌ ហើយ កំណត់ត្រាប្រវត្តិសាស្ត្រសំខាន់ជាងរបៀបស្វែងរកយុត្តិធម៌របស់សាលាជំរះក្តីអន្តរជាតិ និង ចំរុះ ដែលតែងមានលក្ខណៈវាទបដិវាទ ។ ទោះជាយ៉ាងណាក៏ដោយ ចំនួនជនរងគ្រោះ និង សាក្សី និងប្រធានបទដែលពួកគេអាចបង្ហាញភស្តុតាង នឹងមានកំរិតបំផុត ដើម្បីជាប្រយោជន៍នៃសវនាការដោះស្រាយវិវាទ ហើយដោយសារតែកំរិតព្រំដែនយុត្តាធិការរបស់សាលាក្តីដែលបានបង្ហាញខាងលើ ។

ហេតុដូច្នេះ សាលាក្តីតែមួយគត់មិនអាចរំពឹងថាបានដោះស្រាយឧក្រិដ្ឋកម្មដែលកើតមានក្នុងរបបខ្មែរក្រហមបានទាំងអស់ឡើយ ហើយសំខាន់ត្រូវពិចារណារកវិធីដំណោះស្រាយបន្ថែមទៀត ។ ការប្រកាសផ្សព្វផ្សាយ និង ប្រយោជន៍ដែលសាលាក្តីនេះបង្កើត ជាមួយសាធារណជន និង ប្រទេសម្ចាស់ជំនួយ មានន័យថា

នេះជាឱកាសដ៏ល្អក្នុងការស្វែងរកគំរោងការយុត្តិធម៌បន្ថែមទៀត ដើម្បីដោះស្រាយបទល្មើសដែលប្រព្រឹត្តក្នុងរបបខ្មែរក្រហម។

ការព្រួយបារម្ភដ៏សំខាន់របស់មនុស្ស ដែលបានសម្ភាសជាច្រើនគឺថា ប្រវត្តិសាស្ត្រមិនអាចកើតមានជាថ្មីម្តងទៀត ហើយថាមនុស្សជំនាន់ក្រោយបានយល់ និងជឿរឿងរបស់អ្នកដែលធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម។ ជាធម្មតាការឱ្យជនរងគ្រោះទាំងនេះ បានបញ្ចេញមតិ ហើយរឿងរបស់ពួកគាត់ត្រូវបានអ្នកដទៃបានឮ និងយល់ច្បាស់ជាពិសេស យុវជនកម្ពុជាជំនាន់ក្រោយនោះ បានធ្វើឱ្យសម្ភាសិតជាច្រើនសប្បាយរីករាយ។ ការអប់រំជាសាធារណៈអំពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមនឹងជាឧបករណ៍ដ៏មានតម្លៃមួយបន្ថែមទៅលើសាលាក្តីពិសេសនេះ។

## ក. សុវត្ថិភាពការអប់រំសាធារណៈ

សំខាន់ណាស់ថា ក្នុងការពិភាក្សាអំពីអំពើហិង្សាផ្លូវភេទជាមួយប្រជាជនពួកគាត់មានអារម្មណ៍កក់ក្តៅ។ មនុស្សជាច្រើន ដែលបានឃើញឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមតែងមានការភ័យខ្លាចអំពីសុវត្ថិភាពរបស់ខ្លួន។ គ្រោះថ្នាក់ចំពោះពួកគាត់អាចមិនធ្ងន់ធ្ងរដូចពួកគាត់នឹកគិតទេ តែអាចធ្វើឱ្យគាត់ភ័យខ្លាច។ នៅពេលមានសវនាការពេលខាងមុខនេះ អាចមានការរំខាន និង អសន្តិសុខកើនឡើងក្នុងសហគមន៍ដែលជនល្មើសរស់នៅ។ ការយល់ដឹងមានកំរិតអំពីវិសាលភាព និង យុត្តាធិការនៃសាលាក្តីពិសេសនេះ ហើយជនល្មើសដែលភ័យខ្លាចមានគេរកឃើញអាចចាត់ឧបាយកលបំបាត់សាក្សី។

ស្លាកស្នាមទុរយស និង ការរិះគន់ដែលមានចំពោះជនរងគ្រោះដោយការរំលោភនឹងមិនត្រូវបានគេមើលងាយទៀតឡើយ។ ខណៈពេលមានចលនាមួយក្នុងប្រទេសកម្ពុជា ដើម្បីបញ្ចប់និទណ្ឌភាពចំពោះអ្នករំលោភ និង បំបាត់ការរិះគន់លើ

ជនរងគ្រោះនោះសង្គមកម្ពុជានៅតែមានការរិះគន់ខ្លះៗ លើជនរងគ្រោះពីការរំលោភ។ នាង Surtees ពន្យល់ថាៈ

ការទទួលខុសត្រូវចំពោះបទល្មើសរំលោភ ស្ថិតនៅយ៉ាងហោចណាស់ខាងស្ត្រីខ្លះដែរ... ម្យ៉ាង បើសិនស្ត្រីនោះជាមនុស្សល្អ នោះតាមនិយមន័យ ការទាក់ទងផ្លូវភេទណាមួយនោះត្រូវតែជាការរំលោភ។ តែម្យ៉ាងវិញ បើគេរំលោភនាងយ៉ាងណាក៏គេរិះគន់នាងដែរ ដូច្នេះនាងជាមនុស្សមិនល្អ ហើយកិត្តិយសគ្រួសារនាងទាំងមូលទទួលផលមិនល្អ។ ដូច្នេះ ស្ត្រីដែលគេដឹងថាជាជនរងគ្រោះ តាមការផាកវិន័យទៅលើបុរសចំពោះបទល្មើសផ្លូវភេទ (ទោះជាបង្ខំ ឬស្ម័គ្រចិត្ត)។ ទន្ទឹមនឹងពេលនោះដែរ ស្ថានភាពមិនអាចលុបលៀងបានរបស់ស្ត្រីបានដាក់ទំងន់លើស្ត្រី ទាំងផ្នែកសង្គម និង អារម្មណ៍ ដោយមានទទួលខុសត្រូវមួយចំនួន។

ដើម្បីដោះស្រាយបញ្ហាស្លាកស្នាមទុរយសនោះ អង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ជំរើសដល់ជនរងគ្រោះអំពីរបៀប ដែលពួកគាត់និយាយពីបទពិសោធន៍ ហើយថាតើសំដែងឡើងជាសាធារណៈ ឬជាឯកជន។ បងស្រីតាំងគីមបាននិយាយជាសាធារណៈអំពីបទពិសោធន៍ ដែលគេរំលោភបងស្រីក្នុងរបបខ្មែរក្រហមក្នុងភាពយន្តឯកសារដែលបង្ហាញទាំងរឿងនិងអត្ត-សញ្ញាណរបស់នាង។ ផ្នែកឯកសារភាពយន្តនេះ ធ្វើឱ្យនាងក្លាយជាដូនជី ជាសេចក្តីសំរេចមួយដែលនាងទំនងជាសំរេចចិត្តក្នុងពេលថតខ្សែភាពយន្ត។ ខណៈពេលដែលវាមិនមានការទាក់ទងគ្នាទេនោះ វាអាចថាបានដឹងអ្វីដែលបានកើតឡើងដល់ បងកាន់តែមានអារម្មណ៍កក់ក្តៅក្នុងការ ចាកចេញពីសហគមន៍នាង ហើយក្លាយខ្លួនជាដូនជី ជាជាងស្ថិតនៅប្រឈមមុខស្លាកស្នាមទុរយសដែលក្លាយខ្លួនជាជនរងគ្រោះផ្លូវភេទ។ អ្នកដែលផ្សព្វផ្សាយបទពិសោធន៍របស់ជនរងគ្រោះត្រូវផ្តល់ឱ្យជនរងគ្រោះ និង សាក្សីនូវជំរើសការពារអត្តសញ្ញាណ

របស់ខ្លួន។ អ្វីដែលសំខាន់គឺថា សហគមន៍យល់ពីរឿងរបស់ខ្លួន មិនមែនជាការស្គាល់ឈ្មោះទេ។

## ខ~ អត្ថប្រយោជន៍សំរាប់ប្រទេសកម្ពុជាបច្ចុប្បន្ន

ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការនិយាយ អំពីបទពិសោធន៍នៃអំពើហិង្សាផ្លូវភេទ មិនត្រឹមតែអាចជួយបុគ្គលយល់ព្រមនឹងបទពិសោធន៍របស់ខ្លួន តែថែមទាំងជួយបញ្ចប់ភាពស្ងៀមស្ងាត់ជុំវិញរឿងហិង្សាផ្លូវភេទ ដែលមានក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ការរក្សាភាពស្ងៀមស្ងាត់ និង ការមានស្លាកស្នាមទុរយសជុំវិញការរំលោភ និង អំពើហិង្សាផ្លូវភេទដទៃទៀតជាការបន្ថែមដល់និទណ្ឌភាព ដែលជនល្មើសពេញចិត្តប្រទេសកម្ពុជាសព្វថ្ងៃនេះ។ តាមការចាប់ផ្តើមពិភាក្សាអំពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម យើងអាចជួយបំបាត់ភាពស្ងៀមស្ងាត់អំពីបទល្មើសផ្លូវភេទ។

ខាងក្រោមនេះជាគំនិតមួយចំនួនចំពោះសកម្មភាពរបស់អង្គការ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈនៃអំពើហិង្សា ផ្លូវភេទក្នុងរបបខ្មែរក្រហម។

- បញ្ចូលការពិភាក្សាស្តីពីអំពើហិង្សាផ្លូវភេទក្នុងកម្មវិធីសំខាន់ៗ ស្តីពីសវនាការរបស់សាលាក្តីពិសេស
- បញ្ចូលការពិភាក្សា ស្តីពីអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហមក្នុងកម្មវិធីអប់រំសិទ្ធិនារី
- បង្ហាញពីភាពយន្តឯកសារដែលផលិតដោយអង្គការ DC-Cam អំពីការរំលោភក្នុងរបបខ្មែរក្រហម
- បង្កើតនាដកម្មតាមវិទ្យុ ឬសំភារៈអប់រំសាធារណៈដទៃទៀត ដែលពន្យល់ ឬបញ្ចូលបទពិសោធន៍រងគ្រោះដោយអំពើហិង្សាផ្លូវភេទរបស់ស្ត្រី ក្នុងរបបខ្មែរក្រហម។

## IX. **សេចក្តីសន្និដ្ឋាន**

ខណៈពេលដែលរដ្ឋាភិបាលហាមឃាត់ជាផ្លូវការ នូវទំនាក់ទំនងស្នេហាក្រៅចំណងអាពាហ៍ពិពាហ៍ ទោះជាព្រមព្រៀង ឬមិនព្រមព្រៀង តែអំពើហិង្សាផ្លូវភេទនៅតែកើតមានក្នុងរបបខ្មែរក្រហម។ ដោយទាំងជនល្មើស និង ជនរងគ្រោះត្រូវតែទទួលទោសនោះ ជនល្មើសដឹងច្បាស់ថា ជនរងគ្រោះភាគច្រើនមុខជាមិនរាយការណ៍អំពីការរំលោភឡើយ។ ជនល្មើសដទៃទៀត សំលាប់ជនរងគ្រោះដើម្បីបំបាត់មាត់។ សម្ភាសិតនិយាយថា មន្រ្តីមូលដ្ឋានដែលទទួលបន្ទុកអនុវត្តនយោបាយនោះ បានប្រព្រឹត្តអំពើហិង្សាផ្លូវភេទជាច្រើន។ ពួកវាហាក់ដូចជាមិនមានអ្នកគ្រប់គ្រងពីលើ ឬប្រព្រឹត្តដោយការឯកភាពពីថ្នាក់លើ ដោយបណ្តោយឱ្យមន្រ្តីថ្នាក់ក្រោមរំលោភជាចំហ។ អ្នកដែលគេចាប់ដាក់គុកក្នុងរបបខ្មែរក្រហម និង អ្នកដែលគេយកទៅសំលាប់ចោលមានភាពងាយរងគ្រោះដោយឡែកចំពោះអំពើហិង្សាផ្លូវភេទ ជាមន្រ្តីដែលពួកគេមិនមានអំណាចគ្រប់គ្រងពេញលេញ លើជោគវាសនាខ្លួន។

រដ្ឋាភិបាលលើកលែងទោស ហើយជំរុញឱ្យមានទំនាក់ទំនងស្នេហាក្នុងចំណងអាពាហ៍ពិពាហ៍ ព្រោះពួកគេត្រូវការមនុស្ស ដើម្បីធ្វើការងារកសិកម្ម ដែលជាសសរគោលរបស់បដិវត្តន៍។ នយោបាយនេះធ្វើឱ្យមានអំពើហិង្សាផ្លូវភេទថែមទៀត ព្រោះមន្រ្តីដែលមានភារកិច្ចរៀបចំអាពាហ៍ពិពាហ៍ ឱ្យប្រជាជនក្នុងរបបខ្មែរក្រហមប្រើអំពើហិង្សាផ្លូវភេទដើម្បីឱ្យព្រមរៀបការ។ ទោះជាសកម្មភាពផ្លូវភេទ មានការព្រមព្រៀង ឬមិនមានការព្រមព្រៀងក៏ដោយ ក៏មិនមានការព្រួយបារម្ភណ៍ចំពោះរដ្ឋាភិបាល ហើយគូស្រករខ្លះឈ្លៀតយកប្រយោជន៍នេះ ដើម្បីរំលោភដៃគូថ្មីថ្មោងរបស់ខ្លួន ដោយគ្មានទោស។

សាលាក្តីពិសេសអាចតំណាងឱ្យឱកាសមួយ ដើម្បីទទួលស្គាល់ និងដោះស្រាយជាចុងក្រោយនូវអំពើហិង្សាផ្លូវភេទដែល កើតឡើងក្នុងរបបខ្មែរក្រហម។ តែពាក្យ

ពេជន៍ក្នុងច្បាប់របស់សាលាក្តីពិសេសនេះមានន័យថា ការកាត់ទោសដោយជោគជ័យ ចំពោះអំពើហិង្សាផ្លូវភេទមិនមានលក្ខណៈច្បាស់លាស់ ។ ក៏ប៉ុន្តែ តួអង្គនៅក្រៅសាលាក្តីនេះអាចជួយធ្វើឱ្យតុលាការពិតជាទទួលស្គាល់បញ្ហានេះ ហើយធានាថា សាលាក្តីពិសេសនេះ គិតគូដោយយកចិត្តទុកដាក់បំផុតដល់អ្នកដែលមានសេចក្តីក្លាហានចេញមុខ មកប្រាប់រឿងរបស់ខ្លួន។

ការព្រួយបារម្ភដ៏សំខាន់មួយរបស់ជនរងគ្រោះ ដែលចូលរួមក្នុងការស្រាវជ្រាវនេះគឺថា ប្រជាជនកម្ពុជាគប្បីដឹងរឿងរបស់ខ្លួន ហើយសាលាក្តីពិសេសមិនគួរគប្បីទទួលខុសត្រូវតែចំពោះភារកិច្ចនោះតែម្នាក់ឯងឡើយ។ ការរួមចំណែកផ្តល់ព័ត៌មានក្នុងរបាយការណ៍នេះ និង ក្នុងការស្រាវជ្រាវដទៃទៀតស្តីពីបញ្ហាយេនឌ័រ ក្នុងរបបខ្មែរក្រហមដោយមានការចូលរួមស្តាប់កាន់ តែទូលំទូលាយនោះ នឹងជួយអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្ររបស់ខ្លួន ហើយអាចឃើញផ្លូវបញ្ចប់ភាពស្ងៀមស្ងាត់ដែលនៅតែបិទបាំងអំពើហិង្សាផ្លូវភេទក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ។

## X. **វិធីសាស្ត្រស្រាវជ្រាវ**

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា មានបណ្តាញការងារធំធេងផ្នែកឃ្លាំមើលអំពើហិង្សាគ្រួសារ។ ភ្នាក់ងារឃ្លាំមើលចំនួន ១០ក្នុងខេត្តចំនួន៥ បានធ្វើការស្ទង់មតិបឋមដែលមានអ្នកចូលរួមចំនួន១៥០០នាក់ ចាប់ពីអាយុ៤៣ឆ្នាំឡើងទៅដែលបានរស់ក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់១៩៧៩។ ការស្ទង់មតិនោះបានសាកសួរសំណួរសំរាប់ទិន្នន័យជាមូលដ្ឋាន និង សំណួរពីការរៀបការដោយបង្ខំគោលនយោបាយផ្លូវភេទរបស់ខ្មែរក្រហម ពេស្យាកម្មដោយបង្ខំ ការបង្ខំឱ្យអាក្រាតកាយ ការចាប់រំលោភ ការមានផ្ទៃពោះដោយបង្ខំ ការកាត់អវយវផ្លូវភេទ និង អំពើហិង្សាផ្លូវភេទក្នុងគុក និង ក្នុងមណ្ឌលកែប្រែ ហើយសួរថា តើអ្នកផ្តល់ព័ត៌មានបានឃើញ

ឬក៏បានឆ្លងកាត់ព្រឹត្តិការណ៍នេះដោយខ្លួនឯងវឹទេ? ភ្នាក់ងារឃ្លាំមើលបានសម្ភាសបុរស និងស្ត្រី ដែលយើងជឿថា បុរសទាំងនោះក៏អាចជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទដែរ ឬជាអ្នកបានឃើញផ្ទាល់ភ្នែក ហើយថាពួកគាត់ក៏ទទួលរងនូវអាពាហ៍ពិពាហ៍ដោយបង្ខំដែរ ។

ភ្នាក់ងារឃ្លាំមើលបានរាយការណ៍ថា មនុស្សមួយចំនួនមានការស្ទាក់ស្ទើរមិនចង់និយាយពីបទពិសោធន៍របស់ខ្លួន ។ ជួនកាលគេបានចុះទៅដល់អ្នកផ្តល់ព័ត៌មានម្តងហើយម្តងទៀតដើម្បីឱ្យមានការទុកចិត្តមុនពេលពួកគេធ្វើការស្ទង់មតិនេះ ។ ខណៈពេលការស្ទង់មតិនេះធ្វើជាលក្ខណៈព្រាវៗនោះ ភ្នាក់ងារឃ្លាំមើលមួយចំនួនសម្ភាសមនុស្ស ដែលពួកគេដឹងថាបានទទួលរងអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម ។

ភ្នាក់ងារឃ្លាំមើលបានបញ្ជូនការស្ទង់មតិរបស់ខ្លួន រួមទាំងកំណត់បន្ថែមស្តីពីអ្នកផ្តល់ព័ត៌មានដែលមានប្រយោជន៍ ពិសេសចំពោះអ្នកស្រាវជ្រាវក្នុងទីក្រុងភ្នំពេញ ។ គេបានត្រួតពិនិត្យរបាយការណ៍ស្ទង់មតិនិមួយៗ ហើយបានជ្រើសរើសអ្នកផ្តល់ព័ត៌មានសំខាន់ៗប្រមាណ២០នាក់ពីខេត្តនីមួយៗ ។ ខេត្តមួយចំនួនទទួលបានអ្នកផ្តល់ព័ត៌មានច្រើនជាងខេត្តដទៃ ប្រហែលមកពីអត្រាខ្ពស់ជាងនៃអំពើហិង្សាផ្លូវភេទនិង ការរៀបការដោយបង្ខំនៅតំបន់ទាំងនោះ ឬដោយសារភ្នាក់ងារ ឃ្លាំមើលមានការប្តេជ្ញាចិត្តខ្លាំងជាងគេចំពោះគំរោងការនេះក្នុងខេត្តនោះ ។ ជាសរុប យើងសម្ភាសមនុស្សចំនួន៩៦នាក់ អំពីបទពិសោធន៍របស់ខ្លួន ដោយមានប្រុស២៨នាក់ និង ស្រី៦៨នាក់ ។ យើងជ្រើសរើសតែសម្ភាសិតណា ដែលនិយាយថាខ្លួនជាជនរងគ្រោះ ឬសាក្សី ហើយរបាយការណ៍នេះបញ្ចូលសក្ខីកម្មរបស់អ្នកដែលយើងកំណត់ថា ជាជនរងគ្រោះ និង សាក្សី ។ ខណៈដែលរយៈពេលកន្លងទៅយូរមានន័យថាដំណើរ រឿងខ្លះរបស់សាក្សី និង ជនរងគ្រោះអាចជឿទុកចិត្តតិចជាងការដែលពួកគាត់ រាយការណ៍ក្រោយ

ពីរបបខ្មែរក្រហមដួលរលំភ្លាមៗ។ អ្នកដែលបានឃើញ ឬបានទទួលរងអំពើឧក្រិដ្ឋនេះមានសក្តិកម្មជឿទុក ចិត្តខ្ពស់បំផុត ហើយតែងនឹកឃើញបទពិសោធន៍របស់ខ្លួនឡើងវិញបានយ៉ាងល្អ។

ភ្នាក់ងារឃ្លាំមើលរៀបចំពេលវេលាសម្ភាស ហើយសម្ភាសិត និង អ្នកធ្វើការសម្ភាសន៍កំណត់ទីកន្លែងដើម្បីសម្ភាស ឧទាហរណ៍ នៅផ្ទះរបស់ភ្នាក់ងារឃ្លាំមើល ផ្ទះរបស់សម្ភាសិត ទីវត្តអារាម ឬសាលាឃុំ។ ការសម្ភាសន៍ធ្វើឡើងជាឯកជនតែរក្សា ភាពសម្ងាត់ដែលតែងតែពន្យាការសម្ភាសន៍ដើម្បីសុំឱ្យមនុស្សឈរមើលចាកចេញសិន។

បទសម្ភាសន៍ខ្លះមានការលំបាក ដោយសារបញ្ហាបកប្រែ ឬដោយសារតែសម្ភាសិតមានអារម្មណ៍ភ័យខ្លាចជាពិសេស។ អ្នកបកប្រែរួមទាំងអ្នកសម្ភាសលោកស្រី កាស៊ូមី ដែលមិនមែនជាអ្នកចេះភាសាខ្មែរពីកំណើត តែងជួបប្រទះថាសម្ភាសិត ប្រើគ្រាមភាសាតាមតំបន់របស់ខ្លួន និង តួលេខក្រៅផ្លូវការដែលធ្វើឱ្យពិបាកយល់។ សម្ភាសិតតែងប្រាប់ដំណើររឿងទៅមុខទៅ ក្រោយដែលមានទាំងព្រឹត្តិការណ៍ខុសៗគ្នាទៀតផង។ បញ្ហានេះមានន័យថា ជួនកាលយើងមិនបានសាកសួរដេញតាមសំណួរ សំខាន់ៗទេ។ បទសម្ភាសន៍ស្ទើរតែទាំងអស់ត្រូវបានថតជាខ្សែអាត់ ហើយយើងខិតខំកែតំរូវការភ័ន្តច្រលំណាដែលកើតមានក្នុង ពេលសម្ភាសដោយយកចិត្តទុកដាក់ត្រួតពិនិត្យ និង បកប្រែបទសម្ភាសក្នុងខ្សែអាត់។

សេវាចិត្តសាស្ត្រមានកំរិតបំផុតក្នុងប្រទេសកម្ពុជា ហើយយើងមិនអាចផ្តល់សេវា ឬការគាំទ្រជាប្រចាំទៅដល់អ្នកដែលបានចូលរួមក្នុងការធ្វើសម្ភាសនេះ។ ការសម្ភាសន៍ពិតជាមានការជាប់ពាក់ព័ន្ធចំពោះសុខមាលភាពផ្នែកចិត្តសាស្ត្ររបស់មនុស្ស ហើយយើងបានពិគ្រោះជាមួយអង្គការសេវាសង្គមកម្ពុជាចំពោះដំបូន្មាន ស្តីពីរបៀបដោះស្រាយការកង្វល់ទាំងនេះ។ យើងយល់ថា ការសម្ភាសន៍គប្បីកំរិតតែទៅលើ

ប្រធានបទណាដែលយើងកំពុងសិក្សា បើទោះជាគេបានលើកឡើងនូវបទពិសោធន៍ឈឺចាប់ ដ៏សំខាន់បំផុតដែលតែងមិនស្ថិតក្នុងវិស័យសិក្សារបស់យើង។ មានន័យថាពួកគាត់នឹងមិននិយាយឡើងវិញនូវបទពិសោធន៍ដ៏ឈឺចាប់ទាំងអស់របស់ខ្លួន ដោយខ្លាចមានការឈឺចាប់បន្ថែមទៀត ហើយបានជៀសវាងការជំពាក់ជំពិនខាងសីលធម៌របស់សម្ភាសិត ដែលគិតថាយើងនឹងរាយការណ៍នូវបទពិសោធន៍ទាំងអស់នោះ។ នៅពេលដឹងថា សម្ភាសិតមានអារម្មណ៍ក្រៀមក្រំ ភ័យខ្លាច តានតឹង យើងបានស្នើសម្ភាសិតឱ្យបង្ហាញបណ្ដាញទ្រទ្រង់របស់ខ្លួន ឧទាហរណ៍ដូចជាព្រះសង្ឃ មាតាបិតា និង មិត្រដែលអាចនិយាយបាន។ យើងក៏បានស្នើរឱ្យភ្នាក់ងារឃ្លាំមើលចុះសួរសុខទុក្ខសម្ភាសិតក្នុងរយៈពេល៣ថ្ងៃនៃការសម្ភាសន៍ ដើម្បីសួរថាតើពួកគាត់មានអារម្មណ៍យ៉ាងណាអំពីការសម្ភាសន៍នោះ ហើយថាតើពួកគាត់មានបញ្ហា ឬការព្រួយបារម្ភដោយសារតែការធ្វើសម្ភាសនេះទេ? យើងបានស្នើរឱ្យភ្នាក់ងារឃ្លាំមើលរាយការណ៍បញ្ហានានាមកកាន់យើងដូច្នេះយើងអាចចាត់វិធានការណ៍បន្ថែមទៀត បើសមស្រប។

ការយល់ព្រម ដែលបានដឹងពិតប្រាកដពិបាកនឹងទទួលណាស់ក្នុងប្រទេសកម្ពុជា។ ខណៈពេលដែលយើងតែងតែព្យាយាមធ្វើឱ្យសម្ភាសិតពិតជានិយាយមករកយើងដោយឆន្ទៈសេរី ហើយទីតាំងធ្វើសម្ភាសមានផាសុខភាពនោះ យើងមិនអាចជឿជាក់ថា ពុំមានការបង្ខំនៅក៏រិតណាមួយដែលកំណត់ដោយភ្នាក់ងារឃ្លាំមើល ឬប្រការដែលថា អ្នកស្រាវជ្រាវមក ពីទីក្រុងភ្នំពេញមានឆន្ទៈសម្ភាសពួកគាត់។ នៅពេលសម្ភាសិតបង្ហាញសញ្ញាថា មិនមានផាសុខភាព ឬការភ័យខ្លាចនោះ យើងនឹងខិតខំធ្វើការងារបន្ថែមទៀត ដើម្បីឱ្យពួកគាត់ពិតជាមានឆន្ទៈចូលរួមក្នុងការសម្ភាសន៍ ហើយពួកគាត់មានភាពសុខស្រួល ជាមួយកាលៈទេសៈពេលវេលានៃកាធ្វើសម្ភាស។ តែសម្ភាសិតភាគច្រើនសប្បាយដោយមានឱកាសចែករំលែករឿងរ៉ាវរបស់ខ្លួន ជារឿយៗ រឿងដែល ពួកគាត់មិនបានចែករំលែកពីមុន។

## XI. ជំរើសឯកសារយោង

### អំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម


Katrina Anderson, “Gender and Transitional Justice: Turning Reconciliation on Its Head: Responding to Sexual Violence Under the Khmer Rouge” (2005) 3 *Seattle J. Soc. Just.* 785.

Ratana Huy, “Khmer Rouge Wedding” *Searching for the Truth* (DC-Cam, Phnom Penh, Cambodia) (2002) Number 25, 26.

Monika Satya Kalra “Forced Marriage: Rwanda’s Secret Revealed” (2001) 7 U.C. Davis J. Int’l L & Pol’y 197

Kalyanee Mam, “Evidence of Sexual Abuse during the Rule of the DK” *Searching for the Truth* (DC-Cam, Phnom Penh, Cambodia) (2001) Number 15, 2.

Kalyanee Mam, “Koh Khsach Chunlea: An Island of Widows” Documentation Center of Cambodia

Kalyanee Mam, “The Endurance of the Cambodian Family Under the Khmer Rouge Regime: An Oral History” in Cook, Susan E. (ed.) *Genocide in Rwanda and Cambodia: New Perspective.*

Rachana Phat and Youk Chhang *The Khmer Rouge Rice Fields: The Story of Rape Survivor Tang Kim* (2004).


### អំពើហិង្សាផ្លូវភេទក្នុងជំលោះដទៃទៀត


Amnesty International, *Lives Blown Apart: Crimes Against Women in times of Conflict* 2004.

Human Rights Watch, *Shattered Lives: Sexual Violence during the Rwandan Genocide and its Aftermath* (last accessed at www.hrw.org/reports/1996/Rwanda.htm 11 August 2006).

Human Rights Watch, *We’ll Kill you if you Cry: Sexual Violence in the Sierra Leone Conflict* (2003), available at http://www.hrw.org/reprorts/2003/sierraleone/sierleon0103.pdf (last visited Aug. 25, 2005).

David Boyle “The Rights of Victims: Participation, Representation, Protection and Reparation” *Journal of International Criminal Justice* 4 (2006) 307.

Kvinna Till Kvinna, *Voices from the Field: About Prosecution of Sexualized Violence in an International Context* (2004) http://www.iktk.se/publikationer/rapporter/pdf/Voices.pdf (last accessed 17 August 2006)

Binaifer Nowrojee, *Your Justice is too Slow: Will the ICTR fail Rwanda's Rape Victims?* United Nations Research Institute For Social Development Occasional Paper 10 (November 2005) http://www.unrisd.org/

International Commission of Jurists, *Trial Observation Manual* (June 2002) (last accessed 2 October 2006 at http://www.hrea.org/erc/Library/monitoring/icj02.pdf#search=%22international%20commission%20of%20jurists%20trial%20observation%20manual%22).

University of California at Berkeley, *Sierra Leone Trial Monitoring Program* (last accessed 2 October 2006 at http://socrates.berkeley.edu/~warcrime/SL-archives.htm).

Office of the High Commissioner for Human Rights, *Training Manual on Human Rights Monitoring* (last accessed 2 October 2006 at http://www1.umn.edu/humanrts/monitoring/index.html)